# សេចក្តីផ្តើម

សព្វថ្ងៃ សញ្ញាសម្គាល់របស់ព្រះជាម្ចាស់នៅក្នុងលោកនេះ ដូចជាពិបាករកឃើញ ហើយចំពោះអ្នកខ្លះគ្មានសោះតែម្តង ។ សន្តៈប៉ូលសរសេរសម្រាប់ជនជាតិរ៉ូម៉ាំងថា៖ *"លក្ខណៈដ៏ប្រសើរបំផុតរបស់ព្រះអង្គដែលមនុស្សមើលពុំឃើញ គឺឫទ្ធានុភាពដែលនៅស្ថិតស្ថេរអស់កល្បជានិច្ចក្តី ឬឋានៈរបស់ព្រះអង្គជាព្រះជាម្ចាស់ក្តី ព្រះអង្គបានសម្តែងឲ្យគេឃើញតាំងពីកំណើតពិភពលោកមកម្ល៉េះ នៅពេលណាដែលគេរិះគិតអំពីស្នាព្រះហស្តរបស់ព្រះអង្គ ។ដូច្នេះគេពុំអាចដោះសាខ្លួនបានឡើយ"*(**រម១,២០**)។ប៉ុន្តែគ្មានស្នាព្រះហស្តណារបស់ព្រះជាម្ចាស់ សូម្បីតែមេឃ និងដីមិនបានបង្ហាញភស្តុតាងច្បាស់លាស់ អំពីវត្តមានរបស់ព្រះអង្គឡើយ។ ពេលនោះ គ្រីស្តបរិស័ទបែរមុខទៅរកព្រះគ្រីស្តដែលជា *"រូបតំណាងរបស់ព្រះជាម្ចាស់ ដែលយើងមើលពុំឃើញ"* (**កូឡ ១,១៥**) គឺព្រះជាម្ចាស់ប្រសូតជាមនុស្សយាងមកក្នុងលោកនេះ ក្នុងអង្គព្រះគ្រីស្ត។ ប៉ុន្តែតើព្រះគ្រីស្តនេះ បានបង្ហាញភស្តុតាងច្បាស់លាស់អំពីព្រះជាម្ចាស់? សន្តៈប៉ូល បានទទួលស្គាល់ថា៖ *"ជនជាតិយូដាសុំមើលទីសម្គាល់ដ៏អស្ចារ្យ ឯជនជាតិក្រិករកភស្តុតាងតាមប្រាជ្ញា រីឯយើងវិញ យើងប្រកាសអំពីព្រះគ្រីស្ត ដែលសោយទិវង្គតនៅលើឈើឆ្កាង ។ ជនជាតិយូដាយល់ឃើញថា ពាក្យប្រកាសនេះ រារាំងគេមិនឲ្យជឿបាន ហើយជនជាតិដទៃយល់ឃើញថាជារឿងលេលា"* (**១ករ ១,២២-២៤**)។

តើមានព្រះជាម្ចាស់ឬទេ? សព្វថ្ងៃ ចំពោះមនុស្សភាគច្រើន សំណួរនេះ ពិតជាពិបាកឆ្លើយមែន ជាពិសេសអំពើអាក្រក់ និងទុក្ខលំបាករារាំងគេមិនអាចជឿលើព្រះជាម្ចាស់បានឡើយ គឺបើមានព្រះជាម្ចាស់មែនហេតុអ្វីបានជាមានអំពើអាក្រក់[1]?

យើងជាគ្រីស្តបរិស័ទត្រូវតែ *"ប្រុងប្រៀបខ្លួនឆ្លើយតទល់នឹងអស់អ្នកដែលសាកសួរអំពីសេចក្តីសង្ឃឹមរបស់បងប្អូនជានិច្ច"* (**១ ស ៣,១៥**) ដ្បិតមូលដ្ឋានគ្រឹះនៃជំនឿរបស់យើងស្ថិតនៅលើព្រះបន្ទូល ដែលមានក្នុង យហ ១,១៨ ៖ "ពុំដែលមាននរណាម្នាក់ បានឃើញព្រះជាម្ចាស់ឡើយ មានតែព្រះបុត្រាមួយព្រះអង្គប៉ុណ្ណោះ ដែលបាននាំយើងឲ្យស្គាល់ព្រះអង្គ ដ្បិតព្រះបុត្រាមានព្រះជន្មរួមជាមួយព្រះបិតា" ទោះបីជាការអះអាងបែបនេះ អាចនាំអ្នកកាន់សាសនាដទៃជំទាស់យ៉ាងណាក៏ដោយ។ប៉ុន្តែត្រូវឆ្លើយទៅគេដោយទន់ភ្លន់ ដោយគោរព និងដោយមានមនសិការល្អ"( ១ ស ៣,១៦ )។

[1] *សូមអានលទ្ធិគ្រីស្តសាសនាតាមព្រះសហគមន៍កាតូលិកពីលេខ២១២៣ដល់លេខ២១២៨*

# ជំពូកទី១
# អ្វីទៅជាទេវវិទ្យា?

****

## ១) ជំនឿ និងប្រាជ្ញា

ហេតុអ្វីបានជាព្រះអង្គលាក់ព្រះភ័ក្ត្រកុំឲ្យទូលបង្គំឃើញ? សំណួរនេះ មានក្នុងទំនុកតម្កើងជាច្រើន។ នៅពេលដែលព្រះអម្ចាស់លាក់ព្រះភ័ក្ត្ររបស់ព្រះអង្គ អ្នកជឿអស់សង្ឃឹម គ្មានទីពឹង ជិតស្លាប់។ *"ប្រសិនបើព្រះអម្ចាស់មិនគង់ជាមួយទូលបង្គំទេនោះ ទូលបង្គំនឹងភ័យខ្លាចក្រៃលែង"* (ទន ៨៨,១៥)។ គ្រប់ពេលវេលាអ្នកជឿបែរមុខទៅរកព្រះអម្ចាស់ ដើម្បីទូលទៅព្រះអង្គថា៖ *"ទូលបង្គំស្វែងរកព្រះភ័ក្ត្ររបស់ព្រះអង្គ"* (ទន ៣០,៨)។ តើការស្វែងរកនេះ អាចទទួលជោគជ័យបានឬទេ? តាមសន្តៈយ៉ូហាន *"ពុំដែលមាននរណាម្នាក់បានឃើញព្រះជាម្ចាស់ឡើយ"* ប៉ុន្តែលោកបន្ថែមភ្លាមថា៖ *"មានតែព្រះបុត្រាមួយព្រះអង្គប៉ុណ្ណោះ ដែលបាននាំយើងឲ្យស្គាល់ព្រះអង្គ ដ្បិតព្រះបុត្រាមានព្រះជន្មរួមជាមួយព្រះបិតា"* (យហ ១,១៨)។ ព្រះយេស៊ូមានព្រះបន្ទូលដដែលចំពោះលោកថូម៉ាស៖ *"បើអ្នករាល់គ្នាស្គាល់ខ្ញុំ អ្នករាល់គ្នាក៏ស្គាល់ព្រះបិតារបស់ខ្ញុំដែរ។ ឥឡូវនេះអ្នករាល់គ្នាស្គាល់ព្រះអង្គហើយព្រមទាំងបានឃើញព្រះអង្គថែមទៀតផង"* (យហ ១៤,៧)។ លើសពីនេះទៅទៀត ព្រះយេស៊ូមានព្រះបន្ទូលថែមទៀតថា៖ *"អ្នកណាបានឃើញខ្ញុំក៏បានឃើញព្រះបិតាដែរ"* (យហ ១៤,៩)! ការអះអាងនេះ ជាស្នូលនៃជំនឿរបស់គ្រីស្តបរិស័ទ។

ប៉ុន្តែត្រូវធ្វើដូចម្តេចដើម្បីជឿថា ព្រះបន្ទូលនេះ ពិតប្រាកដមែន? តើយើងអាចជឿព្រះយេស៊ូឬទេ? ទេវវិទូមានគោលដៅតែមួយ គឺពិនិត្យបញ្ជាក់ព្រះបន្ទូលនេះ។ តាមសន្តៈ អង់សេលម៍ (Anselme) ទេវវិទ្យាចេញមកពីជំនឿដែលស្វែងរកការយល់ដឹង៖ Fides quaerens intellectum គឺអ្នកជឿចង់យល់អំពីអ្វីដែលខ្លួនគេជឿ ឬ *"ជំនឿចង់បានប្រាជ្ញា"* បានសេចក្តីថា ទេវវិទូមិនព្រមបំបែកជំនឿចេញពីប្រាជ្ញាឡើយ (ទោះបីត្រូវតែជឿមុននឹងយល់)។ សន្តៈអូគូស្ទីន (Augustine) មានប្រសាសន៍ថា៖ *"បើយើងមិនចេះរិះគិតពិចារណាទេ យើងមិនអាចមានជំនឿពិតប្រាកដបានឡើយ"*។ ជំនឿសំខាន់ជាងប្រាជ្ញា ប៉ុន្តែអ្នកជឿត្រូវយល់ដើម្បីជឿ។ អ្នកជឿស្វែងរកអំពីហេតុផលនៃ ជំនឿដោយប្រើប្រាជ្ញា ហើយនៅពេលដែលគេយល់កាន់តែស៊ីជម្រៅ គេមានជំនឿកាន់តែមាំមួនឡើងៗ។ ប៉ុន្តែសន្តៈអូគូស្ទីនបន្ថែមទៀតថា៖ *"កុំស្វែងយល់ដើម្បីជឿ ប៉ុន្តែសូមជឿដើម្បីយល់"*។ ទេវវិទ្យាជា *"វិទ្យាសាស្ត្រនៃជំនឿ"*។

## ២) ទេវវិទ្យា និងទស្សនវិទ្យា

ទេវវិទ្យាចាក់ឫសលើបទពិសោធន៍របស់អ្នកជឿ ទេវវិទូចង់យល់ដឹងអំពីបទពិសោធន៍របស់ខ្លួន។ ដូច្នេះហើយ

បានជាទេវវិទ្យាខុសប្លែកពីទស្សនវិទ្យានៃសាសនា គឺទស្សនវិទូនៃសាសនាស្វែងរកអំពីជំនឿដោយអព្យាក្រឹត គឺគេមិនព្រមឲ្យជំនឿប៉ះពាល់នឹងការស្វែងយល់របស់គេឡើយ។ ផ្ទុយទៅវិញ ទេវវិទូជាអ្នកជឿ ដែលរិះគិតអំពីជំនឿរបស់ខ្លួនឯង។ សម្រាប់សន្តៈអង់សេលម៍ ទេវវិទូត្រូវតែអធិដ្ឋានសិន មុននឹងស្វែងរក។ ឯទស្សនវិទូវិញ គេធ្វើដូចជាគេពុំមានជំនឿឡើយ (ឬមួយគេមិនមែនជាអ្នកជឿទេ)។ ទេវវិទូជាអ្នកជឿដែលចង់ស្វែងយល់អំពីបទពិសោធន៍របស់ខ្លួន។ ក្នុងប្រវត្តិសាស្ត្រព្រះសហគមន៍ គ្រីស្តបរិស័ទបានពន្យល់ជំនឿរបស់គេតាមវប្បធម៌ផ្សេងៗ។

ឧ. នៅសម័យជនជាតិយូដា គ្រីស្តបរិស័ទត្រូវបង្ហាញថា ព្រះយេស៊ូជាព្រះមេស្ស៊ី ដែលជនជាតិយូដាកំពុងរង់ចាំ ឯនៅសម័យក្រិកគេត្រូវតែបង្ហាញថា ព្រះគ្រីស្តជាព្រះប្រាជ្ញាញាណដែលជនជាតិក្រិកកំពុងស្វែងរក។ល។ នេះ គឺជាតួនាទីនៃទេវវិទូ។

ម្យ៉ាងទៀត តាមវប្បធម៌ទាំងអស់នោះ មានមនុស្សជាច្រើនរិះគិតអំពីជំនឿ ដោយខ្លួនគេមិន(ព្រម)ជឿ។ គេប្រើមុខវិជ្ជាជាច្រើន ដូចជាប្រវត្តិសាស្ត្រ ចិត្តវិទ្យា សង្គមវិទ្យា ជាពិសេសទស្សនវិទ្យា[2] ដើម្បីរិះគិតអំពីជំនឿរបស់គ្រីស្តបរិស័ទ។ ដោយប្រើអំណះអំណាងពិបាកតទល់ អ្នកទាំងអស់នោះ អាចនាំគ្រីស្តបរិស័ទខ្លះឲ្យបាត់បង់ជំនឿ ប៉ុន្តែតាមការពិតការរិះគន់បែបនេះ ដូចជាឱកាសឲ្យទេវវិទូគ្រីស្តបរិស័ទរិះគិតកាន់តែជ្រាលជ្រៅ អំពីជំនឿវិញ។ ហេតុនេះ ហើយបានជាសន្តៈថូម៉ាសអាគីណាស (Thomas Aquinas) សរសេរថា៖ *"ទស្សនវិទ្យាជាអ្នកបម្រើនៃទេវវិទ្យា"* បានសេចក្តីថា ដោយរិះគន់អំពីជំនឿទស្សនវិទូនាំទេវវិទូឲ្យរិះគិត និងយល់អំពីជំនឿរបស់គេកាន់តែជ្រាលជ្រៅទៅទៀត។

**៣) Fides quae**

ជាភាសាឡាតាំង Fides quae មានន័យថា *"សេចក្តីនៃជំនឿ"*។

## *តើអ្នកជឿត្រូវជឿអ្វីខ្លះ?*

អស់រយៈពេលជាច្រើនសតវត្ស អ្នកដឹកនាំព្រះសហគមន៍ចាត់ទុកថា ការសម្តែងជា "លទ្ធិ" មួយ គឺសេចក្តីដែលត្រូវតែជឿ ដើម្បីទៅជាគ្រីស្តបរិស័ទ។ នៅមហាសន្និបាតវ៉ាទីកង់ទី ២ អស់លោកអភិបាល បានផ្តល់អត្ថន័យថ្មីដល់ការសម្តែង គឺជាព្រះយេស៊ូគ្រីស្តផ្ទាល់ខ្លួនតែម្តង៖

*"ព្រះជាម្ចាស់ប្រកបដោយព្រះហឫទ័យសប្បុរស និងដោយព្រះប្រាជ្ញាញាណ ទ្រង់សព្វព្រះហឫទ័យសម្តែងព្រះអង្គផ្ទាល់ និងសម្តែងគម្រោងការដ៏អស្ចារ្យនៃព្រះហឫទ័យរបស់ព្រះអង្គឲ្យមនុស្សលោកស្គាល់ (អក ១, ៩) (DV ២) ... ហេតុនេះ អ្នកដែលឃើញព្រះគ្រីស្ត ក៏ឃើញព្រះបិតាដែរ (យហ ១៤, ៩)។ ពេលព្រះយេស៊ូរស់នៅជាមួយមនុស្សលោក ទ្រង់បង្ហាញព្រះអង្គផ្ទាល់ តាមព្រះបន្ទូល និងតាមកិច្ចការ តាមទីសម្គាល់ និងតាមការអស្ចារ្យ ហើយជាពិសេស ដោយទ្រង់សោយទិវង្គត ហើយក្រោកឡើងពីចំណោមមនុស្សស្លាប់ និងមានព្រះជន្មថ្មីដ៏រុងរឿង។ នៅទីបញ្ចប់ ទ្រង់ចាត់ព្រះវិញ្ញាណនៃសេចក្តីពិត។ ដោយព្រះគ្រីស្តប្រព្រឹត្តការទាំងនោះ ព្រះ*

---

[2] *ទស្សនវិទ្យា គឺជាការរិះគិតអំពីសំណួរខ្លះសំខាន់ៗដូចជា តើមនុស្សជានរណា? តើត្រូវធ្វើដូចម្តេច ដើម្បីបានជីវិតល្អប្រសើរ? ជាដើម ដោយសំអាងលើអំណះអំណាងចេញពីប្រាជ្ញាតែប៉ុណ្ណោះ។*

*អង្គបង្ហើយ និងបង្គ្រប់សេចក្តីដែលព្រះជាម្ចាស់បានសម្តែងអំពីព្រះអង្គផ្ទាល់ ព្រះគ្រីស្តក៏បញ្ជាក់ពីការសម្តែងព្រះជាម្ចាស់នេះដែរ។ ព្រះគ្រីស្តក្នុងឋានៈជាព្រះជាម្ចាស់បញ្ជាក់ទៀតថា ព្រះជាម្ចាស់ផ្ទាល់គង់នៅជាមួយយើងដើម្បីដកយើងឲ្យរួចផុតពីភាពងងឹតនៃអំពើបាប និងនៃសេចក្តីស្លាប់ ព្រមទាំងប្រោសឲ្យយើងក្រោកឡើង និងទទួលព្រះជន្មដែលស្ថិតនៅអស់កល្បជានិច្ច" (DV ៤)*។

សម្រាប់មហាសន្និបាតវ៉ាទីកង់ទី ២ សេចក្តីនៃជំនឿ គឺព្រះយេស៊ូគ្រីស្តផ្ទាល់ ឯលទ្ធិនៃសាសនាគ្រាន់តែជាការពន្យល់នៃការសម្តែងនេះតែប៉ុណ្ណោះ។ *"នៅជំនាន់ដើម ព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់បុព្វបុរសយើងជាច្រើនលើកច្រើនសា ដោយប្រើរបៀបផ្សេងៗជាច្រើនតាមរយៈពួកព្យាការី"* (ហប ១,១)។ តាមអត្ថបទនេះ ព្រះយេស៊ូគ្រីស្តឆ្លុះបញ្ចាំងព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់ (យហ ១,១៤) គឺព្រះជាម្ចាស់មិនប្រើព្រះបុត្រា ដូចជាឧបករណ៍ដើម្បីសម្តែងព្រះអង្គទេ ព្រះជាម្ចាស់ក៏សម្តែងព្រះអង្គនៅក្នុងអង្គព្រះបុត្រា។ ព្រះជាម្ចាស់ផ្ទាល់ស្ថិតនៅក្នុងអង្គព្រះគ្រីស្ត។ ព្រះបុត្រាជាព្រះបន្ទូលតែមួយនៃព្រះជាម្ចាស់ ព្រះអង្គជាការសម្តែងតែម្តង។

ដូច្នេះហើយ បានជាត្រូវបង្រៀនអំពីព្រះយេស៊ូគ្រីស្ត នាំអ្នកស្វែងរក និងគ្រីស្តបរិស័ទឲ្យគេជួប ស្គាល់ និងស្រឡាញ់ព្រះយេស៊ូគ្រីស្តច្រើនជាងបង្រៀនលទ្ធិនៃសាសនា។ ព្រះគ្រីស្តជាឫសគល់នៃជំនឿ សេចក្តីឯទៀតៗនៃជំនឿគ្រាន់តែជាប់នឹងព្រះអង្គ។

### ៤) Fides qua

ជាភាសាឡាតាំង Fides qua មានន័យថា *"អំពើរបស់អ្នកជឿ"*។

តើនៅក្នុងជម្រៅចិត្តមនុស្សមានអ្វីខ្លះ បានជាមនុស្សអាចជឿបាន?

សម្រាប់សន្តៈអូគូស្ទីន ជំនឿមិនមែនជាកិច្ចការរបស់មនុស្សទេ ពីព្រោះជំនឿមកពីព្រះជាម្ចាស់ ជាព្រះអំណោយទានរបស់ព្រះអង្គ៖ *"សិលាអើយ! អ្នកដឹងសេចក្តីនេះមិនមែនដោយខ្លួនឯងទេ គឺព្រះបិតារបស់ខ្ញុំដែលគង់នៅស្ថានបរមសុខ*បានសម្តែងឲ្យអ្នកដឹង"* (មថ ១៦,១៦)។ យើងជឿមកពីព្រះជាម្ចាស់មិនមែនមកពីកម្លាំងខ្លួនឯងឡើយ។

ប៉ុន្តែតាមការពិតទៅ ជំនឿជាកិច្ចការរបស់មនុស្សផងដែរ គឺមនុស្សត្រូវតែស្តាប់ព្រះសូរសៀងរបស់ព្រះជាម្ចាស់ និងស្តាប់បង្គាប់ព្រះអង្គ (រម ១,៥ ; ១៦,២៦)។ មនុស្សមិនស្តាប់បង្គាប់ព្រះជាម្ចាស់ ដោយសារព្រះអង្គមានអំណាចទេ មនុស្សស្តាប់បង្គាប់ព្រះអង្គ ព្រោះមនុស្សបើកចិត្តឲ្យសេចក្តីពិតវិញ។ ការស្តាប់បង្គាប់នេះជាការស្តាប់៖ *"ព្រះអម្ចាស់មិនចង់បានយញ្ញបូជា...តែព្រះអង្គបើកត្រចៀក ទូលបង្គំឲ្យចេះស្តាប់ព្រះអង្គ"* (ទន ៤០,៧)។ ផ្ទុយពីលោកអដាំព្រះយេស៊ូបានស្តាប់បង្គាប់ព្រះជាម្ចាស់ (ហប ១០,៥; រម៥,១៩)។ អ្នកជឿចាប់ផ្តើមស្តាប់៖ *"អ៊ីស្រាអែលអើយ! ចូរស្តាប់!"* (ទក ៦,៤)។

ម្យ៉ាងទៀត អ្នកស្តាប់អាចជឿបាន ព្រោះតែមនុស្សជា *"រូបតំណាង"* របស់ព្រះជាម្ចាស់។ សន្តៈអូគូស្ទីនមានប្រសាសន៍ថា៖ មនុស្ស capax Dei គឺមនុស្សអាចជួប និងស្គាល់ព្រះអង្គ ព្រោះគេចូលរួមចំណែកក្នុងលក្ខណៈសម្បត្តិរបស់ព្រះអង្គ។ លោកបន្ថែមទៀតថា៖ *"ព្រះអម្ចាស់បានបង្កើតមនុស្សលោកសម្រាប់ព្រះអង្គ ហើយ*

*យើងមិនអស់ចិត្តទាល់តែយើងនៅក្នុងអង្គព្រះអង្គ*”។ បើមនុស្សពុំមានលក្ខណៈរបស់ព្រះជាម្ចាស់ទេ គេមិនអាចស្តាប់ ជួប និងស្គាល់ព្រះអង្គបានឡើយ។ គ្រីស្តបរិស័ទអាចជឿបាន ព្រោះគេជាអ្នកស្វែងរកអត្ថន័យនៃជីវិតដែលព្រះជាម្ចាស់សម្តែងឲ្យគាត់ស្គាល់។ ខ្ញុំជឿព្រោះខ្ញុំយល់ថា ការសម្តែងទាក់ទងនឹងជីវិតរបស់ខ្ញុំ។ មនុស្សនិងព្រះជាម្ចាស់ជាប់ពាក់ព័ន្ធនឹងគ្នា។

ដូច្នេះហើយ បានជាទេវវិទូមិនគ្រាន់តែត្រូវស្វែងយល់អំពីព្រះជាម្ចាស់ទេ ថែមទាំងត្រូវស្វែងយល់អំពីលក្ខណៈផ្សេងៗពីគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ដូចជាវប្បធម៌ សាសនា ប្រវត្តិសាស្ត្រជាដើម ដើម្បីប្រកាសដំណឹងល្អ និងពន្យល់ជំនឿឲ្យគេ[3]។ ទេវវិទូត្រូវតែសិក្សាអំពីព្រះជាម្ចាស់ផង អំពីមនុស្សផងដែរ ព្រោះនៅពេលដែលមនុស្សស្គាល់ព្រះជាម្ចាស់ គឺគេស្គាល់ខ្លួនឯងផងដែរ។ ដើម្បីទៅជាទេវវិទូមួយរូបយ៉ាងពិតប្រាកដ ត្រូវតែសិក្សាអំពីព្រះជាម្ចាស់ផង សិក្សាអំពីមនុស្សផង និងហ៊ានប្រឈមមុខអស់អ្នកដែលប្រឆាំង ឬមិនរវល់នឹងជំនឿ។ ទេវវិទូជា *“មនុស្សម្នាក់ ដែលឆ្លើយតប”* នឹងសំណួររបស់ខ្លួនឯងផង របស់អ្នកដទៃផងដែរ។ ទេវវិទូជាអ្នកបម្រើនៃជំនឿសម្រាប់អ្នកដទៃ។ ទោះបីសេចក្តីនៃជំនឿ មិនដែលប្រែប្រួលយ៉ាងណាក៏ដោយ ក៏ពិភពលោក និងចិត្តមនុស្សតែងតែផ្លាស់ប្តូរជានិច្ច។ បើគាត់ចង់ឲ្យអ្នកដទៃស្តាប់គាត់ ទេវវិទូត្រូវតែសម្របតាមលក្ខណៈរបស់អ្នកដទៃ (វប្បធម៌...)។

### *សេចក្តីបញ្ចប់៖ ទេវវិទ្យាមិនអាចថ្លែងបាន (apophatic)*

ទេវវិទូជាអ្នកជឿ ដែលស្វែងយល់អំពីជំនឿរបស់ខ្លួនឯង គឺគាត់សុខចិត្តឲ្យអ្នកដទៃ (ដែលមានវប្បធម៌ សាសនា លក្ខណៈប្លែកពីគាត់) រិះគន់អំពីជំនឿនេះ ដើម្បីឲ្យគាត់រីកចម្រើនក្នុងជំនឿ។ ទេវវិទូតែងតែចង់ស្វែងយល់អំពីជំនឿ និងរីកចម្រើនក្នុងការស្គាល់ព្រះជាម្ចាស់ ប៉ុន្តែគាត់ដឹងច្បាស់ថា គាត់មិនអាចយល់អំពីព្រះជាម្ចាស់ទាំងស្រុងបានឡើយ។ ទោះបីព្រះជាម្ចាស់ប្រសូតជាមនុស្ស ដើម្បីសម្តែងព្រះអង្គឲ្យមនុស្សស្គាល់យ៉ាងណាក៏ដោយក៏ទេវវិទូយល់កាន់តែច្បាស់ថា ព្រះជាម្ចាស់ជាអាថ៌កំបាំងដ៏អស្ចារ្យ ដែលមិនអាចយល់ទាំងស្រុងបានឡើយ។

### *តាមមលទ្ធិគ្រីស្តសាសនា៖*

“៤០ ដោយសារយើងមិនអាចស្គាល់ព្រះជាម្ចាស់ទាំងស្រុងបានទេ ពាក្យសម្តីរបស់យើងអំពីព្រះជាម្ចាស់ក៏មានព្រំដែនដែរ។ ដូច្នេះ យើងអាចនិយាយអំពីព្រះជាម្ចាស់តាមរយៈសត្វលោក និងតាមការយល់ដឹង និងការគិតពិចារណារបស់យើងតែប៉ុណ្ណោះ។

៤១ សត្វលោកទាំងឡាយមានលក្ខណៈម្យ៉ាងដូចព្រះជាម្ចាស់ ជាពិសេសមនុស្សដែលជាតំណាង និងមានលក្ខណៈដូចព្រះអង្គ។ លក្ខណៈផ្សេងៗនិងល្អៗនៃសត្វលោក (សេចក្តីពិត សប្បុរសធម៌ និងសោភណភាព) ឆ្លុះបញ្ចាំងអំពីលក្ខណៈដ៏ល្អឥតខ្ចោះឥតព្រំដែនរបស់ព្រះជាម្ចាស់។ ដូច្នេះហើយ បានជាយើងអាចនិយាយអំពីព្រះជាម្ចាស់ តាមលក្ខណៈល្អៗនៃសត្វលោក ដ្បិត *“ភាពថ្កុំថ្កើង និងសម្រស់របស់សត្វលោកនាំមនុស្សសញ្ជឹងគិត ដោយការប្រៀបធៀបអំពីព្រះអង្គដែលបានបង្កើតសត្វលោកទាំងអស់”* (ប្រាញ

---

[3] *គំនិតនេះ ផ្ទុយពីគំនិតរបស់លោកកាល បារថ៍ (Karl Barth) ដែលជាទេវវិទូតប្រូតេស្តង់*

១៣,៥)។

**៤២** ព្រះជាម្ចាស់ខុសប្លែក និងហួសពីសត្វលោកទាំងអស់។ ដូច្នេះ ត្រូវតែបន្សុទ្ធពាក្យសម្ដីរបស់យើង ដែលមានព្រំដែន ដែលប្រើនិមិត្តរូប និងដែលមិនគ្រប់លក្ខណៈ កុំឲ្យយើងច្រឡំនឹងព្រះដ៏វិសុទ្ធបំផុត *"ដែលយើងមិនអាចយល់ដែលយើងមិនអាចមើលឃើញ ហើយដែលយើងមិនអាចគ្រប់គ្រងបានឡើយ"* (សន្តៈយ៉ូហានគ្រីសូស្តូម) ជាមួយនឹងការយល់ដឹងរបស់យើង។ ពាក្យសម្ដីយើងតែងតែស្ថិតនៅក្រោមអាថ៌កំបាំងរបស់ព្រះជាម្ចាស់។

**៤៣** ទោះបីពាក្យសម្ដីយើងមានព្រំដែនក្ដី ក៏យើងអាចនិយាយអំពីព្រះជាម្ចាស់ម្យ៉ាងដែរ។ យើងអាចប្រៀបធៀបសត្វលោកនឹងព្រះជាម្ចាស់មែន តែត្រូវរំលឹកថា ព្រះជាម្ចាស់មានលក្ខណៈខុសពីសត្វលោកឆ្ងាយណាស់ *(ឡាត្រង់ទី ៤)* ហើយយើងមិនអាចយល់អំពីព្រះជាម្ចាស់ទាំងស្រុងនោះបានទេ (សន្តៈថូម៉ាសអាគីណាស)។"

## សំណួរ៖

១) អ្វីទៅជាទេវវិទ្យា?
២) តើទេវវិទ្យា និងទស្សនវិទ្យាមានទំនាក់ទំនងយ៉ាងដូចម្ដេច? សូមពន្យល់។
៣) អ្វីទៅជាការសម្ដែង (មុន និងក្រោយមហាសន្និបាតវ៉ាទីកង់ទី ២)?
៤) តើ Fides quae / Fides qua ខុសគ្នាត្រង់ចំណុចណាខ្លះ?
៥) ហេតុអ្វីត្រូវរៀនអំពីទេវវិទ្យានៅស្រុកខ្មែរសព្វថ្ងៃ?

# ជំពូកទី ២
# ប្រវត្តិសាស្ត្រនៃទេវវិទ្យា

****

## ១) អត្ថន័យដើមនៃទេវវិទ្យា

សាសនានីមួយៗមានទេវវិទ្យា គឺជាការដោះសារជំនឿរបស់គេសម្រាប់ខ្លួនឯង និងសម្រាប់អ្នកដទៃផង។ អត្ថន័យដើមនៃពាក្យ *"ទេវវិទ្យា"* មកពីទស្សនវិទ្យាក្រិក។ ពាក្យ *"ទេវវិទ្យា"* មានអត្ថន័យបី គឺ៖

១.១) លទ្ធិនៃទេវកថា៖ សម្រាប់លោកប្លាតុង (Platon) ទេវវិទ្យាពុំមានប្រយោជន៍ ព្រោះជារឿងប្រឌិតអំពីព្រះផ្សេងៗ ដែលមិនទាក់ទងនឹងជីវិតមនុស្សលោក។

១.២) ទេវវិទ្យានៃសង្គម និងនយោបាយ៖ គឺពិធីផ្សេងៗនៅក្នុងសង្គមដែលត្រូវតែធ្វើ ដើម្បីការពារប្រទេសជាតិ។

១.៣) ទេវវិទ្យាធម្មជាតិ ឬទេវវិទ្យានៃទស្សនវិទ្យា៖ សម្រាប់លោកអារីស្តូត (Aristote) គឺជាការសិក្សាអំពីសភាវៈដើមដំបូង។

ជាដំបូង គ្រីស្តបរិស័ទមិនសូវចង់ប្រើពាក្យ *"ទេវវិទ្យា"* ព្រោះតាមអត្ថន័យទីមួយ ទេវវិទ្យាសំដៅទៅលើរឿងក្លែងក្លាយតាមអត្ថន័យទីពីរ ទេវវិទ្យាជាប់នឹងប្រពៃណី និងទំនៀមទម្លាប់ជានិច្ច ហើយប្រាជ្ញាមនុស្សអាចពន្យល់អំពីទេវវិទ្យាតាមអត្ថន័យទីបី *(សម្រាប់គ្រីស្តបរិស័ទ ជំនឿសំខាន់ជាងប្រាជ្ញា)*។

## ២) នៅសម័យសង្គមគ្រីស្តបរិស័ទ

នៅសតវត្សទី ១១ ទេវវិទ្យារីកចម្រើន គឺលោកអាបេលារ (Abelard) ផ្តល់អត្ថន័យថ្មីដល់ពាក្យ *"ទេវវិទ្យា"* គឺលោកចាប់ផ្តើមពន្យល់ព្រះគម្ពីរ ដោយប្រើប្រាជ្ញា គឺដោយបញ្ចេញអំណះអំណាង ដែលមានហេតុផលច្បាស់លាស់។ ពីមុនគេធ្លាប់ពន្យល់ព្រះគម្ពីរ ដោយអាងលើយោបល់ និងអំណាចរបស់បុព្វបុរសនៃព្រះសហគមន៍ *(ដូចជាសន្តៈអូគូស្ទីនជាដើម)*។

### *ទេវវិទ្យាបម្រើអ្នកជឿ បានសេចក្តីថា៖*

២.១) Fides ex auditu *(រម ១០,១៤.១៧)*៖ យើងជឿមកពីយើងស្តាប់ គឺត្រូវតែទទួលសេចក្តីនៃជំនឿ ទុកជាមុនសិន។ យើងមិនអាចធ្វើទេវវិទ្យាបានឡើយ បើយើងចេញពីវិស័យនៃជំនឿ។

២.២) តាមលោក កាលបារថ៍ ទេវវិទូរិះគិតអំពីខ្លួនឯង គឺអំពីព្រះសហគមន៍ ដែលត្រូវទទួលការរិះគន់នេះ បានសេចក្តីថា ព្រះសហគមន៍ត្រូវសុខចិត្តចុះក្រោមអំណាចនៃទេវវិទ្យា។

២.៣) តាមសន្តថូម៉ាសអាគីណាស ទេវវិទ្យាជា *"វិទ្យាសាស្ត្រ"* (ទេវវិទ្យាជាលទ្ធិដ៏វិសុទ្ធ) ដែលចុះក្រោមអំណាច (scientia subalternata) នៃការសម្តែង។ ទេវវិទូចូលរួមចំណែកក្នុងចំណេះដឹងរបស់ព្រះជាម្ចាស់ផ្ទាល់ ដែលទ្រង់ចែកឲ្យមនុស្សលោកស្គាល់។ ទេវវិទូទទួលអ្វីដែលព្រះជាម្ចាស់ប្រោសប្រទាន បានសេចក្តីថា theos *(ព្រះ)* គ្រប់គ្រងលើ logos (ការរិះគិតពិចារណាលើព្រះ)។

## ៣) មុខងាររបស់ទេវវិទូ

ទេវវិទូមានមុខងារបីមកពីការផ្លាស់ប្តូរ ដែលកើតឡើងក្នុងប្រវត្តិសាស្ត្រ៖

៣.១) **ការសិក្សាអំពីព្រះគម្ពីរ (exegesis)**៖ ទេវវិទូទទួលសេចក្តីនៃជំនឿ ដែលមានក្នុងព្រះគម្ពីរ ហើយដែលសាក្សីជាច្រើនបានបញ្ជូលមក។ ដោយសារព្រះជាម្ចាស់ប្រសូតក្នុងប្រវត្តិសាស្ត្រមនុស្ស ទេវវិទូត្រូវតែសិក្សាអំពីប្រភពនៃព្រះគម្ពីរ គឺតើអត្ថបទទាំងអស់នោះ ពិតជាចាក់ឫសក្នុងប្រវត្តិសាស្ត្រមនុស្សឬទេ? នៅទីនេះ ទេវវិទូចង់ *"យល់"* អំពីជំនឿ (subtilitas intelligendi)។

៣.២) **ការសិក្សាអំពីគោលការណ៍ និងលទ្ធិនៃជំនឿ (systematic or dogmatic)**៖ ទេវវិទូប្រៀបដូចជាគ្រូគណិតវិទ្យា គឺគាត់ស្វែងរកហេតុផលនៃជំនឿត្រឹមត្រូវតាមប្រាជ្ញា។ ត្រូវតែគោរពអ្វីដែលព្រះសហគមន៍បានបញ្ជូនបន្ត ម្យ៉ាងទៀតត្រូវតែពន្យល់អត្ថន័យថ្មីសម្រាប់សព្វថ្ងៃផងដែរ *(ឧ. ព្រះគ្រីស្តសោយទិវង្គត... សម្រាប់យើង)*។ នៅទីនេះ ទេវវិទូចង់ *"ពន្យល់"* (subtilitas explicandi)។

៣.៣) **ទេវវិទ្យាមូលដ្ឋាន**៖ ទេវវិទូត្រូវតែពន្យល់ជំនឿដល់អ្នកដទៃ គឺប្រកាសដំណឹងល្អ។ មានការអប់រំជំនឿការនិយាយសន្ទនាជាមួយអ្នកឥតសាសនា ឬជាមួយអ្នកកាន់សាសនាដទៃ ត្រូវតែរិះគិតអំពីរបៀបប្រកាសដំណឹងល្អក្នុងវប្បធម៌មួយ។ល។ នៅទីនេះ ទេវវិទូចង់ *"អនុវត្ត"* (subtilitas applicandi)។

## ៤) ការផ្លាស់ប្តូរនៃទេវវិទ្យាមូលដ្ឋាន

ទេវវិទ្យាបានផ្លាស់ប្តូរជាច្រើនលើកច្រើនសាតាមប្រវត្តិសាស្ត្រ។

***៤.១) Apologetic***៖ ពាក្យនេះ ដែលមកពី ១ស ៣,១៥ មានន័យថា *"ការពារ"* *"ដោះសារ"* ជំនឿ។ សៀវភៅដើមនៃទេវវិទ្យាភាគច្រើនមានចំណងជើងថា *"ប្រឆាំង"* គឺគ្រីស្តបរិស័ទដើមត្រូវការពារជំនឿប្រឆាំងនឹងខ្មាំងសត្រូវផ្សេងៗជាច្រើន ដូចជាសាសន៍ដទៃ ទស្សនវិទូជនជាតិយូដាជាដើម។ សៀវភៅទាំងអស់នោះ ដូចជាសុន្ទរកថា របស់មេធាវីដែលមានបំណងចង់ឈ្នះការកាត់ក្តី។

ឧ. នៅឆ្នាំ១៣៤ ក្នុង *"ការនិយាយសន្ទនាជាមួយលោកទ្រីផង់"* (Tryphon) សន្តៈយ៉ូស្តាំង (Justin) ចង់បង្ហាញចំពោះព្រះចៅអធិរាជរ៉ូម៉ាំងអង់តូនីន (Antonin) ថា ជំនឿរបស់គ្រីស្តបរិស័ទជា *"ទស្សនវិទ្យាតែមួយច្បាស់លាស់ ដែលមានប្រយោជន៍"*។ លោកព្យាយាមឲ្យជនជាតិយូដា (លោកទ្រីផង់តំណាងជនជាតិយូដា) កែប្រែចិត្តគំនិតផ្ញើជីវិតលើព្រះគ្រីស្ត។ លោកសូមឲ្យព្រះចៅអធិរាជឈប់បៀតបៀនគ្រីស្តបរិស័ទផងដែរ។

នៅសម័យនោះ លោកទែរទូលីយ៉ាំង (Tertullian ឆ្នាំ២០០) ល្បីល្បាញជាងគេ សរសេរសៀវភៅជាច្រើនដើម្បីការពារជំនឿប្រឆាំងនឹងសាសន៍ដទៃ ជាពិសេសលោកបង្ហាញថា ការបៀតបៀនគ្រីស្តបរិស័ទអយុត្តិធម៌

ហើយលោកទាមទារឲ្យមានសេរីភាពនៃសាសនា។

ទេវវិទ្យាបែបនេះគ្រោះថ្នាក់ ពីព្រោះយូរៗទៅយើងចង់ឈ្នះខ្លាំងសត្រូវជាជាងបង្ហាញអំពីហេតុផល និងសោភណភាពនៃជំនឿ។ យើងចង់ការពារខ្លួនជាជាងប្រកាសដំណឹងល្អ។ ទីបញ្ចប់ធ្វើឲ្យទេវវិទ្យាបែបនេះបង្ហាញថា ជំនឿយើងទន់ខ្សោយយើងខ្លាចអ្នកដទៃ។

### *៤.២) ការបញ្ចេញហេតុផលនៃជំនឿ*

យូរៗទៅ ទេវវិទ្យាទទួលអត្ថន័យវិជ្ជមាន គឺទេវវិទូចាប់ផ្តើមពន្យល់អំពីហេតុផល និងសេចក្តីពិតនៃជំនឿ។

ទេវវិទូចង់បង្ហាញថា ជំនឿស្របនឹងប្រាជ្ញា ដែលជាកត្តារួមរបស់មនុស្សទាំងអស់។ សន្តះអង់សេលម៍មានគោលដៅបង្ហាញថា ការប្រមាថមើលងាយជំនឿយើង គ្មានឫសគល់ត្រឹមត្រូវតាមប្រាជ្ញាទាល់តែសោះ។ របៀបប្រសើរជាងគេ ដើម្បីការពារជំនឿ គឺបង្ហាញហេតុផលនៃជំនឿឲ្យគេយល់ថា ជំនឿស្របតាមប្រាជ្ញា។ ទេវវិទូនោះត្រូវមានចិត្តទូលាយ និងចេះស្តាប់ការរិះគន់របស់អ្នកដទៃ ដោយចេះដាក់ខ្លួនហ៊ានប្រឈមមុខនឹងការពិត ហើយត្រូវតែចេះកែប្រែចិត្តគំនិតផងដែរ។

### *៤.៣) ទេវវិទ្យាមូលដ្ឋានៈ ការនិយាយសន្ទនា*

ជាមួយទេវវិទ្យាមូលដ្ឋាន ទេវវិទូបោះជំហ៊ានមួយទៅមុខទៀត គឺគេមិនប្រឆាំង ឬបញ្ចេញអំណះអំណាងទេ ប៉ុន្តែគេនិយាយសន្ទនាជាមួយអ្នកដទៃ ដូចជាអ្នកកាន់សាសនាដទៃ អស់អ្នកដែលពុំមានសាសនា មិនជឿលើព្រះជាម្ចាស់ អស់អ្នកដែលមិនរវីរវល់នឹងគ្រីស្តសាសនាជាដើម។

ទេវវិទូត្រូវតែស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ផង សេចក្តីរង់ចាំ តម្រូវការ និងសេចក្តីសង្ឃឹមរបស់មនុស្សផងដែរ គឺគេត្រូវតែរួមសាមគ្គីជាមួយមនុស្ស ជាពិសេសអស់អ្នកដែលរងទុក្ខលំបាក។ យើងនិយាយអំពី *"ទេវវិទ្យាតាមកាលៈទេសៈ"*៖ a/b = x/y (a = ហេតុការណ៍ពីអតីតកាល b = កាលៈទេសៈពីអតីតកាល x = ហេតុការណ៍បច្ចុប្បន្នកាល y = កាលៈទេសៈបច្ចុប្បន្នកាល)។

ឧ. ការចាកចេញពីស្រុកអេស៊ីប និងការឆ្លងសមុទ្រក្រហម (a) មានអត្ថន័យសម្រាប់ជនជាតិយូដា ក្នុងប្រវត្តិសាស្ត្ររបស់ពួកគេ (b)។ ក្នុងកាលៈទេសៈរបស់យើង (y) យើងត្រូវពន្យល់អំពីហេតុការណ៍នោះ (x) សម្រាប់មនុស្សសព្វថ្ងៃ គឺព្រះយេស៊ូជាលោកម៉ូសេថ្មី ដែលនាំឲ្យយើងឆ្លងពីសេចក្តីស្លាប់ទៅជីវិតអស់កល្បជានិច្ច។

## ៥) ការប្រឈមមុខនៃទេវវិទ្យា

ជំនឿមិនដែលប្រែប្រួលឡើយ ប៉ុន្តែកាលៈទេសៈផ្លាស់ប្តូរជានិច្ច។ ទេវវិទូតែងតែត្រូវសម្របទេវវិទ្យាតាមវប្បធម៌របស់មនុស្ស ដើម្បីឲ្យគេអាចស្តាប់ដំណឹងល្អ។ តាមប្រវត្តិសាស្ត្រទេវវិទ្យាបានប្រឈមមុខនឹងការផ្លាស់ប្តូរប្រាំពីរដង៖

## *៩.១) "ស្របតាមគម្ពីរ"៖ ជនជាតិយូដា*

ជាដំបូង ព្រះសហគមន៍ដើមដំបូងចង់ដោះសារជំនឿសម្រាប់ជនជាតិយូដា។ នៅឆ្នាំ ៧០ សន្តៈប៉ូលចង់បង្ហាញថា ព្រះគ្រីស្តយាងមក "*ស្របតាមគម្ពីរ*" (នេះដែរ (មថ ២១,៤២ ; ២២,២៩ ; ២៦,៥៦)។ ទេវវិទូគ្រីស្តបរិស័ទព្យាយាមបង្ហាញថា សម្ព័ន្ធមេត្រីថ្មីបំពេញសម្ព័ន្ធមេត្រីចាស់ ព្រះយេស៊ូបង្ហើយសម្ព័ន្ធមេត្រី ដែលព្រះជាម្ចាស់បានចាប់ផ្តើមជាមួយលោកម៉ូសេ។

ទេវវិទ្យានេះ សំខាន់ណាស់ ប៉ុន្តែមានផលប្រយោជន៍សម្រាប់អ្នកជឿតែប៉ុណ្ណោះ៖ នៅឆ្នាំ ៨៥-១៦០ លោកម៉ារស៊ីអង់ (Marcion) ចង់លុបសម្ព័ន្ធមេត្រីចាស់ចោល ព្រោះគាត់និយាយថា ក្នុងសម្ព័ន្ធមេត្រីចាស់ ព្រះជាម្ចាស់ឆាប់ខ្ញាល់ និងសាហាវ ឯក្នុងសម្ព័ន្ធមេត្រីថ្មីវិញ ព្រះយេស៊ូបង្ហាញថា ព្រះជាម្ចាស់ពោរពេញដោយធម៌មេត្តាករុណា។ សន្តៈអ៊ីរ៉េណេ (Irenee) ស្តីបន្ទោសគាត់ថា គាត់មិនស្គាល់ព្រះគម្ពីរច្បាស់លាស់ (ក្នុងសម្ព័ន្ធមេត្រីចាស់ ព្រះជាម្ចាស់ ពោរពេញដោយធម៌មេត្តាករុណាដែរ (ហស ២,១៦-២២) ឯមានពេលខ្លះ ក្នុងសម្ព័ន្ធមេត្រីថ្មី ព្រះជាម្ចាស់ខ្ញាល់ដែរ (មថ ១៨,២១-១៩,១) ឯលោកទែរទូលីយ៉ាំងវិញ លោកបង្ហាញថា សម្ព័ន្ធមេត្រីចាស់ និងសម្ព័ន្ធមេត្រីថ្មីរួមជាមួយគ្នាជាធ្លុងតែមួយដូចព្រះជាម្ចាស់មានតែមួយដែរ។

គ្រីស្តបរិស័ទបានដេញលោកម៉ារស៊ីអង់ឲ្យចេញពីព្រះសហគមន៍ ប៉ុន្តែជនជាតិយូដាមិនបានចាញ់ទេវវិទ្យាបែបនេះ។ លើសពីនេះទៅទៀត យើងអាចបង្ហាញថា ព្រះយេស៊ូមិនបំពេញសម្ព័ន្ធមេត្រីចាស់ឡើយ។ តាមការពិតត្រូវតែជឿថា ព្រះយេស៊ូជាព្រះគ្រីស្តសិន ដើម្បីបកស្រាយសម្ព័ន្ធមេត្រីចាស់ស្របតាមគ្រីស្តសាសនា គឺដោយយល់ថា សម្ព័ន្ធមេត្រីចាស់ប្រកាសព្រះអង្គទុកជាមុន។ ប្រសិនបើយើងមិនជឿសិន យើងមិនអាចយល់ថា សម្ព័ន្ធមេត្រីចាស់ ដូចជា "*បាំង*" សម្ព័ន្ធមេត្រីថ្មី[4]។

## *៩.២) ប្រកាសដំណឹងល្អសម្រាប់សាសន៍ដទៃ*

សាសន៍ដទៃមិនស្គាល់ព្រះគម្ពីរ ដូច្នេះហើយ បានជាគ្រូបាធ្យាយព្រះសហគមន៍ចង់បង្ហាញឲ្យពួកគេយល់ថា គ្រីស្តបរិស័ទជាសាក្សីពិតប្រាកដ ដែលអាចជឿទុកចិត្តបាន (រម ១០,១៤)។ ហេតុការណ៍នៃជំនឿអាងលើអស់អ្នក ដែល "*បានឃើញ និងបានស្តាប់*"។ ព្រះគ្រីស្តបានជ្រើសរើសសាវ័ក (កក ១,៨) ឲ្យទៅជាសាក្សី (កក ២,៣២; ២២,១៥) នៃសេចក្តីពិត។

តើយើងអាចជឿទុកចិត្តសាក្សីទាំងអស់នោះបានឬទេ? នៅក្នុងសម្ព័ន្ធមេត្រីថ្មី ហើយមានគេមិនព្រមជឿក្រុមសាវ័ក ហើយចាត់ទុកព្រះយេស៊ូថាជាអ្នកកុហក (មថ ២៧,៦៣)។ លោកអូរីសែន (Origene) ជាពិសេសលោក អើសេប នៅសេសារ៉េ (Eusebe of Cesaree - ឆ្នាំ ៣៤០) សិក្សាអំពីប្រវត្តិសាស្ត្រដើម្បីឲ្យសាសន៍ដទៃយល់ថា ពួកគេអាចជឿទុកចិត្តគ្រីស្តបរិស័ទបាន។ ប៉ុន្តែ តើប្រវត្តិសាស្ត្រជាសេចក្តីពិតមែន? ព្រះយេស៊ូពិតជាបាន

---

4 *"គំនិតរបស់ជនជាតិអ៊ីស្រាអែល នៅងងឹតសូន្យ ដ្បិតរហូតមកទល់សព្វថ្ងៃ ពេលគេអានគម្ពីរសម្ព័ន្ធមេត្រីចាស់ ស្បៃដដែលនោះនៅបាំងគំនិតរបស់គេ។ ស្បៃនៅបាំងគេដដែល លុះដល់គេចូលរួមជាមួយព្រះគ្រីស្ត ទើបស្បៃនោះ រសាត់បាត់ទៅ។ មកទល់សព្វថ្ងៃនេះ ពេលគេអានគម្ពីររបស់លោកម៉ូសេមានស្បៃមួយនៅបាំងចិត្តគេមិនឲ្យយល់ ក៏ប៉ុន្តែ នៅពេលគេបែរចិត្តគំនិតរកព្រះអម្ចាស់ ស្បៃនោះចេញពីគេបាត់ទៅ" (២ករ ៣,១៣-១៦)។*

រស់នៅស្រុកអ៊ីស្រាអែលមែន ប៉ុន្តែយើងត្រូវតែមានជំនឿដើម្បីប្រកាសថា លោកយេស៊ូជាព្រះគ្រីស្ត។ ទេវវិទ្យាបែបនេះ គ្រាន់តែបង្ហាញថា យើងអាចជឿទុកចិត្តគ្រីស្តបរិស័ទប៉ុណ្ណោះ[5] ប៉ុន្តែមិនអាចយកចិត្តអ្នកដទៃឲ្យជឿបានឡើយ។

## ៩.៣) ទំនាក់ទំនងជាមួយទស្សនវិទ្យា

ក្នុងកិច្ចការគ្រីស្តទូត សន្តៈប៉ូលទៅប្រកាសដំណឹងល្អនៅក្រុងអាថែន (កក ១៧,១៦) ជជែកសន្ទនាជាមួយទស្សនវិទូក្រិក។ ដើម្បីប្រកាសដំណឹងល្អដល់សាសន៍ដទៃ គ្រីស្តបរិស័ទមិនអាចចាប់ផ្តើមនិយាយអំពី *"លោកម៉ូសេ និងពួកព្យាការី"* ឡើយ គឺគេត្រូវចាប់ផ្តើមពីការស្វែងរកព្រះជាម្ចាស់ ដែលមនុស្សទាំងអស់មាននៅក្នុងចិត្ត។

ហេតុដូច្នេះហើយ បានជាសន្តៈក្លេម៉ង់ នៅអាឡិចសង់ឌ្រី (Clement of Alexandria) មានប្រសាសន៍ថា ចំពោះជនជាតិក្រិកទស្សនវិទ្យា ដូចសម្ព័ន្ធមេត្រីចាស់ ចំពោះជនជាតិយូដាដែរ គឺទស្សនវិទ្យារៀបចំផ្លូវថ្វាយព្រះគ្រីស្តដែលទ្រង់បំពេញទស្សនវិទ្យានេះវិញ។

សន្តៈថូម៉ាសអាគីណាសជាគំរូបញ្ជាក់អំពីគំនិតនេះ។ នៅសតវត្សទី ១៣ លោកជាទេវវិទូដ៏អស្ចារ្យបង្ហាញថា ជំនឿស្របតាមប្រាជ្ញា និងបំពេញចិត្តគំនិតរបស់មនុស្ស។ មហាសន្និបាតវ៉ាទីកង់ទី ១ ប្រកាសថា៖ *"ទោះបីជំនឿលើប្រាជ្ញាយ៉ាងណាក៏ដោយ ក៏ជំនឿមិនអាចប្រឆាំងនឹងប្រាជ្ញាដែរ"* ព្រោះមានព្រះជាម្ចាស់តែមួយ ដែលបានបង្កើតប្រាជ្ញាមនុស្ស ហើយដែលបានសម្តែងអាថ៌កំបាំងនៃជំនឿ។ ទំនាក់ទំនងរវាងជំនឿ និងប្រាជ្ញាមានបីដំណាក់កាល ៖

- ប្រាជ្ញាជា preparatio evangelica គឺប្រាជ្ញារៀបចំផ្លូវថ្វាយជំនឿ។
- ទោះបីជាសេចក្តីនៃជំនឿលើសប្រាជ្ញាក៏ដោយ ក៏សេចក្តីទាំងអស់នោះ មិនប្រឆាំងនឹងប្រាជ្ញាដែរ។ លើសពីនេះទៅទៀត សេចក្តីនៃជំនឿបំពេញប្រាជ្ញាដែលរង់ចាំសេចក្តីនោះដែរ។
- ជំនឿបានបង្កើតផលប្រយោជន៍ជាច្រើន សម្រាប់មនុស្សលោកគ្រប់វិស័យ ដែលជាហេតុផលមួយទៀតបង្ហាញថា ប្រាជ្ញាមនុស្សអាចជឿទុកចិត្តអ្នកជឿបាន។

ជំនឿ និងប្រាជ្ញាដូចជា "ស្លាបពីរ ដែលនាំវិញ្ញាណមនុស្សឲ្យឡើងឆ្ពោះទៅសេចក្តីពិត" (Fides et ratio – យ៉ូហានប៉ូលទី ២ (John Paul II)) ។

## ៩.៤) ព្រះសហគមន៍ណាពិតប្រាកដ?

តាំងពីសតវត្សទី ១៦ គ្រីស្តបរិស័ទបានប្រឈមមុខនឹងឧបសគ្គមួយទៀត គឺតើព្រះសហគមន៍ពិតប្រាកដស្ថិតនៅឯណា? ក្រុមប្រូតេស្តង់ប្រឆាំងនឹងអំណាចព្រះសហគមន៍ ពួកគេមិនព្រមថា ព្រះសហគមន៍ជាព្រះសហគមន៍តែមួយពិតប្រាកដរបស់ព្រះយេស៊ូគ្រីស្ត និងជាព្រះសហគមន៍តែមួយប្រកបដោយមធ្យោបាយនៃការសង្គ្រោះ។ ព្រះសហគមន៍កាតូលិកតែងតែព្យាយាមបង្ហាញភស្តុតាងថា ជាព្រះសហគមន៍ពិតប្រាកដ ដែលកាន់ជំនឿពិត

---

*5 ដែលមានច្រើននាក់សុខចិត្តស្លាប់ដោយសារជំនឿ។*

ប្រាកដផងដែរ។ ព្រះសហគមន៍អាងលើអំណះអំណាងពីរគឺ៖ ព្រះគម្ពីរបញ្ជាក់ថា ព្រះសហគមន៍កាតូលិកមានប្រភពចេញមកពីព្រះជាម្ចាស់ (ក្រុមប្រូតេស្តង់ទទួលស្គាល់ព្រះគម្ពីរតែប៉ុណ្ណោះ) ហើយស្របតាមប្រវត្តិសាស្ត្រព្រះសហគមន៍សព្វថ្ងៃចេញមកពីព្រះសហគមន៍ដើមដំបូង ដែលមានក្រុមគ្រីស្តទូតជាគ្រឹះ។

***តាមការពិតបញ្ហានេះ លើកសំណួរសំខាន់ៗបី ៖***

- តើព្រះសហគមន៍មកពីព្រះជាម្ចាស់ឬទេ? ព្រះសហគមន៍កាតូលិកអាងលើអត្ថបទដំណឹងល្អ មថ ១៦,១៣- ២០ ; លក ២២,៣១-៣២ ; យហ ២១,១៥-១៧។ ប៉ុន្តែសម្រាប់ក្រុមប្រូតេស្តង់ សំណួរនេះមិនសូវសំខាន់ទេ ព្រោះគេធ្លាប់អះអាងថា ព្រះសហគមន៍ពិតប្រាកដ គឺជាសហគមន៍របស់អស់អ្នកដែលប្រកាសថាព្រះគ្រីស្តយេស៊ូជាឫសគល់នៃជីវិតរបស់គេ (១ករ ៣,១១)។
- តើព្រះសហគមន៍ចេញមកពីក្រុមគ្រីស្តទូតឬទេ? ព្រះសហគមន៍កាតូលិកអះអាងថា ជំនឿរបស់ខ្លួនពិតប្រាកដ ព្រោះពួកលោកអភិបាលចេញមកពីក្រុមគ្រីស្តទូតតាំងពីដើមដំបូង។ សម្រាប់ក្រុមប្រូតេស្តង់វិញ ជំនឿពិតប្រាកដមកពីជំនឿនេះ ស្របតាមការប្រៀនប្រដៅរបស់ក្រុមគ្រីស្តទូត។
- តើព្រះសហគមន៍សព្វថ្ងៃមិនអាចភ័ន្តច្រឡំបានឬទេ? សម្រាប់ព្រះសហគមន៍កាតូលិក សម្តេចប៉ាប ដែលជាអ្នកបន្តមុខងាររបស់លោកសិលា មានព្រះវិញ្ញាណដ៏វិសុទ្ធមកជួយឧបត្ថម្ភ កុំឲ្យព្រះសហគមន៍វង្វេងក្នុងជំនឿ *(មហាសន្និបាតវ៉ាទីកង់ទី ១)*។ សម្រាប់ក្រុមប្រូតេស្តង់វិញ ការមិនអាចភ័ន្តច្រឡំមិនមែនមកពីអំណាចមេដឹកនាំទេ ប៉ុន្តែមកពីព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ សម្រាប់ព្រះសហគមន៍ទាំងមូល។

ទោះជាយ៉ាងណាក៏ដោយ ក៏មនុស្សស្តាប់បង្គាប់ព្រះសហគមន៍ មិនមែនមកពីព្រះសហគមន៍មានអំណាច ប៉ុន្តែមកពីព្រះសហគមន៍ជាសាក្សីនៃសេចក្តីពិត។

### ***៩.៥) ការសម្រេចចិត្តពឹងលើខ្លួនឯង (បុគ្គលនិយម)***

តាំងពីសម័យទំនើប មនុស្សមានមន្ទិលសង្ស័យលើអ្វីៗទាំងអស់ សូម្បីតែលើព្រះសហគមន៍ ឬលើព្រះជាម្ចាស់ដែរ។ មានតែ Cogito (ខ្ញុំគិត) របស់លោកដេការ៉ឺ (Descartes) ជាអ្នកវិនិច្ឆ័យអំពីសេចក្តីពិត គឺត្រូវតែហ៊ានគិតដោយខ្លួនឯង ដោយមិនពឹងផ្អែកលើអំណាចណាមួយទៀតទេ។ ដូច្នេះហើយ បានជាទេវវិទូលែងសរសេរសៀវភៅអំពីជំនឿពីព្រះជាម្ចាស់ ផ្ទុយទៅវិញគេពន្យល់ជំនឿដោយចាប់ផ្តើមជាមួយនឹងតម្រូវការរបស់មនុស្ស (*ដូចជាសេចក្តីស្រឡាញ់សេរីភាព សេចក្តីសុខសាន្តជាដើម*)។

ឧ. នៅសតវត្សទី ១៣ សន្តៈថូម៉ាសអាគីណាស ចាប់ផ្តើមពន្យល់គ្រីស្តសាសនាពីសេចក្តីពិតនៃព្រះត្រៃឯក (ពីព្រោះចំពោះមនុស្សនៅសម័យនោះ ព្រះជាម្ចាស់ជាអ្នកធានាសេចក្តីពិត) ឯនៅសតវត្សទី ២០ លោក កាល រ៉ានើរ (Karl Rahner) ចាប់ផ្តើមពន្យល់ជំនឿពីសេចក្តីរង់ចាំ និងតម្រូវការរបស់មនុស្សរហូតមកដល់ឡើងឆ្ពោះទៅព្រះជាម្ចាស់ ដែលជាអ្នកបំពេញតម្រូវការទាំងអស់នោះ។ *(ដើម្បីយល់ចំណុចនេះឲ្យបានច្បាស់លាស់ សូមអានជំពូកទី ៣)*។

### *៩.៦) ការមិនរវីរវល់នឹងសាសនា*

ក្នុងសង្គមទំនើប មនុស្សភាគច្រើនមិនរវីរវល់នឹងសាសនា៖ *"មានអ្នកខ្លះមិនដែលរិះគិតអំពីព្រះជាម្ចាស់ទេ គេដូចជាគ្មានរវីរវល់អំពីសាសនាសោះ ហើយគិតថាមិនបាច់រវីរវល់នឹងសាសនាណាឡើយ"* (GS ១៩,២)។ មនុស្សបែបនេះគិតថា គេមានសុភមង្គលរួចហើយ គេមិនត្រូវការព្រះណាមួយ ឬសាសនាណាមួយឡើយ ដើម្បីទទួលការសង្គ្រោះ។

ដូច្នេះហើយ បានជាទេវវិទូត្រូវសួរខ្លួនឯងថា៖ តើត្រូវធ្វើដូចម្តេច ដើម្បីប្រកាសដំណឹងល្អដល់អស់អ្នកដែលមិនត្រូវការដំណឹងល្អណាមួយ?

### *សេចក្តីបញ្ចប់៖ កំណត់ព្រំដែននៃទេវវិទ្យា*

ទេវវិទូជាច្រើនចង់បង្ហាញថា ជំនឿនៃគ្រីស្តសាសនាលើព្រះជាម្ចាស់ ដែលមានក្នុងព្រះសហគមន៍កាតូលិកជាជំនឿពិតប្រាកដ ដែលមនុស្សទាំងអស់ត្រូវតែជឿ ដើម្បីទទួលការសង្គ្រោះ។ ប៉ុន្តែទេវវិទ្យានីមួយៗមានកំណត់ព្រំដែន៖

- **Demonstratio religiosa** ៖ ទេវវិទូអះអាងថា មនុស្សគ្រប់សម័យ គ្រប់វប្បធម៌ កាន់សាសនាមួយមនុស្សជាសាសនាបុគ្គល ទើបអាចជួបព្រះជាម្ចាស់បាន។ ប៉ុន្តែសព្វថ្ងៃ ការមិនព្រមជឿលើព្រះណាមួយ ឬការមិនរវីរវល់នឹងសាសនាផ្ទាញ់អំណះអំណាងនេះ។
- **Demonstratio christiana**៖ គ្រីស្តសាសនាជាសាសនាពិតប្រាកដ ដែលបំពេញសេចក្តីរង់ចាំ សេចក្តីសង្ឃឹម និងតម្រូវការទាំងប៉ុន្មានរបស់មនុស្ស។ ប៉ុន្តែសព្វថ្ងៃ សាសនាដទៃបំពេញចិត្តគំនិតមនុស្សជាច្រើនផងដែរ។
- **Demonstratio catholica** ៖ គេអះអាងថាព្រះសហគមន៍កាតូលិក ជាព្រះសហគមន៍តែមួយពិតប្រាកដ។ ប៉ុន្តែសម្រាប់មនុស្សលោកសព្វថ្ងៃ ព្រះសហគមន៍កាតូលិកគ្រាន់តែជាព្រះសហគមន៍មួយ ក្នុងចំណោមព្រះសហគមន៍ជាច្រើនផ្សេងទៀត។

**សំណួរ៖**

១) តើពាក្យ *"ទេវវិទ្យា"* មកពីណា?
២) តើទេវវិទូមានមុខងារអ្វីខ្លះ?
៣) ហេតុអ្វីបានជាទេវវិទ្យាបានផ្លាស់ប្តូរក្នុងប្រវត្តិសាស្ត្រ?
៤) ហេតុអ្វីបានជាទេវវិទ្យាមានកំណត់ព្រំដែន?
៥) តើទេវវិទូខ្មែរសព្វថ្ងៃត្រូវប្រឈមមុខនឹងអ្វីខ្លះ?

# ជំពូកទី ៣
# ទេវវិទូសំខាន់ៗ

****

## ១) សន្ត:ថូម៉ាសអាគីណាស (Thomas Aquinas)[6]

នៅសតវត្សទី ១៣ នៅទ្វីបអឺរ៉ុប មានទេវវិទូគ្រីស្តបរិស័ទដ៏ល្បីល្បាញជាច្រើន (សន្ត:បូណាវង់ទូរ៍ (Bonaventure) លោកដូនស្កូត (Dun Scott) លោកគីយ៉ូម ដូកាម (Guillaume d'Occam)) និពន្ធសៀវភៅស្តីអំពីលទ្ធិនៃគ្រីស្តសាសនាតាមរបៀបថ្មី គឺដោយប្រើទស្សនវិទ្យា និងហេតុផលស្របតាមប្រាជ្ញា ហេតុនេះហើយបានជាទេវវិទ្យារីកចម្រើនជាខ្លាំង។

ក្នុងចំណោមអ្នកនិពន្ធទាំងអស់នោះ សន្ត:ថូម៉ាស កើតនៅអាគីណាស នៅប្រទេសអ៊ីតាលី នៅឆ្នាំ ១២២៥។ លោកចូលបួសក្នុងក្រុមគ្រួសារបព្វជិតដូមីនីកូនៅឆ្នាំ ១២៤៤។ លោកចូលរៀននៅមហាវិទ្យាល័យនៅទីក្រុងប៉ារីសជាមួយនឹងសន្ត:អាលបេរ៍ ដ៏ប្រសើរ (Albert the Great) ជាគ្រូបង្រៀន ហើយលោកថូម៉ាសបានសញ្ញាប័ត្រទេវវិទ្យានៅឆ្នាំ ១២៥៦។ លោកថូម៉ាសបង្រៀនគ្រប់កន្លែងនៅអឺរ៉ុប មុននឹងទទួលមរណភាព នៅឆ្នាំ ១២៧៤ នៅតាមផ្លូវទៅសន្និបាតទីក្រុងលីយ៉ុង *(ប្រទេសបារាំង)*។

ស្នាដៃរបស់លោកថូម៉ាសមានឈ្មោះថា "Summa Theologiae" មាន៣វគ្គ។ ការធ្វើសំយោគរវាងលទ្ធិនៃគ្រីស្តសាសនា ដែលទទួលពីជំនាន់ដើម និងវប្បធម៌សម័យលោក ដោយយកទស្សនវិទ្យារបស់លោកអារីស្តូត និងលោកប្លាតុង (Platon) មករិះគិត។

លោកតែងតែចាត់ទុកខ្លួនឯងជាទេវវិទូ ហើយមិនចង់ប៉ះពាល់នឹងទស្សនវិទ្យា[7] លើកលែងតែដើម្បីពង្រឹងទេវវិទ្យាឲ្យបានស្របតាមប្រាជ្ញា។ ដូចសន្ត:អង់សេលម៍ លោកថូម៉ាសមានបំណងចង់ស្វែងយល់ជំនឿ (Fides quaerens intellectum)។ ទេវវិទូមានមុខងារពន្យល់សេចក្តីពិតទាំងអស់នៃជំនឿ ដោយប្រើទស្សនវិទ្យា ដូចជាឧបករណ៍ម្យ៉ាង៖ ទស្សនវិទ្យាជាអ្នកបម្រើរបស់ទេវវិទ្យា។ ជាពិសេសនៅសតវត្សទី ១៣ នោះ គេរកឃើញ និងអានឡើងវិញទស្សនវិទ្យារបស់លោកអារីស្តូត (Aristote) ជាទស្សនវិទូក្រិកពីសម័យដើម។ លោកថូម៉ាសប្រើរបៀបទស្សនវិទ្យានេះ គឺលោកបញ្ចេញអំណះអំណាងដ៏ត្រឹមត្រូវ ដែលមានហេតុផលច្បាស់លាស់ ស្របតាមប្រាជ្ញា (ដែលជាកត្តារួមរបស់មនុស្សទាំងអស់) ដើម្បីពន្យល់សេចក្តីទាំងប៉ុន្មានទាក់ទងនឹងជំនឿ។ គេហៅរបៀបរិះគិតបែបនេះថា ទេវវិទ្យា ស្កូឡាស្ទិក។ ទេវវិទ្យានេះ មិនសូវប្រើព្រះគម្ពីរ និងហេតុផលរបស់គ្រូបាធ្យាយដូចកាល

---

*6 សូមអានសៀវភៅ "ព្រះអំណោយទាន" របស់លោកឪពុកអស្លេ (Ashley)*

*7 នៅសម័យនោះ ដែលជាសង្គមគ្រីស្តបរិស័ទពាក្យ "ទស្សនវិទ្យា" មានអត្ថន័យអវិជ្ជមាន គឺសំដៅទៅលើអស់អ្នកដែលមិនជឿ។*

ពីមុនឡើយ។ សម្រាប់លោក ទេវវិទ្យាជាវិទ្យាសស្ត្រនៃជំនឿ ប៉ុន្តែវិទ្យាសាស្ត្រនេះ ជាវិទ្យាសាស្ត្រដ៏សក្ការៈដែលគោលការណ៍ទាំងប៉ុន្មាន ចុះក្រោមអំណាចនៃសេចក្តី ដែលព្រះជាម្ចាស់បានសម្តែងឲ្យយើងស្គាល់។ ដូច្នេះហើយ បានជាទេវវិទ្យាជាវិទ្យាសាស្ត្រសំខាន់ជាងគេ ដែលចេញមកពីព្រះជាម្ចាស់ ហើយដែលប្រើទស្សនវិទ្យា (ប្រាជ្ញា) ដើម្បីពន្យល់ជំនឿកុំឲ្យអ្នកជឿវង្វេង ឬភ័ន្តច្រឡំឡើយ។

លោកថូម៉ាសដូចជាបែងចែកសេចក្តី ដែលប្រាជ្ញាមនុស្សលោកអាចស្គាល់ដោយខ្លួនឯង នឹងសេចក្តីហួសប្រាជ្ញា គឺសេចក្តីដែលព្រះជាម្ចាស់សម្តែងឲ្យមនុស្សលោកស្គាល់។ ធ្វើដូច្នោះ មានគេស្តីលោកថា លោកដូចជាបែងមនុស្សជាពីរផ្នែកម្យ៉ាង។ ប៉ុន្តែសម្រាប់លោកថូម៉ាស ទេវវិទ្យា *(ជំនឿ)* និងទស្សនវិទ្យា *(ប្រាជ្ញា)* ប្រៀបធៀបដូចជាស្លាបទាំងពីរនៃសេចក្តីពិត ដែលមិនអាចប្រឆាំងនឹងគ្នាបានឡើយ ព្រោះសេចក្តីពិតមានតែមួយ ដែលចេញមកពីព្រះជាម្ចាស់ ជាព្រះតែមួយគត់ដែរ (Fides et ratio)៖ *"ព្រះហឫទ័យប្រណីសន្តោសមិនប្រឆាំងនឹងធម្មជាតិមនុស្សទេ ប៉ុន្តែបំពេញធម្មជាតិនេះវិញ"*។

## ២) លោកការល បារថ៍ (Karl Barth)[8]

នៅសតវត្សទី ១៦ លោកលូធែរ (Luther) ជាបូជាចារ្យបព្វជិតកាតូលិកម្នាក់ បែកចេញពីព្រះសហគមន៍កាតូលិក និងបង្កើតក្រុមនិកាយថ្មីមួយទៀត ដែលគេហៅខ្លួនថា *"ប្រូតេស្តង់"*។ ពាក្យនេះ មកពីភាសាបារាំង ដែលគេបកប្រែថា *"អ្នកតវ៉ា ឬអ្នកប្រឆាំង"*។

នៅពេលជាមួយគ្នានេះ លោកលូធែរប្រឆាំងនឹងទេវវិទ្យាស្កូឡាស្ទីក ដែលបានក្លាយទៅជាប្រព័ន្ធដ៏អរូបិយ ដែលពឹងផ្អែកលើប្រាជ្ញា និងទស្សនវិទ្យាតែប៉ុណ្ណោះ ដាច់ពីប្រភពនៃជំនឿគឺព្រះគម្ពីរ។ ពួកគេស្តីថា ទេវវិទ្យាបែបនេះ មិនទាក់ទងនឹងការរស់នៅប្រចាំថ្ងៃរបស់គ្រីស្តបរិស័ទឡើយ។ លោកសូមឲ្យប្រើព្រះគម្ពីរតែប៉ុណ្ណោះ (Sola Scriptura) ដើម្បីស្វែងយល់ជំនឿ។ ព្រះសហគមន៍កាតូលិកបានឆ្លើយតបនឹងលោកក្នុងមហាសន្និបាតនៅទីក្រុងត្រង់ (១៥៤៦)៖ (សូមអានជំពូកស្តីអំពី *"ទំនាក់ទំនងរវាងព្រះគម្ពីរ ការបញ្ជូនបន្ត នឹងក្រុមមេដឹកនាំព្រះសហគមន៍"*)។

ដូចលោកលូធែរ៍ រួមជាមួយលោក រូដូល បូល្តម៉ាន (Rudolph Bultmann) យ៉ូគែន មូល្តម៉ាន (Jürgen Moltmann) និងលោក ប៉ូល ទីលីច (Paul Tillitch) លោក កាលបារថ៍ (១៨៨៦-១៩៦៨) ជាទេវវិទូ និងជាគ្រូគង្វាលប្រូតេស្តង់ដ៏ល្បីល្បាញម្នាក់។ គំនិតថ្មីរបស់លោកបានជួយយើងជាគ្រីស្តបរិស័ទកាតូលិក ឲ្យរៀបចំមហាសន្និបាតវ៉ាទីកង់ទី ២។

លោក កាលបារថ៍ អះអាងថា *"មានតែព្រះជាម្ចាស់ទេ ដែលមានព្រះបន្ទូលត្រឹមត្រូវអំពីព្រះជាម្ចាស់"* គឺលោកប្រឆាំងនឹងអស់អ្នក (សូម្បីតែទេវវិទូក្តី) ដែលមានបំណងចង់ប្រើព្រះជាម្ចាស់ ដើម្បីជាប្រយោជន៍ផ្ទាល់ គឺព្រះជាម្ចាស់ជាព្រះដ៏ខ្ពង់ខ្ពស់បំផុត ខុសប្លែកពីមនុស្សលោក ដែលមានសេរីភាពពេញលេញ។ ហេតុនេះហើយ បានជាទេវវិទូពិតប្រាកដជាទេវវិទូ ដែលប្រឈមមុខនឹងព្រះគម្ពីរ និងហ៊ានកែទេវវិទ្យា តាមព្រះបន្ទូលរបស់ព្រះជាម្ចាស់។ គេហៅទេវវិទ្យានេះ ទេវវិទ្យានៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ ឬទេវវិទ្យាបដិសំយោគ (dialectic)

---

*8 សូមអានសៀវភៅគ្រូអប់រំជំនឿ "ស្ពាព្រះហស្តទី១ និងប្រវត្តិសាស្ត្រព្រះសហគមន៍ជំពូកទី៩និងទី១០*

ឬទេវវិទ្យានៃវិបត្តិ (Krisis)។

សម្រាប់លោក បារថ៍ ការសម្តែង គឺជាមនុស្សម្នាក់ ព្រះយេស៊ូគ្រីស្តផ្ទាល់ ដែលនាំយើងឲ្យ "រិះគិតពិចារណាអំពីព្រះជាម្ចាស់ប្រឆាំងនឹងគំនិត *(ក្លែងក្លាយរបស់មនុស្ស)* អំពីព្រះជាម្ចាស់។ ព្រះយេស៊ូជាការ *"យល់ព្រម"* ជានិច្ច លើសពីការ *"មិនយល់ព្រម"* ទាំងអស់របស់មនុស្សលោក ដែលសុទ្ធតែជាអ្នកបាប។ តាមការពិតលោក កាលបារថ៍ ចង់បញ្ជាក់យ៉ាងខ្លាំងថា ព្រះជាម្ចាស់ជាព្រះដ៏ខ្ពង់ខ្ពស់បំផុត ខុសប្លែកពីមនុស្សឆ្ងាយណាស់។ លោកចង់បង្ហាញអំពីសិរីរុងរឿង និងឯករាជ្យរបស់ព្រះជាម្ចាស់ ទើបលោកបោលអ្វីៗទាំងអស់ ដែលមកពីមនុស្សដូចជាការស្គាល់ព្រះជាម្ចាស់តាមធម្មជាតិ *(តាមប្រាជ្ញា) (តាមទស្សនវិទ្យា)* គឺមនុស្សមិនអាចថ្លែងអំពីព្រះជាម្ចាស់បានឡើយ *("មានតែព្រះជាម្ចាស់ទេ ដែលមានព្រះបន្ទូលត្រឹមត្រូវអំពីព្រះអង្គ")* គឺមនុស្សគ្រាន់តែត្រូវស្តាប់ព្រះបន្ទូលរបស់ព្រះអង្គប៉ុណ្ណោះ។

លោក បារថ៍ ខ្លាចថា ព្រះជាម្ចាស់ និងមនុស្សលោកដូចជាលាយនឹងគ្នា។

ទោះបីព្រះជាម្ចាស់ប្រោសយើងឲ្យទៅជាសុចរិតយ៉ាងណាក៏ដោយ ក៏ព្រះអង្គសព្វព្រះហឫទ័យឲ្យយើងចូលរួមក្នុងការសង្គ្រោះដែរ៖ *"មនុស្សអាចចូលរួមចំណែកបានមកពីព្រះហឫទ័យប្រណីសន្ដោស របស់ព្រះជាម្ចាស់ដែរ ប៉ុន្តែព្រះអង្គមិនធ្វើអ្វីៗទាំងអស់ឡើយ"* (មហាសន្និបាតទីក្រុងត្រង់) (សូមអានជំពូកស្តីអំពីអ្វីទៅជាជំនឿ?)។

## ៣) **លោកកាល រ៉ានើរ** (Karl Rahner)9

លោក កាល រ៉ានើរ (១៩០៤-១៩៨៤) ជាទេវវិទូកាតូលិក ជនជាតិអាល្លឺម៉ង់ម្នាក់ ជាសមាជិកបព្វជិតសហជីវិត ដែលមានបំណងចង់ប្រកាសដំណឹងល្អ ឲ្យមនុស្សលោកទាំងអស់ស្គាល់។ លោក កាល រ៉ានើរ និពន្ធសៀវភៅមួយ ដែលមានចំណងជើងថា *"ក្បួនមូលដ្ឋាននៃជំនឿ"* ។ ក្នុងសៀវភៅនេះ លោក រ៉ានើរ ស្តីបន្ទោសទេវវិទ្យាស្កូឡាស្ទីកថា ទេវវិទ្យាបែបនេះ បែកមនុស្សជាពីរផ្នែក៖ ផ្នែកធម្មជាតិ និងផ្នែកហួសធម្មជាតិ *(ការប្រណីសន្ដោស)* ហើយទេវវិទ្យានេះ ដូចជាមិនទាក់ទងនឹងការរស់នៅប្រចាំថ្ងៃរបស់មនុស្សលោកសព្វថ្ងៃ។ ក្នុង ៩ ដំណាក់កាល លោកព្យាយាមបង្ហាញថា គ្រីស្តសាសនាបំពេញជម្រៅចិត្តមនុស្សឲ្យបានពេញលក្ខណៈ។

ក្នុងដំណាក់កាលទាំង ៣ ដំបូង លោកចាប់ផ្តើមពីមនុស្ស ដែលតែងតែរកព្រះជាម្ចាស់។ តើរចនាសម្ព័ន្ធរបស់មនុស្សជាអ្វី បានជាគេអាចទទួលព្រះជាម្ចាស់? តើមនុស្សត្រូវទៅជាយ៉ាងណា បានជាគេអាចទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់បាន? គឺលោកចង់បង្ហាញថា ក្នុងជម្រៅចិត្តមនុស្សមានអ្វីម៉្យាង ដែលធ្វើឲ្យគេអាចស្តាប់ និងយល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ មនុស្សមានសភាវៈហួសធម្មជាតិ (Supernatural Existential) (ដូចជាឧបករណ៍ក្នុងចិត្ត ដើម្បីឲ្យគេអាចមានទំនាក់ទំនងជាមួយព្រះជាម្ចាស់)។ ដូច្នេះ ដើម្បីធ្វើទេវវិទ្យាយ៉ាងត្រឹមត្រូវ ត្រូវតែធ្វើទស្សនវិទ្យាផងដែរ។ បើយើងចង់និយាយអំពីព្រះជាម្ចាស់ យើងក៏ត្រូវនិយាយអំពីមនុស្សផងដែរ។ សម្រាប់លោក កាល រ៉ានើរ មនុស្សតែងតែស្វែងរកគោលដៅនៃជីវិត មានបំណងឥតឈប់ឈរទៅរកព្រះជាម្ចាស់ជាអ្នករង់ចាំព្រះអង្គជានិច្ចទាល់តែបានអស់ចិត្ត។ ចាប់ពីដំណាក់កាលទី ៤ លោកបង្ហាញថា ព្រះជាម្ចាស់

---

9 *សូមអានសៀវភៅ "ព្រះអំណោយទាន" របស់លោកឪពុកអស្លេ* (Ashley)

យាងមករកមនុស្សស្វែងរកមនុស្ស ហើយព្រះអង្គគង់នៅក្នុងជម្រៅចិត្តមនុស្ស។ គឺលោកចង់បង្ហាញថា ការប្រណីសន្តោសស្ថិតក្នុងធម្មជាតិមនុស្សតែម្ដង។ សភាវៈហួសធម្មជាតិនេះ ជាព្រះអំណោយទាននៃការប្រណីសន្តោសរួចស្រេចទៅហើយ។ ហេតុនេះហើយ បានជាលោកសរសេរថា មនុស្សភាគច្រើនដូចជាគ្រីស្តបរិស័ទដែលមិនដឹងខ្លួនថា គេជាគ្រីស្តបរិស័ទអនាមិក ("Anonymous Christians") គឺអស់អ្នកដែលស្វែងរកព្រះជាម្ចាស់ ដោយមានឆន្ទៈល្អ និងប្រព្រឹត្តអំពើល្អ។

មានគេស្ដីបន្ទោសលោកថា លោកយល់ច្រឡំការសម្ដែងរបស់ព្រះជាម្ចាស់ក្នុងអង្គព្រះគ្រីស្ត ដែលមានតែគ្រីស្តបរិស័ទទទួល និងស្គាល់ជាមួយនឹងការប្រណីសន្តោស ដែលព្រះជាម្ចាស់ប្រោសប្រទានឲ្យមនុស្សទាំងអស់ដើម្បីសង្គ្រោះគេ។ សម្រាប់លោក រ៉ានើរហាក់ដូចជាមិនចាំបាច់ឲ្យព្រះគ្រីស្តសម្ដែងព្រះជាម្ចាស់ឡើយ។ ទោះជាយ៉ាងណាក៏ដោយ លោក កាល់រ៉ានើរ បានជួយរៀបចំមហាសន្និបាតវ៉ាទីកង់ទី ២ ដោយជួយបំភ្លឺចិត្តគំនិតគ្រីស្តបរិស័ទនៅសម័យនោះឲ្យយល់ឃើញថា ព្រះជាម្ចាស់គង់នៅក្នុងចិត្តមនុស្សទាំងអស់ ជួយសង្គ្រោះពួកគេទាំងអស់គ្នា តាមព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គ។ លើសពីនេះទៅទៀត លោកបានជួយយើងឲ្យមានទំនាក់ទំនងជាមួយនឹងសាសនាដទៃ ដែលជា *"រស្មីនៃសេចក្ដីពិត" (សូមអានជំពូកស្ដីអំពីសាសនាដទៃ)*។

## ៤) លោក ហានស៍ អ៊ឺរស៍ វ៉ុន បាលថាសារ៍ (Hans Urs von Balthasar)

លោកកើតនៅប្រទេសស្វីសនៅឆ្នាំ ១៩០៥។ លោកបានចូលសិក្សានៅវិទ្យាល័យរបស់ក្រុមសហជីវិត ព្រះយេស៊ូ។ បន្ទាប់មកលោកបានទទួលបរិញ្ញាប័ត្របណ្ឌិតផ្នែកអក្សរសាស្ត្រអាល្លឺម៉ង់។ ក្នុងឆ្នាំ ១៩២៩ លោកបានចូលក្រុមសហជីវិតព្រះយេស៊ូនៅប្រទេសអាល្លឺម៉ង់ ហើយលោកទទួលការតែងតាំងជាបូជាចារ្យឆ្នាំ ១៩២៦ ។ ក្នុងឆ្នាំ ១៩៤០ ដោយមានរបបណាស៊ីបៀតបៀនលើសេរីភាពនៃកាសែតកាតូលិក លោកបានចាកចេញពីអាល្លឺម៉ង់។ នៅឆ្នាំ ១៩៤០ លោក បាលថាសារ៍ បានទទួលអ្នកស្រី Adrienne von Speyr ធ្វើជាសហការី។ បន្ទាប់មកលោកចាកចេញពីក្រុមសហជីវិតព្រះយេស៊ូ ហើយត្រូវបានទទួលជាបូជាចារ្យភូមិភាគ នៃភូមិភាគឈឺរ៍ (Chur)។

សម្ដេចប៉ាបមិនបានអញ្ជើញលោកឲ្យចូលរួមមហាសន្និបាតវ៉ាទីកង់ទី ២ ឡើយ ។ ទោះជាយ៉ាងណាក៏ដោយ ក៏ច្រើនឆ្នាំក្រោយមកកេរ្តិ៍ឈ្មោះរបស់លោកក្នុងឋានៈជាទេវវិទូបានល្បីល្បាញឡើង។ នៅឆ្នាំ ១៩៦៩ សម្ដេចប៉ាបប៉ូលទី ៦ បានតែងតាំងលោកឲ្យធ្វើការក្នុងគណៈកម្មការទេវវិទ្យាអន្តរជាតិ។ បន្តិចម្ដងៗ កេរ្តិ៍ឈ្មោះរបស់លោកបានល្បីល្បាញ ហើយសម្ដេចប៉ាប យ៉ូហាន ប៉ូលទី ២ ដាក់ឈ្មោះលោកជាការឌីណាលនៅឆ្នាំ ១៩៨៨។ ជាអកុសលលោកទទួលមរណភាពពីរថ្ងៃមុនពិធីតែងតាំងនោះ។

លោករិះគន់ទេវវិទ្យារបស់គ្រូបាធ្យាយ និងទេវវិទ្យារបស់សម័យទំនើប ជាពិសេសរបស់លោក កាល រ៉ានើរ គឺតាមគ្រូបាធ្យាយ គ្រីស្តសាសនាបំពេញអត្ថន័យនៃសកលលោក ឯតាមទេវវិទ្យាទំនើប គ្រីស្តសាសនាបំពេញជម្រៅចិត្តមនុស្ស ទើបគ្រីស្តសាសនាជាសេចក្ដីពិត។ សម្រាប់លោក បាលថាសារ៍ ទេវវិទ្យានោះ បន្ទោសគ្រីស្តសាសនា តាមការពិតគ្រីស្តសាសនាមិនត្រូវដោះសារខ្លួនឯងសោះ។ ដោយសារព្រះជាម្ចាស់ស្រឡាញ់មនុស្សលោករហូតដល់បូជាព្រះជន្មនៅលើឈើឆ្កាង យើងអាចសន្និដ្ឋានថា គ្រីស្តសាសនាជាសេចក្ដីពិតតែម្ដង មិនចាំ

បាច់យកសកលលោក ឬជម្រៅចិត្តមនុស្សធ្វើជាទីពឹងនៃគ្រីស្តសាសនានេះឡើយ។ យើងមិនត្រូវការដោះសារសេចក្ដីស្រឡាញ់ទេ គ្រាន់តែដកពិសោធន៍បានហើយ។ យើងជឿមកពីសោភណភាពនៃសេចក្ដីស្រឡាញ់ និងសោភណភាពនៃសេចក្ដីពិតតែម្ដង។

លោក បាលថាសារ៍ បាននិពន្ធសៀវភៅជាច្រើន ប៉ុន្តែស្នាដៃសំខាន់ៗរបស់លោក *(ត្រៃវិទ្យា)* ស្របតាមអត្ថបទដំណឹងល្អរបស់សន្តៈយ៉ូហាន ហើយចែកជាបីផ្នែក៖

១)**សិរីរុងរឿង និងឈើឆ្កាង ជាផ្លូវចូលក្នុងស្នាដៃរបស់លោក៖** សោភណភាពនៃឈើឆ្កាងធ្វើឲ្យយើងផ្ញើជីវិតទៅលើព្រះជាម្ចាស់ ។ សិរីរុងរឿងរបស់ព្រះគ្រីស្ត គឺព្រះអង្គបូជាព្រះជន្មនៅលើឈើឆ្កាង គឺជាសិរីរុងរឿងផ្ទុយនឹងសិរីរុងរឿងខាងលោកីយ៍។ សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ហួសពីការស្មានរបស់យើង យើងក៏ត្រូវតែលត់ជង្គង់។

២) **វិនាដកម្មរបស់ព្រះជាម្ចាស់ ៖** ជាស្នូលនៃស្នាដៃរបស់លោក គឺថាសេចក្ដីស្រឡាញ់ និងព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់យាងមកជួបប្រទះនឹងសេរីភាពរបស់មនុស្ស ហើយវិនិច្ឆ័យគេ។ ទោះបីជាមនុស្សពុំដឹងខ្លួនយ៉ាងណាក៏ដោយ ក៏គេជាតួក្នុងវិនាដកម្មនេះរួចស្រេចទៅហើយ។

៣) **ហេតុផលរបស់ព្រះជាម្ចាស់ស្ដីអំពីព្រះវិញ្ញាណដ៏វិសុទ្ធ ៖** ដែលជួយណែនាំមនុស្សឲ្យទទួលការសង្គ្រោះ។ ក្នុងវគ្គនេះ លោករិះគិតអំពីស្ថានរកដែរ។

លោក បាលថាសារ៍ ចង់ពន្យល់ការសម្ដែងដោយប្រើពាក្យតែមួយ គឺសោភណភាព។ ព្រះគ្រីស្តដូចជាទាក់ទាញអារម្មណ៍យើង ដោយសារព្រះអង្គល្អឥតខ្ចោះជាសេចក្ដីពិត និងជាសប្បុរសធម៌ដែលគ្មានព្រំដែន។ ព្រះសហគមន៍ក៏ត្រូវឆ្លុះបញ្ចាំងសោភណភាពនេះ។

**សំណួរ៖**

១) សូមពន្យល់ទេវវិទ្យារបស់សន្តៈថូម៉ាសអាគីណាស

២) ហេតុអ្វីបានជាលោក កាលបារថ៍ ប្រឆាំងនឹងទេវវិទ្យាស្លូឡាស្ទីក?

៣) សូមពន្យល់ទេវវិទ្យារបស់លោក កាល៉រាន់នើរ

៤) តើលោក បារថ៍ និងលោក ៉រាន់នើរ បានជួយរៀបចំមហាសន្និបាតវ៉ាទីកង់ទី ២ យ៉ាងដូចម្ដេច?

៥) តើត្រូវធ្វើដូចម្ដេច ដើម្បីធ្វើទេវវិទ្យានៅស្រុកខ្មែរ?

# ជំពូកទី ៤
# មនុស្សស្វែងរកព្រះជាម្ចាស់[10]

****

តាំងពីប្រមាណមួយសតវត្សមកហើយ ទស្សនវិទូដែលមិនជឿលើព្រះណាមួយ តែងតែអះអាងថាគ្មាននរណាម្នាក់រើរវល់នឹងព្រះជាម្ចាស់ទៀតទេ។ គេធ្លាប់និយាយថា *“ព្រះជាម្ចាស់សោយទិវង្គត”*។ តើសេចក្តីនេះ ត្រឹមត្រូវឬទេ? ទោះបីជានៅក្នុងសង្គមទំនើបការអះអាងនេះ ហាក់ដូចជាត្រឹមត្រូវមែនយ៉ាងណាក៏ដោយ ក៏នៅក្នុងពិភពលោកទាំងមូលយើងយល់ឃើញថា សាសនានីមួយៗរីកចម្រើនជាខ្លាំង ទើបបង្ហាញថា តាមការពិតមនុស្សត្រូវការ និងស្វែងរកព្រះជាម្ចាស់ជានិច្ចដដែល។

នៅក្នុងជំពូកនេះ យើងនឹងរិះគិតពិចារណាអំពីទេវវិទ្យា ដែលចាប់ផ្តើមពីបទពិសោធន៍របស់មនុស្សអំពីព្រះជាម្ចាស់។ ផ្លូវរបស់យើងចាប់ផ្តើមពីមនុស្សឆ្ពោះទៅព្រះជាម្ចាស់៖ តើមនុស្សអាចទៅរកព្រះជាម្ចាស់ឬទេ? តើគេអាចជួបព្រះជាម្ចាស់យ៉ាងដូចម្តេច? តើនៅក្នុងជម្រៅចិត្តមនុស្សមានអ្វីខ្លះ បានជាគេអាចមានទំនាក់ទំនងជាមួយព្រះជាម្ចាស់? ហេតុអ្វីបានជាមនុស្សមានគំនិតអំពីព្រះជាម្ចាស់ដូច្នេះ?

***យើងនឹងប្រតិបត្តិតាមបីដំណាក់កាល៖***

- មនុស្សចាំបាច់ត្រូវការព្រះជាម្ចាស់ ទើបគេដើរតាមបីមាគ៌ា ដែលគេហៅថា *“ភស្តុតាងថាមានព្រះជាម្ចាស់មែន”* ដើម្បីទៅរកព្រះជាម្ចាស់។
- ទេវវិទូ និងទស្សនវិទូបដិសេធមិនព្រមទទួលស្គាល់មាគ៌ាទាំងបីនោះ ដោយអះអាងថា មនុស្សមិនអាចស្គាល់ព្រះជាម្ចាស់ដោយពឹងលើខ្លួនឯងបានឡើយ។
- តើការស្វែងរករបស់មនុស្សឆ្ពោះទៅព្រះជាម្ចាស់មានអត្ថន័យយ៉ាងដូចម្តេច? តើការស្វែងរកបែបនេះ បង្ហាញអ្វីខ្លះ អំពីមនុស្សផង អំពីព្រះជាម្ចាស់ផង? ហេតុអ្វីបានជាមនុស្សស្វែងរកព្រះជាម្ចាស់ដូច្នេះ?

យើងនឹងយល់ឃើញថា ទោះបីជាមនុស្សបរាជ័យ មិនអាចជួបព្រះជាម្ចាស់ដោយខ្លួនឯងបានយ៉ាងណាក៏ដោយ ក៏ការស្វែងរកនេះបង្ហាញថាមានព្រះជាម្ចាស់មែន។ ប៉ុន្តែមនុស្សត្រូវរង់ចាំឲ្យព្រះជាម្ចាស់សម្តែងព្រះអង្គឲ្យគេស្គាល់ (ជំពូកទី៥)។

## ១) តើគំនិតអំពីព្រះជាម្ចាស់ចេញមកពីណា?

មនុស្សស្វែងរកអត្ថន័យនៃជីវិត ចង់ដឹងថា តើមានព្រះជាម្ចាស់មែនឬទេ? តើមនុស្សអាចស្គាល់ព្រះអង្គ

---

*10 សូមអានលទ្ធិគ្រីស្តសាសនាពីលេខ២៧ដល់លេខ៣០*
*សូមអានសេចក្តីផ្សេងៗអំពីទេវវិទ្យារបស់លោកកាល រ៉ាន់នើរ (ជំពូកទី៣)*

បានឬទេ ? តាំងពីដើមរៀងមកមនុស្សស្វែងរកព្រះជាម្ចាស់តាមរយៈផ្សេងៗពីគ្នា។ព្រះសហគមន៍កាតូលិកអះអាងថា ប្រាជ្ញាមនុស្សអាចស្គាល់ព្រះជាម្ចាស់បាន ប៉ុន្តែដោយសារមនុស្សជាប់បាប គេអាចវង្វេងភ័ន្តច្រឡំ ដូច្នេះហើយបានជាព្រះជាម្ចាស់ត្រូវសម្តែងព្រះអង្គឲ្យមនុស្សស្គាល់ព្រះអង្គឲ្យបានគ្រប់លក្ខណៈ។

## ១.១) មនុស្សស្វែងរកព្រះជាម្ចាស់៖ "ភស្តុតាង" របស់លោកថូម៉ាសអាគីណាស

### *តើមានព្រះជាម្ចាស់ឬទេ ?*

គេឃើញមានសេចក្តីអាក្រក់ បើមានព្រះជាម្ចាស់ ហេតុអ្វីនៅតែមានអំពើអាក្រក់ ពីព្រោះព្រះជាម្ចាស់ជាសភាវៈល្អ។ ប៉ុន្តែបើយោងតាមកណ្ឌគម្ពីរសេរីភាព ព្រះជាម្ចាស់មានព្រះបន្ទូលមកលោកម៉ូសេថា៖ «យើងជាព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅ»។ ដូច្នេះ បើយោងតាមលោកថូម៉ាស មានអំណះអំណាង៥ដូចនៅខាងក្រោម៖

១)អំណះអំណាងដែលទាញចេញពីចលនា។ ចលនាមានភាពច្បាស់លាស់ និងជាភស្តុតាងសម្រាប់ញាណរបស់យើង។ លោក ថូម៉ាស ពិនិត្យឃើញថា ពេលមានចលនា លុះត្រាតែមានម្នាក់ជំរុញឲ្យមានចលនា ។ បើមានចលនាត្រូវចាប់ផ្តើមពីទីតាំងរបស់ខ្លួនឆ្ពោះទៅទីតាំងដែលត្រូវទៅ។

ឧ. ភ្លើងក្តៅកម្តៅនេះធ្វើឲ្យឈើក្តៅ ហើយឆេះឈើប្តូរទៅជាផេះ។ ភ្លើងដែលនឹងទៅជាក្តៅជាង ឬត្រជាក់ជាង។ មានចលនាទី១ ទៅទី ២ ត្រូវមានបុព្វហេតុដែលជំរុញឲ្យមានចលនា។

ឧ. ដំបូង៖ ដៃកាន់ដំបងអាចធ្វើឲ្យមានចលនា ដោយរូបកាយប្រើដៃរហូតដល់ចុងក្រោយ ជាបុព្វហេតុដែលអត់ត្រូវការជំរុញនោះគឺ *«ព្រះជាម្ចាស់»*។

២) អត្ថិភាពព្រះជាម្ចាស់ចេញមកពីបុព្វហេតុមានប្រសិទ្ធភាព។ បុព្វហេតុប្រសិទ្ធភាពតាមលំដាប់លំដោយមានរបៀបរៀបរយក្នុងសណ្តាប់ធ្នាប់។ បុព្វហេតុដំបូងគឺជា បុព្វហេតុនៃបុព្វហេតុកណ្តាល ហើយបុព្វហេតុកណ្តាលជាបុព្វហេតុនៃបុព្វហេតុក្រោយគេ។

ឧ. ម្នាក់អង្គុយលើកង់ ហើយជាក់កង់។ ប៉ុន្តែបើមិនជាក់កង់វាមិនទៅមុខទេ។ បើអត់មានបុព្វហេតុប្រសិទ្ធភាពដើម ក៏អត់មានប្រសិទ្ធភាពចុងក្រោយដែរ។ បុព្វហេតុប្រសិទ្ធភាពដើម គឺជា*«ព្រះជាម្ចាស់»* ។

៣) អត្ថិភាពរបស់ព្រះជាម្ចាស់ មានអត្ថិភាពទាញចេញពីភាពចាំបាច់ និងលទ្ធិភាពដែលអាចធ្វើបាន។

ឧ. ដើម្បីដាំដើមផ្កាបានត្រូវតែមានដី។ យើងឃើញនៅក្នុងធម្មជាតិ ចំពោះវត្ថុមានលទ្ធភាពនៅ និងមានលទ្ធភាពមិនអាចនៅ។ ពួកវាបានកើតឡើង នឹងត្រូវរលួយបាត់ទៅវិញ។ ពេលណាអ្វីមួយមានអត្ថិភាព តែពេលណាមួយទៀត អ្វីមួយនោះអត់មានអត្ថិភាព។

ឧ. មនុស្សមុនកើត និងក្រោយពីកើត។ នោះយើងឃើញថា មានពេលណាមួយអត់មានអ្វីទាំងអស់ ជាអត្ថិភាព ហើយឥឡូវនេះ មានអ្វីៗមានអត្ថិភាព។ ដូច្នេះត្រូវតែទទួលស្គាល់អ្វី ដែលមានអត្ថិភាពដំបូងដែលនាំឲ្យមានអត្ថិភាពបន្តបន្ទាប់នោះ គឺជា*«ព្រះជាម្ចាស់ »*។

៤) អត្ថិភាពរបស់ព្រះជាម្ចាស់ត្រូវបានបង្ហាញចេញពីភាពជាប់ជាលំដាប់លំដោយ ឬការមានកម្រិតដែលត្រូវរកឃើញក្នុងអ្វីៗទាំងអស់។ ភាវៈទាំងអស់មានខ្លះដែលល្អច្រើនជាង ខ្លះល្អតិចជាង មនុស្សខ្លះឆ្លាតជាងមនុស្សខ្លះល្ងង់ នោះយើងដឹងច្បាស់ថា ពិតជាមានអ្វីដែលខ្ពស់ជាង និងអ្វីដែលទាបជាង។

ឧ. ការយល់ដឹងរបស់លោក ថូម៉ាស ខុសពីការយល់ដឹងរបស់យើង។

ឧ. ព្រះអាទិត្យក្តៅ ពេលកម្តៅមកដល់ផែនដី កម្តៅត្រូវកាត់បន្ថយ។

បើយើងខិតទៅទីតាំងខ្ពស់ ល្អ ស្អាត នោះយើងកាន់តែមានសភាវៈខ្ពស់ ខិតទៅជិតគំរូ។ គំរូនៃផ្នែកណាមួយដែលខ្ពស់ជាងគេ ពិតជាមានកម្រិតទាបជាងក្នុងនោះ។

ឧ. បើសោភណភាពខ្ពស់ជាងគេ នោះពិតជាមានសោភណភាពខាងក្រោម។

គ្រូនៃសេចក្តីពិត វត្ថុមានកម្រិតនៃសេចក្តីពិត ពេលរៀននោះខិតទៅជិតសេចក្តីពិត។ គំរូនេះ គឺជា«*ព្រះជាម្ចាស់*» ។

៥) ការបង្ហាញអត្ថិភាពព្រះជាម្ចាស់ គឺចេញពីការគ្រប់គ្រងពិភពលោកតាមក្រិត្យក្រម។ យើងឃើញវត្ថុដែលខ្វះចំណេះដឹង ជាអង្គធាតុធម្មជាតិរស់នៅតាមសភាវៈ តែធ្វើចលនាតាមគោលដៅ រឿងនេះចេញមកពីហេតុថា វត្ថុតែងតែដំណើរការ ដើម្បីឆ្ពោះទិសទៅកាន់គោលដៅ មិនជារឿងចៃដន្យទេ។ សត្វអត់មានបញ្ញា វាធ្វើអ្វីៗដដែលៗតែមានប្រយោជន៍សម្រាប់ពួកវា។

ឧ. សត្វធ្វើសំបុក ទោះបីជាសតវត្សរ៍មុន ឬសតវត្សរ៍នេះ។

យើងអាចសន្និដ្ឋានថា បើវត្ថុធម្មជាតិទាំងអស់អត់មានប្រាជ្ញា ធ្វើដដែលរហូតនោះ ត្រូវមានសភាវៈដែលប្រកបដោយប្រាជ្ញាញាណ ផ្តល់ទិសដៅដល់វត្ថុធម្មជាតិទាំងអស់ ឲ្យឈានទៅរកគោលដៅរបស់ខ្លួន ឲ្យមានសណ្តាប់ធ្នាប់ក្នុងភាពស្រុះស្រួល។ សភាវៈនោះហៅថា «*ព្រះជាម្ចាស់*»។

## ១.២) មនុស្សទៅរកព្រះជាម្ចាស់៖ បីផ្លូវឆ្ពោះទៅព្រះជាម្ចាស់[11]

- ជាដំបូង មនុស្សមានទំនាក់ទំនងជាមួយព្រះជាម្ចាស់មកពីវប្បធម៌របស់ខ្លួន គឺការរស់នៅក្នុងក្រុមគ្រួសារជាពិសេសក្នុងបស្ចិមប្រទេស។ យើងហាក់ដូចជាទទួលមរតកនៃគ្រីស្តសាសនា ដែលមាតាបិតា បងប្អូន និងសង្គមទូទៅបញ្ជូនបន្ត។ ប៉ុន្តែតើត្រូវធ្វើដូចម្តេច ដើម្បីឲ្យជំនឿរបស់បុព្វបុរសយើងទៅជាជំនឿរបស់យើងផ្ទាល់?

- ពិភពលោកជាផ្លូវទីពីរ ដែលអាចនាំយើងទៅរកព្រះជាម្ចាស់។ នៅពេលដែលយើងសម្លឹងមើលធម្មជាតិសោភណភាពនៃអ្វីៗទាំងអស់នៅលើផែនដីនេះ ដែលមានក្នុងលោកនេះ យើងអាចបែរមុខទៅរកព្រះជាម្ចាស់ជាប្រភពនៃអ្វីៗសព្វសារពើដ៏អស្ចារ្យនោះ។

- ផ្លូវទីបីឆ្ពោះទៅព្រះជាម្ចាស់ គឺខ្លួនឯងផ្ទាល់ គឺនៅពេលដែលយើងរិះគិតអំពីសេចក្តីស្រឡាញ់ សេចក្តីពិត សប្បុរសធម៌...យើងអាចយល់ឃើញថា អ្វីៗទាំងអស់ដែលមានក្នុងខ្លួនមនុស្សមានព្រះជាម្ចាស់ជាប្រភព។

---

*11 សូមអានលទ្ធិគ្រីស្តសាសនាពីលេខ៣១ដល់លេខ៣៥*

## ១.៣) តើត្រូវធ្វើដូចម្ដេច ដើម្បីឲ្យដឹងច្បាស់ថា មានព្រះជាម្ចាស់មែន ឬមិនមែន?

ទោះបីជាផ្លូវទាំងបីនោះសំខាន់ណាស់ អាចណែនាំយើងទៅរកព្រះជាម្ចាស់បានយ៉ាងណាក៏ដោយ ក៏ផ្លូវទាំងបីនោះ មិនមែនជាភស្តុតាងបង្ហាញថា មានព្រះជាម្ចាស់មែនដែរ។ ផ្លូវទាំងបីនោះ គ្រាន់តែជាសញ្ញាសម្គាល់អំពីវត្តមានរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ។ តាមការពិតអាស្រ័យទៅលើការបកស្រាយរបស់បុគ្គលម្នាក់ៗ។

ម្យ៉ាងទៀត មានគេនិយាយថា មនុស្សដូចជាបង្កើតព្រះជាម្ចាស់ ព្រោះគេជាចាំបាច់ត្រូវការព្រះមួយអង្គ ដើម្បីលួងលោមចិត្តគេក្នុងគ្រាលំបាក គឺមនុស្សស្រមើស្រមៃថា មានព្រះមួយអង្គពោរពេញដោយសេចក្ដីស្រឡាញ់ ដែលនឹងរកយុត្តិធម៌សម្រាប់អស់អ្នក ដែលត្រូវគេសង្កត់ជិះជាន់។ ដោយសារមនុស្សមិនអាចយល់អំពីដំណើរការនៃពិភពលោក គេប្រឌិតព្រះមួយអង្គជាប្រភពនៃពិភពលោកនោះ។

## ២) ការរិះគន់ការស្វែងរករបស់មនុស្ស

ទាំងទេវវិទូ ទាំងទស្សនវិទូរិះគន់គំនិតថា មនុស្សអាចទៅរកជួប និងស្គាល់ព្រះជាម្ចាស់បាន។ ពួកគេរិះគន់អំពីបីចំណុច៖

### ២.១) ការរិះគន់អំពីចិត្តគំនិតមនុស្ស

- ទស្សនវិទូខ្លះ ដូចជាលោក និច្ឆឺ (Nietzshe) រិះគន់ថា ប្រាជ្ញាមនុស្សខ្សោយពេក មិនអាចស្គាល់ព្រះជាម្ចាស់បាន។ មនុស្សចង់យល់អំពីអត្ថន័យនៃជីវិត ហើយបង្កើតព្រះជាម្ចាស់ដើម្បីបានអស់ចិត្ត។ ផ្លូវទាំងបីនោះបង្ហាញបញ្ជាក់ថា មនុស្សត្រូវការទីពឹងមួយ និងជាចាំបាច់ត្រូវការស្គាល់អត្ថន័យនៃជីវិត។ ប៉ុន្តែប្រាជ្ញាមនុស្សពុំមានអំណាចអាចស្គាល់ព្រះជាម្ចាស់បានឡើយ (លោកកាន្ត)។
- ចំពោះទេវវិទូវិញ ដូចជាលោក កាល បារថ៍ មនុស្សស្វែងរកព្រះជាម្ចាស់ ក្រៅពីអ្វីដែលព្រះអង្គ បានសម្ដែងឲ្យគេស្គាល់បង្ហាញថា មនុស្សនៅតែជាអ្នកបាប មិនព្រមចុះចាញ់ព្រះហឫទ័យប្រោសប្រណីរបស់ព្រះជាម្ចាស់ នៅតែចង់បានឯករាជ្យចង់ពឹងលើខ្លួនឯងជានិច្ច។

### ២.២) ការរិះគន់អំពីផ្លូវទាំងបី

- ទស្សនវិទូរិះគន់ផ្លូវទាំងបី (វប្បធម៌ ពិភពលោក ខ្លួនមនុស្ស) ដោយអះអាងថា ផ្លូវទាំងបីនោះ គ្រាន់តែជាសញ្ញាសម្គាល់នៃវត្តមានរបស់ព្រះជាម្ចាស់ មិនអាចបង្ហាញភស្តុតាងអំពីព្រះអង្គបានឡើយ គឺអាស្រ័យលើការបកស្រាយរបស់បុគ្គលម្នាក់ៗ។
- *ចំពោះលោក កាល បារថ៍ លោកនិយាយថា "យើងស្គាល់ព្រះជាម្ចាស់ ដោយសារតែព្រះអង្គ"* គឺ យើងអាចស្គាល់ព្រះជាម្ចាស់ ព្រោះតែព្រះអង្គសព្វព្រះហឫទ័យមានព្រះបន្ទូលមកមនុស្ស មិនមែនមកពីបទពិសោធន៍ ប្រាជ្ញាចំណេះដឹង ចិត្តគំនិតរបស់មនុស្សទេ។ យើងជឿមិនមែនមកពីអំណាចរបស់យើង ប៉ុន្តែមកពីព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់។

## ២.៣) ការរិះគន់អំពីព្រះ

ទាំងទេវវិទូ ទាំងទស្សនទូរិះគន់ថា ព្រះដែលមនុស្សស្វែងរកជាព្រះក្លែងក្លាយ ដែលចេញពីការស្រមើស្រមៃរបស់គេ។ ព្រះនេះជារូបតំណាងរបស់មនុស្ស មិនអាចទៅជាព្រះដ៏ពិតប្រាកដទេ។ មនុស្សដូចជាផលិតព្រះមួយអង្គ ស្របតាមតម្រូវការរបស់គេ ហើយដែលចុះក្រោមអំណាចរបស់គេ។ ម្យ៉ាងទៀត លោក ប្រ៉ាស្កាល (Pascal) បន្ថែមទៀតថា ការស្វែងរកព្រះជាម្ចាស់ពុំមានប្រយោជន៍ ព្រោះមនុស្សមិនអាចទៅរកព្រះណាមួយដូចព្រះរបស់ព្រះយេស៊ូគ្រីស្ដដែលជាព្រះដ៏អស្ចារ្យជាទីបំផុតលើសពីការស្មានរបស់មនុស្ស។

***សេចក្ដីសង្ខេប៖***

| | **ទស្សនវិទ្យា** | **ទេវវិទ្យា** |
|---|---|---|
| ព្រះជាម្ចាស់ | ព្រះក្លែងក្លាយ | រូបតំណាងរបស់មនុស្ស |
| ផ្លូវ | សញ្ញាសម្គាល់ | ព្រះបន្ទូលរបស់ព្រះជាម្ចាស់ |
| មនុស្ស | ប្រាជ្ញាមានកំណត់ព្រំដែន | មនុស្សជាអ្នកបាប |

## ៣) មនុស្សស្វែងរកព្រះជាម្ចាស់ - ឧទាហរណ៍៖ "កិច្ចការ" របស់លោកម៉ូរីស ប្លង់ដេល

លោកម៉ូសរីសប្លង់ដេល (១៨៦១-១៩៤៩) ជាទស្សនវិទូ កើតមកក្នុងក្រុមគ្រួសារកាតូលិកនៅប្រទេសបារាំង។ ដោយសារវិទ្យាសាស្ដ្រីកចម្រើនជាខ្លាំងសម័យនោះ ជាសម័យប្រាជ្ញានិយម គឺជនជាតិបារាំងជាច្រើនលែងកាន់សាសនាកាតូលិកទៀតទេ ដ្បិតពួកគេអះអាងថា ជំនឿគ្មានហេតុផលស្របតាមប្រាជ្ញាឡើយ។ សម្រាប់ពួកគេជំនឿប្រឆាំងនឹងសាសនា។ លោក ប្លង់ដេល រំលឹកឡើងវិញ ថ្ងៃចូលរៀននៅមហាវិទ្យាល័យអក្សរសិល្ប៍បារាំង។ លោកសរសេរថា៖ *"ខ្ញុំនឹងចងចាំជានិច្ចពាក្យសម្ដីរបស់មិត្តរួមថ្នាក់ម្នាក់ នៅពេលដែលខ្ញុំបានណែនាំខ្លួនថា ខ្ញុំជាគ្រីស្ដបរិស័ទកាតូលិក។ គាត់ឆ្លើយតបមកខ្ញុំថា៖ "តើបុរសម្នាក់នេះ ដែលដូចជាមានប្រាជ្ញាឈ្លាសវៃ អាចទៅជាគ្រីស្ដបរិស័ទយ៉ាងដូចម្ដេចបាន?"*"។ ចាប់ពីពេលនោះ លោក ប្លង់ដេល សម្រេចចិត្តបង្ហាញថា ជំនឿរបស់គ្រីស្ដបរិស័ទមិនប្រឆាំងនឹងប្រាជ្ញា។

នៅឆ្នាំ ១៨៩៣ លោកសរសេរ *"កិច្ចការ"* ជានិក្ខេបបទខាងទស្សនវិទ្យា ដោយមានគោលបំណងបង្ហាញថា តើមនុស្សអាចស្គាល់ព្រះជាម្ចាស់ ដោយពឹងតែលើប្រាជ្ញារបស់ខ្លួនឯងបានឬទេ? តើប្រាជ្ញាមនុស្សអាចស្គាល់អ្វីខ្លះ អំពីព្រះជាម្ចាស់ដោយមិនចាំបាច់ឲ្យព្រះអង្គសម្ដែងព្រះអង្គឲ្យយើងស្គាល់?

លោកចាប់ផ្ដើមសួរសំណួរថា៖ *"តើជីវិតយើងមានទិសដៅឬទេ? អ្វីទៅជាគោលដៅនៃការរស់នៅរបស់យើង? ខ្ញុំរស់ដោយមិនបានសម្រេចចិត្តមានជីវិតឡើយ។ ខ្ញុំមិនដឹងថា ខ្ញុំមកពីណា និងទៅណាទេ។ តើជីវិតខ្ញុំមានអត្ថន័យអ្វីខ្លះ?"*។ លោកចង់បង្ហាញថា គ្មាននរណាម្នាក់អាចគេចផុតពីសំណួរនេះបានឡើយ។ មនុស្សទាំងអស់តែងតែប្រឈមមុខនឹងសួរសំណួរនេះ។ លោកសន្និដ្ឋានថា ចាំបាច់ត្រូវតែឆ្លើយតបនឹងសំណួរនេះ។

បន្ទាប់មក លោកបង្ហាញថា យើងចាំបាច់ចង់បានសុភមង្គល ហើយបំណងនេះគ្មានកំណត់ព្រំដែនឡើយ។

សូម្បីតែនៅពេលដែលគេអះអាងថា គេមិនចង់បានអ្វី ឬគេមិនរវីរវល់នឹងអត្ថន័យជីវិត ឬទោះបីគេចង់ស្លាប់យ៉ាងណាក៏ដោយ ក៏មនុស្សស្ទះស្វែងរកសុភមង្គលដែរ។ ប៉ុន្តែនៅពេលជាមួយគ្នានេះ លោក ប្លង់ដេល បង្ហាញថា យើងមិនអាចទៅដល់សុភមង្គលនេះបានឡើយ គឺយើងចង់បានសុភមង្គល ប៉ុន្តែយើងមិនដែលស្កប់ចិត្តឡើយ។ លោកបន្ថែមទៀតថា ទោះបីយើងស្មានថា យើងបានសុភមង្គលរួចស្រេចហើយក៏ដោយ ក៏តាមការពិតសុភមង្គលនេះ ជាសុភមង្គលក្លែងក្លាយ ដែលមិនអាចបំពេញចិត្តយើងឲ្យបានពេញលេញបានឡើយ។ យើងមិនអាចទៅដល់សុភមង្គលបានឡើយ ប៉ុន្តែចិត្តយើងចង់បានសុភមង្គលជានិច្ច។ ដូច្នេះសម្រាប់លោក មនុស្សត្រូវតែជ្រើសរើសរវាងចម្លើយបីយ៉ាងគឺ៖

- យើងអាចឆ្លើយថា ជីវិតគ្មានន័យ គឺនៅពេលស្លាប់ហើយ យើងសាបសូន្យគ្មានសល់។ ប៉ុន្តែហេតុអ្វីបានជាមានបំណងចង់បានសុភមង្គលដែលគ្មានព្រំដែននេះ ស្ថិតក្នុងជម្រៅចិត្តយើងដូច្នេះ?
- ឬមួយយើងសុខចិត្តទទួលនឹងអ្វីដែលខ្លួនគេមាន គឺជាអ្វីដែលមានកំណត់ព្រំដែន មិនអាចបំពេញចិត្តឲ្យបានពេញលក្ខណៈបានឡើយ។
- ឬមួយទៀត គឺជីវិតមានអត្ថន័យហួសធម្មជាតិ ដែលយើងមិនអាចទៅដល់ដោយខ្លួនឯងបានឡើយ។ ដូច្នេះត្រូវតែរង់ចាំទទួលសុភមង្គលដ៏គ្មានកំណត់ព្រំដែនពីអ្វីមួយ ឬម្នាក់ផ្សេងទៀត ដែលយើងមិនស្គាល់ ហើយដែលលោកប្លង់ដេលហៅថា៖ “X”។
- យើងមិនអាចផ្តល់សុភមង្គលឲ្យខ្លួនឯងបានឡើយ។ ប៉ុន្តែសុភមង្គលនេះ ចាំបាច់សម្រាប់យើង។ តើយើងត្រូវធ្វើយ៉ាងដូចម្តេច? គឺត្រូវរង់ចាំសុភមង្គលនេះ ពី “X” (អ្វីមួយ ឬម្នាក់ដែលយើងមិនស្គាល់)។ តើត្រូវធ្វើដូចម្តេចដើម្បីរកឃើញ “X”? ដោយសារយើងមិនដឹងថា “X” ស្ថិតនៅឯណា យើងមិនអាចទៅរក “X” បានឡើយ។ ផ្ទុយទៅវិញ ត្រូវតែស្វែងរក “X” នៅក្នុងចិត្តគំនិតយើងតែម្តង ដ្បិត “X” ចេញមកពីចិត្តគំនិតយើង។ លោក ប្លង់ដេល សន្និដ្ឋានថា “X” ជាព្រះជាម្ចាស់។ ដល់ពេលដំណាក់កាលនេះ យើងត្រូវតែជ្រើសរើសម្តងទៀតថា៖
- យើងមិនព្រមទទួលព្រះអំណោយទានរបស់ព្រះជាម្ចាស់ ប៉ុន្តែបើយើងធ្វើដូច្នេះ យើងប្រព្រឹត្តខុសនឹងបំណងប្រាថ្នាដ៏គ្មានកំណត់ព្រំដែនរបស់យើង។
- យើងទទួលស្គាល់ថា យើងត្រូវការ “X” យកព្រះជាម្ចាស់ធ្វើជាទីពឹង ដោយបោលសុភមង្គលក្លែងក្លាយឯទៀតៗ។ ដូច្នេះហើយ បានជាសម្រាប់លោកប្លង់ដេលទស្សនវិទ្យា ឬប្រាជ្ញាត្រូវតែទទួលជំនឿ ដើម្បីបានពេញលក្ខណៈទាំងទស្សនវិទូ ទាំងទេវវិទូបានរិះគន់លោកប្លង់ដេលថា លោកមិនគោរពព្រំដែនរវាងប្រាជ្ញា និងជំនឿ៖
- ទស្សនវិទូរិះគន់លោកប្លង់ដេលថា *“លោកអះអាងថា យើងមិនអាចស្កប់ចិត្តនឹងអ្វីដែលយើងមានក្នុងលោកនេះ គឺយើងមានលក្ខណៈហួសធម្មជាតិ។ ប៉ុន្តែយើងមិនអាចបង្ហាញភស្តុតាងអំពីលក្ខណៈហួសធម្មជាតិរបស់មនុស្សនេះបានឡើយ។ ការស្រេកទឹកមិនបង្ហាញភស្តុតាងថា មានប្រភពទឹកឡើយ”។ ម្យ៉ាងទៀត គេរិះគន់លោកប្លង់ដេលទៀតថា ហេតុអ្វីបានជា “X” ទៅជាព្រះជាម្ចាស់? គឺមកពីលោកកាន់គ្រីស្តសាសនា*

*រួចស្រេចទៅហើយ"*។

- ❖ ទេវវិទូរិះគន់លោក ប្លង់ដេលថា តាមលោកប្រាជ្ញាដូចជាបង្ខិតបង្ខំព្រះជាម្ចាស់ឲ្យសម្ដែងព្រះអង្គ ដើម្បីបំពេញការរង់ចាំ និងតម្រូវការរបស់មនុស្ស។ បើដូច្នេះមែន ព្រះអង្គគ្មានសេរីភាពសម្ដែងព្រះអង្គឡើយ។

អស់មួយជីវិត លោកប្លង់ដេលចង់សម្រុះសម្រួលប្រាជ្ញា និងជំនឿ។ ប្រាជ្ញាត្រូវតែមានឯករាជ្យចេញពីជំនឿ ឯជំនឿវិញ ត្រូវតែដាច់ដោយឡែកពីតម្រូវការនៃប្រាជ្ញារបស់មនុស្ស។ លោកចង់បង្ហាញថា ទោះបីមនុស្សមានលក្ខណៈហួសធម្មជាតិយ៉ាងណាក៏ដោយ ក៏ព្រះជាម្ចាស់នៅតែមានសេរីភាពសម្ដែងព្រះអង្គដែរ។ លោកមិនចង់ឲ្យទស្សនវិទ្យាចេញពីជំនឿ ប៉ុន្តែលោកចង់បង្ហាញថា ប្រាជ្ញាអាចណែនាំមនុស្សទៅដល់ផ្លូវចូលនៃជំនឿជាគ្រីស្តបរិស័ទ។ បញ្ហារបស់លោក គឺនៅសម័យនោះ ទស្សនវិទូប្រកាន់ជំនឿខ្លាំងពេក (ប្រាជ្ញានិយម) ឯទេវវិទូមានចិត្តបង្អៀតបង្អល់ពេកដែរ។

## ៤) តើមនុស្សអាចស្គាល់ព្រះជាម្ចាស់ដោយខ្លួនឯងបាន ឬទេ[12]?

តើ *"ការស្គាល់ព្រះជាម្ចាស់ដោយខ្លួនឯង"* មានអត្ថន័យអ្វីខ្លះ?

គេហៅការស្គាល់ព្រះជាម្ចាស់ដោយខ្លួនឯងថា *"ការស្គាល់តាមធម្មជាតិ"*។ ប៉ុន្តែការស្គាល់ព្រះជាម្ចាស់តាមធម្មជាតិខុសប្លែកពី *"ទេវវិទ្យាខាងធម្មជាតិ"*។ ទេវវិទ្យាខាងធម្មជាតិប្រឆាំងនឹង *"លទ្ធិនៃទេវកថា"* (ជារឿងប្រឌិតអំពីព្រះ) និង *"ទេវវិទ្យាខាងនយោបាយ"* (ជាពិធីផ្សេងៗដែលរដ្ឋអំណាចត្រូវតែប្រព្រឹត្ត ដើម្បីគោរពព្រះផ្សេងៗនៃប្រទេសរបស់ខ្លួន)។ ទស្សនវិទូខាងធម្មជាតិ គឺជាអស់អ្នកដែលស្វែងរកលក្ខណៈដ៏ពិតប្រាកដរបស់ព្រះដោយគ្មានរឿងប្រឌិត ឬរឿងខាងនយោបាយមកប៉ះពាល់នឹងលក្ខណៈពិតប្រាកដរបស់ព្រះនោះ។ ទស្សនវិទូរិះគន់ទេវកថា និងទេវវិទ្យានៃសង្គម ហើយស្វែងរកសេចក្ដីពិតអំពីព្រះជាម្ចាស់។

យោងតាមអត្ថន័យនេះ គ្រីស្តបរិស័ទដើមដំបូងអះអាងថា ព្រះដែលព្រះយេស៊ូគ្រីស្តបានសម្ដែងឲ្យស្គាល់ គឺជាព្រះដ៏ពិតប្រាកដស្របតាមលក្ខណៈ ដែលទស្សនវិទូបានស្វែងរកតាំងពីយូរមកហើយ ដោយរកមិនទាន់ឃើញ។ ហេតុនេះហើយបានជាសន្តៈប៉ូលសរសេរថា៖ *"ព្រះរបស់គេ (សាសន៍ដទៃ) មិនមែនជាព្រះពិតប្រាកដ"* (**កាឡ** ៤,៨) ប៉ុន្តែព្រះរបស់គ្រីស្តបរិស័ទជាព្រះតែមួយ ដែលបំពេញលក្ខណៈពិតប្រាកដរបស់ព្រះជាម្ចាស់[13]។

ប៉ុន្តែនៅសតវត្សទី ១៣ *"ការស្គាល់ព្រះជាម្ចាស់តាមធម្មជាតិ"* ទទួលអត្ថន័យថ្មី គឺ *"ធម្មជាតិ"* នេះ លែងមានអត្ថន័យថា *"ស្របតាមលក្ខណៈ (ធម្មជាតិ) របស់ព្រះ"* ហើយទទួលអត្ថន័យថ្មីថា *"ស្របតាមធម្មជាតិរបស់មនុស្ស"* វិញ។ នៅពេលនោះ ទេវវិទូខាងធម្មជាតិចង់និយាយថា ប្រាជ្ញារបស់មនុស្សអាចស្គាល់ព្រះជាម្ចាស់ដោយខ្លួនឯងបាន (គេអាចយល់ឃើញថា មានព្រះជាម្ចាស់មែន) ប៉ុន្តែព្រះជាម្ចាស់ត្រូវតែសម្ដែងព្រះអង្គ ដើម្បីឲ្យមនុស្សស្គាល់ព្រះអង្គឲ្យបានគ្រប់លក្ខណៈ *(ការស្គាល់ព្រះជាម្ចាស់ហួសធម្មជាតិ)*។ ការស្គាល់ព្រះជាម្ចាស់

---

12 *សូមអានលទ្ធិគ្រីស្តសាសនាពីលេខ៣៦ដល់លេខ៣៨*

13 *ដូច្នេះហើយ បានជាចំពោះគ្រីស្តបរិស័ទ ការស្គាល់ព្រះជាម្ចាស់តាមធម្មជាតិស្របតាមទេវវិទ្យាខាងធម្មជាតិផងដែរ។*

ឧ. *សន្តៈអូគូស្ទីនសរសើរលោក ប្លាតុង ដែលបានយល់ឃើញថា ព្រះជាម្ចាស់ជាព្រះត្រៃឯក។ ប៉ុន្តែចំពោះសន្តៈអូគូស្ទីនការស្គាល់ព្រះជាម្ចាស់ តាមធម្មជាតិនេះ មកពីព្រះអង្គផង ដែលសព្វព្រះហឫទ័យសម្ដែងឲ្យលោកប្លាតុងស្គាល់។*

តាមធម្មជាតិ ដូចជា *"សេចក្តីផ្តើម "* ម្យ៉ាង (praeambula fidei ) មុននឹងព្រះជាម្ចាស់សម្តែងព្រះអង្គ។

តាមលទ្ធិព្រះសហគមន៍កាតូលិក មនុស្សអាចស្គាល់ព្រះជាម្ចាស់ដោយខ្លួនឯងបានមកពី **រម ១,១៩** ប៉ុន្តែចំពោះលោក កាល បារថ៍ សន្តៈប៉ូលចង់និយាយថា ការស្គាល់ព្រះជាម្ចាស់នេះ មិនមែនមកពីកម្លាំងមនុស្សទេ គឺមកពីព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យគេស្គាល់ព្រះអង្គ។ ដូច្នេះហើយ បានជាក្រុមប្រូតេស្តង់មិនព្រមឯកភាពជាមួយនឹងមហាសន្និបាតវ៉ាទីកង់ទី១ (១៨៧០) ដែលអះអាងថា ប្រាជ្ញាមនុស្សអាចយល់ឃើញថា មានព្រះជាម្ចាស់ជាដើមកំណើត និងទីបុងក្រោយនៃអ្វីៗទាំងអស់។ ចំពោះលោក កាល បារថ៍ *"មានតែព្រះជាម្ចាស់ដែលអាចស្គាល់ព្រះជាម្ចាស់បាន"*។

សព្វថ្ងៃ វ៉ាទីកង់ទីពីរបានពន្យល់ថា តាមការពិតទៅនៅពេលដែលព្រះសហគមន៍កាតូលិកអះអាងថា ប្រាជ្ញាមនុស្សអាចស្គាល់ព្រះជាម្ចាស់បាន គឺមិនមែនមកពីកម្លាំងមនុស្សតែប៉ុណ្ណោះទេ ប៉ុន្តែមកពីព្រះជាម្ចាស់ជាប្រភពនៃការស្គាល់ព្រះអង្គនេះ។ ចាប់ពីកំណើតនៃពិភពលោក (រម ១,២០) ព្រះជាម្ចាស់បានសម្តែងព្រះអង្គឲ្យមនុស្សលោកស្គាល់ មុននឹងព្រះយេស៊ូគ្រីស្តចាប់កំណើតជាមនុស្សទៅទៀត។ គេហៅការស្គាល់នេះថា *"ការស្គាល់តាមធម្មជាតិ"* មិនមែនមកពីមនុស្សឯករាជ្យពីព្រះជាម្ចាស់ទេ ប៉ុន្តែមកពីព្រះជាម្ចាស់បានប្រោសប្រទានធម្មជាតិមនុស្សឲ្យស្គាល់ព្រះអង្គតាំងពីដើមរៀងមក។ ធម្មជាតិមនុស្សមានលក្ខណៈអាចស្គាល់ព្រះជាម្ចាស់បាន។ បើមិនដូច្នេះទេ មនុស្សមិនអាចទទួលការសម្តែងដែលមកពីព្រះគ្រីស្តបាន។

**សំណួរៈ**

១) តើការស្វែងរករបស់មនុស្សអំពីព្រះជាម្ចាស់បង្ហាញអ្វីខ្លះចំពោះមនុស្ស?

២) តើមានផ្លូវអ្វីខ្លះ ដែលនាំឲ្យមនុស្សអាចរកព្រះជាម្ចាស់ឃើញ?

៣) សូមរិះគន់ផ្លូវទាំងអស់នោះ។

៤) តើមនុស្សអាចស្គាល់ព្រះជាម្ចាស់ដោយខ្លួនឯងបានឬទេ? ហេតុអ្វី?

៥) ធ្វើដូចម្តេច ដើម្បីនាំពុទ្ធបរិស័ទឲ្យយល់ឃើញថា មានព្រះជាម្ចាស់មែន?

# ជំពូកទី ៥
# ព្រះជាម្ចាស់យាងមករកមនុស្ស

****

## តាមលទ្ធិគ្រីស្តសាសនា៖

៥០ *"ដោយសារប្រាជ្ញារបស់គេ មនុស្សអាចស្គាល់ព្រះជាម្ចាស់យ៉ាងច្បាស់លាស់ ពេលនឹកសញ្ជឹងអំពីស្នាព្រះហស្តរបស់ព្រះអង្គ។ ប៉ុន្តែមនុស្សមិនអាចស្គាល់ព្រះដ៏ពិតប្រាកដដោយខ្លួនឯងបានទេ គឺគេត្រូវការឲ្យព្រះជាម្ចាស់សម្តែងព្រះអង្គ (មហាសន្និបាតវ៉ាទីកង់ទី ១ Dei Filius)។ ព្រះជាម្ចាស់សម្តែងព្រះអង្គឲ្យមនុស្សស្គាល់ដោយគ្មានអ្វី ឬគ្មាននរណាបង្ខិតបង្ខំ។ ព្រះជាម្ចាស់សម្តែងអាថ៌កំបាំងរបស់ព្រះអង្គ និងគម្រោងការដ៏សប្បុរសដែលទ្រង់បានរៀបចំទុកជាមុន ក្នុងអង្គព្រះគ្រីស្តចំពោះមនុស្សលោកទាំងអស់។ ព្រះអង្គសម្តែងគម្រោងការដោយចាត់ព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គឲ្យយាងមក គឺព្រះអម្ចាស់យេស៊ូគ្រីស្ត ហើយដោយចាត់ព្រះវិញ្ញាណដ៏វិសុទ្ធឲ្យយាងមកផងដែរ"*។

ក្នុងជំពូកទីបី យើងបានសិក្សាអំពីការស្វែងរករបស់មនុស្សឆ្ពោះទៅព្រះជាម្ចាស់។ យើងបានសន្និដ្ឋានថាប្រាជ្ញាមនុស្សអាចយល់ឃើញថា មានព្រះជាម្ចាស់មែន ប៉ុន្តែយើងមិនអាចស្គាល់លក្ខណៈយ៉ាងពិតប្រាកដរបស់ព្រះអង្គបានហើយជាធម្មតា ក្នុងការស្វែងរកនេះ មនុស្សបង្កើតព្រះក្លែងក្លាយ ស្របតាមការស្រមើស្រមៃរបស់គេ។ ដូច្នេះហើយបានជាព្រះជាម្ចាស់ត្រូវតែសម្តែងព្រះអង្គឲ្យមនុស្សស្គាល់ឲ្យបានគ្រប់លក្ខណៈ។ ក្នុងជំពូកនេះយើងចាប់ផ្តើមពីព្រះជាម្ចាស់ឆ្ពោះទៅមនុស្ស។ ព្រះជាម្ចាស់យាងមករកមនុស្ស ដែលត្រូវឆ្លើយតបនឹងព្រះអង្គវិញគឺមនុស្សត្រូវសម្រេចចិត្តដើរតាមព្រះអង្គឬទេ។ ដូចសន្តៈ អ៊ីរ៉េណេ ធ្លាប់បង្រៀន យើងមិនអាចស្គាល់ព្រះជាម្ចាស់បានលើកលែងតែព្រះអង្គប្រៀនប្រដៅយើង។ បើព្រះជាម្ចាស់មិនសព្វព្រះហឫទ័យសម្តែងព្រះអង្គទេ យើងក៏មិនអាចស្គាល់ព្រះអង្គបានឡើយ។

### ១) ហេតុអ្វីបានជាព្រះជាម្ចាស់សម្តែងព្រះអង្គឲ្យមនុស្សលោកស្គាល់?

អ្វីទៅជាការសម្តែង? អ្វីទៅជាអត្ថន័យដើមនៃពាក្យ *"សម្តែង"*? តាម ២ ករ ៣,១៤-១៦ ព្រះជាម្ចាស់សម្តែងអត្ថន័យគម្ពីរលោកម៉ូសេ គឺព្រះអង្គលើកស្បៃមួយដែលនៅរាំងជនជាតិយូដាមិនឲ្យយល់អំពីអត្ថន័យពិតប្រាកដនៃគម្ពីរនោះ។ ការសម្តែង = ការមើលឃើញឲ្យច្បាស់។

តាមការពិតយើងមិនត្រូវភ្លេចថា ព្រះជាម្ចាស់សម្តែងព្រះអង្គក្នុងបីសាសនា៖ ក្នុងសាសនាយូដា ព្រះជាម្ចាស់សម្តែងព្រះអង្គតាមរយៈកិច្ចការផ្សេងៗក្នុងប្រវត្តិសាស្ត្រនៃប្រជាជនអ៊ីស្រាអែល ក្នុងអ៊ីស្លាមសាសនាព្រះជាម្ចាស់សម្តែងព្រះអង្គក្នុងសៀវភៅមួយ (ដែលគេហៅថា គូរ៉ាន) ឯក្នុងគ្រីស្តសាសនា ព្រះជាម្ចាស់សម្តែងព្រះ

អង្គផ្ទាល់ គឺនៅក្នុងអង្គព្រះយេស៊ូនៅភូមិណាសារ៉ែត។ ហេតុនេះហើយ បានជាលោកវ៉ានើរសរសេរថា គ្រីស្តសាសនាប្លែកពីសាសនាឯទៀតៗទាំងអស់។ លទ្ធិនៃគ្រីស្តសាសនាមិនមែនជាសេចក្តីណាមួយទេ ប៉ុន្តែជាព្រះគ្រីស្តផ្ទាល់តែម្តង។

## ១.១) ព្រះជាម្ចាស់សម្តែងព្រះអង្គ ដើម្បីជួយអប់រំមនុស្សលោក

បំពោះសន្តៈថូម៉ាស អាគីណាស មានមូលហេតុពីរពន្យល់ថា ព្រះជាម្ចាស់សម្តែងព្រះអង្គ គឺដើម្បីជួយសង្គ្រោះមនុស្ស ហើយដើម្បីជួយបំភ្លឺប្រាជ្ញាមនុស្ស កុំឲ្យគេប្រព្រឹត្តខុសខាងសីលធម៌តទៅទៀត។ មូលហេតុទីមួយសំខាន់ជាងគេ។

ផ្ទុយទៅវិញ បំពោះលោក កាន្ត (Kant) ព្រះជាម្ចាស់សម្តែងព្រះអង្គ គឺព្រះអង្គសម្តែងលទ្ធិខាងសីលធម៌ ដើម្បីជួយបំភ្លឺប្រាជ្ញាមនុស្ស។ លោកបន្ថែមទៀតថា ទោះបីព្រះជាម្ចាស់មិនបានសម្តែងលទ្ធិទាំងអស់នោះក៏ដោយ ក៏យូរៗទៅប្រាជ្ញាមនុស្សនឹងបានរកឃើញវិន័យខាងសីលធម៌ដោយខ្លួនឯង។ បំពោះលោក ព្រះយេស៊ូគ្រាន់តែជាគ្រូខាងសីលធម៌ ការសម្តែងជាលទ្ធិខាងសីលធម៌មួយ ហើយប្រាជ្ញាលើសអ្វីៗទាំងអស់ គឺសេចក្តីពិតមកពីមនុស្សផ្ទាល់តែម្តង។ មនុស្សទទួលការសង្គ្រោះដោយសារបំណេះដឹងរបស់គេ។

## ១.២) ព្រះជាម្ចាស់សម្តែងព្រះអង្គ ដោយសារព្រះអង្គស្រឡាញ់មនុស្សលោក

- *“ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកខ្លាំងណាស់ ហេតុនេះហើយបានជាព្រះអង្គប្រទានព្រះបុត្រាតែមួយមក”* (**យហ** ៣,១៦)៖ ព្រះជាម្ចាស់សម្តែងព្រះអង្គឲ្យមនុស្សយល់ឃើញថា ព្រះអង្គស្រឡាញ់គេខ្លាំងណាស់។ សន្តៈអូគូស្ទីន និងសន្តៈថូម៉ាស អាគីណាសពន្យល់ថា ដោយគ្មាននរណាបង្ខំព្រះជាម្ចាស់សព្វព្រះហឫទ័យសម្តែងសេចក្តីស្រឡាញ់របស់ព្រះអង្គសម្រាប់មនុស្ស។
- *“ខ្ញុំមកដើម្បីឲ្យមនុស្សលោកមានជីវិត ហើយឲ្យគេមានជីវិតពេញបរិបូណ៌”* (**យហ** ១០,១០)៖ សន្តៈអូគូស្ទីន ប្រៀបធៀបព្រះយេស៊ូដូចជាគ្រូពេទ្យ ដែលជួយព្យាបាលមនុស្ស។ ប៉ុន្តែយើងអាចសួរថា បើមនុស្សមិនបានប្រព្រឹត្តអំពើបាបដើម តើព្រះជាម្ចាស់នឹងបានសម្តែងព្រះអង្គឬទេ?

## ២) តើព្រះជាម្ចាស់សម្តែងព្រះអង្គយ៉ាងដូចម្តេច?

### *២.១) ព្រះគ្រីស្តសម្តែងព្រះជាម្ចាស់ឲ្យបានពេញលក្ខណៈ*

សន្តៈអ៊ីរ៉េណេ ពន្យល់ថា ព្រះជាម្ចាស់សម្តែងព្រះអង្គឲ្យមនុស្សស្គាល់នៅក្នុងអង្គព្រះគ្រីស្ត។ ព្រះគ្រីស្តផ្ទាល់ជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ *“ជាផ្លូវជាសេចក្តីពិត និងជាជីវិត”* (យហ ១៤,៦)។ នៅពេលព្រះអង្គរស់នៅលើផែនដីនេះ ព្រះយេស៊ូប្រកាសដំណឹងល្អសព្វថ្ងៃ ដោយសារព្រះយេស៊ូមានព្រះជន្មថ្មី (សូមអាន ១ករ ១៥,១៤) ដំណឹងល្អ គឺព្រះយេស៊ូគ្រីស្តផ្ទាល់។ ការមានព្រះជន្មថ្មីជាគន្លឹះ ដើម្បីយល់ថា ព្រះជាម្ចាស់សម្តែងព្រះអង្គនៅក្នុងអង្គព្រះគ្រីស្តយេស៊ូ។

មហាសន្និបាតវ៉ាទីកង់ទីពីរពន្យល់ថា៖ *“ព្រះអង្គសម្តែងព្រះអង្គ ដោយសារព្រឹត្តិការណ៍ និងព្រះបន្ទូល*

*ដែលភ្ជាប់ជាមួយគ្នាយ៉ាងជិតស្និទ្ធ...របៀបព្រះជាម្ចាស់សម្តែងព្រះអង្គនេះ គឺបង្ហាញសេចក្តីពិតដ៏ជ្រាលជ្រៅអំពីព្រះជាម្ចាស់ និងអំពីការសង្គ្រោះរបស់មនុស្ស។ សេចក្តីពិតទាំងពន្លឺក្នុងអង្គព្រះគ្រីស្តសម្រាប់យើង គឺព្រះគ្រីស្តជាស្ពានមេត្រីផង និងបំពេញសេចក្តីទាំងអស់ ដែលព្រះជាម្ចាស់សម្តែងឲ្យបានពេញលក្ខណៈ"* (DV 2)។

មុនព្រះយេស៊ូសោយទិវង្គត និងមានព្រះជន្មថ្មី ព្រះយេស៊ូសម្តែងព្រះជាម្ចាស់តាមរយៈកាយវិការ ព្រះបន្ទូល និងដោយត្រាស់ហៅមនុស្សឲ្យដើរតាមព្រះអង្គ។

ជាដំបូង ព្រះយេស៊ូសម្តែងព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់ ដែលព្រះអង្គឆ្លុះបញ្ចាំង ដោយសារកាយវិការរបស់ព្រះអង្គ គឺការអស្ចារ្យទាំងប៉ុន្មានរបស់ព្រះអង្គ និងទម្លាប់របស់ព្រះអង្គផង។ ព្រះអង្គប្រព្រឹត្តកិច្ចការ ដែលធ្វើឲ្យគេងឿងឆ្ងល់។ ភ្លាមៗនោះ កិច្ចការរបស់ព្រះអង្គដូចជាបំពានធម៌វិន័យនៃសាសនាយូដា អំពីការតមអាហារ (មក ២,១៨-២២) ការគោរពថ្ងៃសប្ប័ទ (មក ២,២៣...) ឬអំពីទំនៀមទម្លាប់បរិសុទ្ធ (មក ៧,១...)។ ព្រះអង្គធ្លាប់បរិភោគជាមួយនឹងអ្នកបាប និងលើកលែងទោសឲ្យគេ (លក ១៥)។ ព្រះអង្គប្រព្រឹត្តដូចជាព្រះអង្គជាព្រះជាម្ចាស់។

ម្យ៉ាងទៀត ព្រះយេស៊ូសម្តែងព្រះជាម្ចាស់តាមរយៈព្រះបន្ទូលរបស់ព្រះអង្គ ជាពិសេសដោយនិទានរឿងជាពាក្យប្រស្នា។ ព្រះយេស៊ូបង្រៀនប្រកបដោយអំណាច *(មក ១,២២ ; ២៧)*។ ព្រះអង្គអះអាងថា អំណាចនេះជាអំណាចរបស់ព្រះជាម្ចាស់ផ្ទាល់ *(មក ២,១០ ; លក ៤,២១)*។ ព្រះយេស៊ូមិនគ្រាន់តែបំពេញធម៌វិន័យទេ ថែមទាំងបង្រៀនវិន័យថ្មីដែរ *(មថ ៥)*។

ទីបញ្ចប់ ព្រះយេស៊ូបង្ហាញថា ព្រះអង្គមានអំណាច ដោយត្រាស់ហៅមនុស្សឲ្យដើរតាមព្រះអង្គ *(មក ១,១៧)*។ ព្រះយេស៊ូមិនគ្រាន់តែអញ្ជើញ ប៉ុន្តែព្រះអង្គបញ្ជាឲ្យមនុស្សសម្រេចដើរតាមព្រះអង្គ។ ត្រូវលះបង់អ្វីៗទាំងអស់ *(មក ១០,២៨)*។ ការសម្រេចចិត្តនេះ សំខាន់ដល់ជីវិត *(មក ៨,៣៤-៣៥)*។

ដូច្នេះហើយ បានជាមុនព្រះយេស៊ូសោយទិវង្គត និងមានព្រះជន្មថ្មីទៅទៀត សាវ័ករបស់ព្រះអង្គចាប់ផ្តើមយល់ឃើញថា ព្រះយេស៊ូគង់ជាមួយព្រះជាម្ចាស់យ៉ាងស្និទ្ធស្នាល ហើយព្រះអង្គលើសពីព្យាការីឯទៀតៗ *(មថ ១២,៤១-៤២)*។ តើព្រះយេស៊ូជានរណា? សូមអាន **មថ** ៣,១៧។ ក្រោយពីព្រះអង្គបានសោយទិវង្គត និងមានព្រះជន្មថ្មីសាវ័កយល់ច្បាស់ថា ព្រះយេស៊ូពិតជាព្រះជាម្ចាស់ប្រសូតជាមនុស្ស *(យហ ២០,២៨)*។

## ២.២) ព្រះជាម្ចាស់សម្តែងព្រះអង្គតាំងពីកំណើតពិភពលោក

ទោះបីព្រះយេស៊ូគ្រីស្តសម្តែងព្រះជាម្ចាស់ឲ្យបានពេញលក្ខណៈយ៉ាងណាក៏ដោយ ក៏មហាសន្និបាតវ៉ាទីកង់ទី២ ពន្យល់ថា ព្រះជាម្ចាស់សម្តែងព្រះអង្គមុនព្រះយេស៊ូប្រសូត គឺៈ *"តាំងពីដើម" "ក្រោយពីលោកអាដាំបានប្រព្រឹត្តអំពើបាបដើម"* និង *"នៅពេលកំណត់"* (DV 3)។ ម្យ៉ាងទៀត ព្រះជាម្ចាស់មានព្រះបន្ទូលតាមរយៈពួកព្យាការី ដែលបានរៀបចំប្រជាជនអ៊ីស្រាអែលឲ្យរង់ចាំព្រះមេស្ស៊ី *(ហប ១,២)*។ ព្រះជាម្ចាស់មិនដែលបានលាក់ព្រះភ័ក្ត្ររបស់ព្រះអង្គឡើយ។

***សូមអានលទ្ធិគ្រីស្តសាសនាតាមព្រះសហគមន៍កាតូលិកពីលេខ ៥១ ដល់លេខ ៧៣។***

## ២.២.១) ព្រះជាម្ចាស់សម្ដែងព្រះអង្គតាមរយៈកិច្ចការក្នុងប្រវត្តិសាស្ត្រ៖

### *លោកបាណេនប៊ែរ (Pannenberg)*

សម្រាប់លោកបាណេនប៊ែរ ព្រះជាម្ចាស់សម្ដែងព្រះអង្គក្នុងប្រវត្តិសាស្ត្រមនុស្សលោក គឺមិនគ្រាន់តែក្នុងព្រះបន្ទូល (លោកបាណេនប៊ែរ រិះគន់លោក កាល បារថ៍)។

- ព្រះជាម្ចាស់មិនសម្ដែងព្រះអង្គតែម្ដងទេ គឺព្រះអង្គសម្ដែងព្រះអង្គតាមរយៈកិច្ចការដ៏អស្ចារ្យរបស់ទ្រង់ គឺដូចជានៅពេលដែលប្រជាជនអ៊ីស្រាអែលចេញពីស្រុកអេស៊ីប។ នៅពេលនោះ ជនជាតិអ៊ីស្រាអែលយល់ឃើញថា ព្រះជាម្ចាស់ជាព្រះដែលរំដោះអស់អ្នកដែលត្រូវគេសង្កត់សង្កិន។
- ព្រះជាម្ចាស់សម្ដែងព្រះអង្គឲ្យបានពេញលក្ខណៈនៅទីបុងក្រោយនៃប្រវត្តិសាស្ត្រ *(មិនមែននៅដើមដំបូងនៃប្រវត្តិសាស្ត្រ)*។ ជនជាតិអ៊ីស្រាអែលស្គាល់ព្រះជាម្ចាស់បន្តិចម្ដងៗ រហូតដល់អវសានកាលនៃពិភពលោក។ ប៉ុន្តែលោកបន្ថែមទៀតថា ព្រះគ្រីស្តធ្វើឲ្យប្រវត្តិសាស្ត្រមកដល់ទីបុងក្រោយទុកជាមុន។
- ព្រះជាម្ចាស់សម្ដែងព្រះអង្គឲ្យមនុស្សទាំងអស់ស្គាល់ គឺការសម្ដែងមិនមែនជារឿងលាក់កំបាំងឯកជន ឬសម្ងាត់ឡើយ ទើបយើងអាចជឿទុកចិត្តបាន។
- ព្រះគ្រីស្តជាគន្លឹះនៃប្រវត្តិសាស្ត្រ បំពេញប្រវត្តិសាស្ត្រនៃជនជាតិអ៊ីស្រាអែល។ ដូច្នេះ យើងមិនត្រូវរង់ចាំឲ្យព្រះជាម្ចាស់សម្ដែងព្រះអង្គម្ដងទៀត។

## ២.២.២) ព្រះជាម្ចាស់សម្ដែងព្រះអង្គក្នុងជម្រៅចិត្តមនុស្សលោក៖ លោកកាល រ៉ានើរ

លោក កាល រ៉ានើរ ពន្យល់ថា តាំងពីកំណើតពិភពលោក ព្រះជាម្ចាស់មានព្រះបន្ទូលមកមនុស្ស គឺដោយបង្កើតមនុស្សតែម្ដង។ មនុស្សជាស្នាព្រះហស្ដរបស់ព្រះជាម្ចាស់ ជារូបតំណាងរបស់ព្រះអង្គ។ មនុស្សមានលក្ខណៈអាចមានទំនាក់ទំនងជាមួយព្រះជាម្ចាស់បាន។ នៅក្នុងជម្រៅចិត្តមនុស្សមានអ្វីម៉្យាង ធ្វើឲ្យមនុស្សអាចទទួលព្រះបន្ទូលរបស់ព្រះអង្គ គឺមនុស្សស្វែងរកសេចក្ដីពិត និងអត្ថន័យនៃជីវិត មានសេចក្ដីរង់ចាំ និងសេចក្ដីសង្ឃឹមផងដែរ។

ដូច្នេះហើយ ទោះបីមនុស្សមិនអាចស្គាល់ព្រះសហគមន៍ ឬព្រះយេស៊ូគ្រីស្តយ៉ាងណាក៏ដោយ ក៏គេអាចទទួលព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ និងប្រព្រឹត្តតាមដែរ។ នៅពេលនោះ លោក កាល រ៉ានើរ និយាយអំពីគ្រីស្តបរិស័ទ *"អនាមិក"*។

ព្រះជាម្ចាស់សម្ដែងព្រះអង្គនៅក្នុងប្រវត្តិសាស្ត្រ ក្នុងវប្បធម៌ សូម្បីតែក្នុងសាសនាមនុស្សផងដែរ ទើបលោកបាក់ឫស ដើម្បីឲ្យមានទំនាក់ទំនងជាមួយនឹងសាសនាដទៃ។

លោក រ៉ានើរ មានបំណងចង់ប្រកាសការសង្គ្រោះសម្រាប់មនុស្សទាំងអស់។ ប៉ុន្តែចំណុចខ្សោយរបស់លោក គឺលោកមិនសូវនិយាយឲ្យត្រង់ៗថា មនុស្សយើងត្រូវតែសម្រេចចិត្តធ្វើជីវិតទាំងស្រុងទៅលើព្រះជាម្ចាស់ និងដើរតាមព្រះគ្រីស្ត ដើម្បីបានទទួលការសង្គ្រោះនេះពិតប្រាកដមែន។

## ៣) បទពិសោធន៍ខាងក្នុង និងសេចក្តីពិត

សព្វថ្ងៃ មនុស្សជាច្រើនអះអាងថា បទពិសោធន៍ផ្ទាល់ខ្លួនអំពីទង្វើណាមួយ សម្តែងនូវសេចក្តីពិតនៃទង្វើនេះ។ ឧ. ពេលយល់សប្តិឃើញអំពីជាតិមុន មនុស្សភាគច្រើនសន្និដ្ឋានថា គេពិតជាបានចាប់ជាតិ។ សម្រាប់អ្នកទាំងអស់នោះ បទពិសោធន៍ជាលក្ខណៈវិនិច្ឆ័យសេចក្តីពិត។ អារម្មណ៍សំខាន់ជាងប្រាជ្ញា ការរំភើបចិត្តសំខាន់ជាងការរិះគិតពិចារណា។ ផ្ទុយទៅវិញ នៅពេលដែលយើងមិន(ទាន់) ដកពិសោធន៍អំពីហេតុការណ៍ណាមួយ យើងនៅតែសួរខ្លួនឯងថា តើហេតុការណ៍នេះពិតប្រាកដឬទេ?

តើត្រូវដកពិសោធន៍អំពីព្រះជាម្ចាស់ ដើម្បីជឿជាក់ថា ពិតជាមានព្រះជាម្ចាស់មែនឬទេ? តើយើងអាចដកពិសោធន៍អំពីព្រះអង្គបានឬទេ? តើបទពិសោធន៍នេះ សម្តែងសេចក្តីពិត ឬបទពិសោធន៍នេះចេញមកពីការស្រមើស្រមៃរបស់យើង? តើត្រូវធ្វើដូចម្តេចដើម្បីដឹងថា បទពិសោធន៍ខាងវិញ្ញាណរបស់យើងពិតប្រាកដឬទេ? តើ *"បទពិសោធន៍"* មានអត្ថន័យអ្វីខ្លះ?

ក្នុងលិខិត Fides et ratio (ជំនឿ និងប្រាជ្ញា) សម្តេចប៉ាប យ៉ូហានប៉ូលទី ២ សូមយើងកុំឲ្យច្រឡំអារម្មណ៍ជាមួយនឹងសេចក្តីពិត។ បើជំនឿអាងតែលើបទពិសោធន៍ផ្ទាល់ខ្លួនប៉ុណ្ណោះ ជំនឿនេះមិនអាចទៅជាជំនឿរបស់មនុស្សទាំងអស់ទេ។ បើជំនឿនៃគ្រីស្តសាសនាអាងលើបទពិសោធន៍ផ្ទាល់របស់មនុស្សម្នាក់ៗតែប៉ុណ្ណោះ តើយើងអាចនិយាយថា ជំនឿនេះស្របតាមសេចក្តីពិតឬទេ? តើបទពិសោធន៍ផ្ទាល់ខ្លួនគ្រប់គ្រាន់ ដើម្បីអះអាងថា យើងមានសេចក្តីពិតឬទេ? ផ្ទុយទៅវិញ បើយើងមិនអាចដកពិសោធន៍អំពីព្រះជាម្ចាស់ តើគ្រីស្តសាសនាសម្តែងសេចក្តីពិតឬទេ?

ជាទូទៅ បទពិសោធន៍ដូចជាចម្លងម្យ៉ាង គឺដោយសារបទពិសោធន៍របស់ខ្លួន មនុស្សម្នាក់ទៅជាម្នាក់ផ្សេងទៀត គឺគេរីកចម្រើនទៅជាអ្នកជំនាញក្នុងវិស័យណាមួយ ឬមានលក្ខណៈសម្បត្តិ ចរិត ឥរិយាបទប្លែកៗពីមុន។ ជាភាសាអាល្លឺមង់ ពាក្យ *"បទពិសោធន៍"* មានអត្ថន័យបីយ៉ាង៖

- **បទពិសោធន៍ខាងវិទ្យាសាស្ត្រ (Experiment)** ៖ សព្វថ្ងៃ មនុស្សភាគច្រើនជឿអ្វី ដែលមកពីវិទ្យាសាស្ត្រ គឺអ្នកវិទ្យាសាស្ត្រអាចបង្ហាញភស្តុតាងច្បាស់លាស់ ដែលមិនអាចភ័ន្តច្រឡំអំពីការអះអាងរបស់គេ។ ហេតុនេះ ហើយបានជាយើងអាចបង្ហាញភស្តុតាងថា ព្រះយេស៊ូពិតជាបានរស់នៅលើផែនដីនេះអស់រយៈពេលប្រមាណ៣០ឆ្នាំ ព្រះយេស៊ូពិតជាមនុស្សម្នាក់ក្នុងប្រវត្តិសាស្ត្រមនុស្ស ព្រះអង្គក៏មិនមែនជាតួប្រឌិត ប៉ុន្តែយើងមិនអាចបង្ហាញភស្តុតាងខាងវិទ្យាសាស្ត្រថា ព្រះយេស៊ូជាព្រះជាម្ចាស់ឡើយ ។
- **បទពិសោធន៍ក្នុងជម្រៅចិត្ត (Erlebnis)** ៖ បទពិសោធន៍នេះ មកពីអារម្មណ៍របស់មនុស្សម្នាក់ៗ ដែលដឹងខ្លួនអំពីវត្តមានរបស់ព្រះជាម្ចាស់ក្នុងចិត្តគំនិតរបស់គេ។ មនុស្សជាច្រើនកែប្រែចិត្តគំនិត ក្រោយពីបានអធិដ្ឋានយ៉ាងសប្បាយៗ លង់ស្មារតី យល់ឃើញក្នុងចិត្តគំនិតថា មានព្រះជាម្ចាស់មែន។ ប៉ុន្តែធ្វើដូចម្តេច ដើម្បីឲ្យដឹងច្បាស់ថា បទពិសោធន៍ខាងវិញ្ញាណនេះ ពិតជាមកពីព្រះជាម្ចាស់ ឬមកពីការស្រមើស្រមៃរបស់ខ្លួន?
- **បទពិសោធន៍រួម (Erfahrung)** ៖ នៅទីនេះ មនុស្សម្នាក់ដកពិសោធន៍ផ្ទាល់អំពីព្រះជាម្ចាស់ ប៉ុន្តែបទ ពិ

សោធន៍ជំរុញឲ្យគេជួបអ្នកផ្សេងទៀត ដែលមានមុខងារពិនិត្យមើលថា តើបទពិសោធន៍នេះ ពិតជាមកពីព្រះជាម្ចាស់ឬទេ?

ខ. កក ៩ រៀបរាប់អំពីលោកប៉ូលកែប្រែចិត្តគំនិត នៅតាមផ្លូវទៅទីក្រុងដាម៉ាស។ ពេលនោះ *"ស្រាប់តែមានពន្លឺមួយចាំងពីផ្ទៃមេឃមកជុំវិញគាត់"* (កក៩,៣) ហើយគាត់ឮសូរសម្លេងមួយ។ *"អស់អ្នកដែលធ្វើដំណើរជាមួយលោកនាំគ្នាឈប់ គេនៅស្ងៀមរកនិយាយអ្វីមិនកើត ព្រោះគេបានឮសម្លេង តែពុំឃើញមាននរណាឡើយ"*។ តើត្រូវធ្វើដូចម្តេច ដើម្បីដឹងថា លោកប៉ូលកំពុងតែមានបទពិសោធន៍ពិតប្រាកដអំពីព្រះជាម្ចាស់ ឬលោកកំពុងតែស្រមៃថា ព្រះជាម្ចាស់មានព្រះបន្ទូលមកគាត់? ពេលនោះ សូរសម្លេងប្រាប់លោកឲ្យទៅជួបមនុស្សម្នាក់ផ្សេងទៀត ជាសាវ័ករបស់ព្រះយេស៊ូដែលមានឈ្មោះថា អណាញ៉ាស។ លោកអណាញ៉ាសបាននិមិ្មតឃើញព្រះជាម្ចាស់ និងបានឮសម្លេងមួយដែរ។ ដោយសារលោកទាំងពីរបានជួបជាមួយគ្នា លោកប៉ូលអាច *"ភ្លឺឡើងវិញ"* គឺគាត់កែប្រែចិត្តគំនិតយ៉ាងពិតប្រាកដ។ ហេតុនេះហើយបានជាយើងអាចសន្និដ្ឋានថា ត្រូវតែមានមនុស្សម្នាក់ (គ្រីស្តបរិស័ទ) ដើម្បីពិនិត្យមើលថា តើបទពិសោធន៍ខាងវិញ្ញាណរបស់ ម្នាក់ជាបទពិសោធន៍ពិតប្រាកដអំពីព្រះជាម្ចាស់ឬទេ។

***សេចក្តីបញ្ចប់៖***

ព្រះជាម្ចាស់ជាអ្នកសម្រេចព្រះហឫទ័យថា នឹងសម្តែងព្រះអង្គឲ្យមនុស្សលោកស្គាល់ គឺមិនមែនមនុស្សដែលជាអ្នកសម្រេចចិត្តឡើយ។ ព្រះជាម្ចាស់សម្តែងព្រះអង្គតាំងពីកំណើតពិភពលោកមកម្ល៉េះ គឺនៅក្នុងជម្រៅចិត្តមនុស្សមានអ្វីម៉្យាង ដែលជំរុញគេឲ្យស្គាល់ព្រះអង្គ។ ម៉្យាងទៀត ព្រះជាម្ចាស់សម្តែងព្រះអង្គនៅក្នុងប្រវត្តិសាស្ត្រមនុស្ស (អ៊ីស្រាអែល) និងឲ្យបានគ្រប់លក្ខណៈនៅក្នុងអង្គព្រះយេស៊ូនៅភូមិណាសារ៉ែត (ព្រះជាម្ចាស់មិនគ្រាន់តែសម្តែងសេចក្តីផ្សេងៗនៅក្នុងជម្រៅចិត្តមនុស្សប៉ុណ្ណោះទេ ហើយព្រះអង្គក៏មិនសម្តែងព្រះអង្គពីខាងក្រៅតែប៉ុណ្ណោះផងដែរ)។ ព្រះជាម្ចាស់យាងមកជួបមនុស្សម្នាក់ៗ នៅក្នុងវប្បធម៌ និងប្រវត្តិសាស្ត្ររបស់ខ្លួន ដែលត្រូវតែឆ្លើយតបនឹងព្រះអង្គ ដោយសារជំនឿពិធីផ្សេងៗ និងកិច្ចការខាងសីលធម៌ គឺដោយសារជីវិតទាំងស្រុងរបស់គេ។

សំណួរ៖

១) ហេតុអ្វីបានជាព្រះជាម្ចាស់យាងមករកមនុស្ស?

២) តើព្រះជាម្ចាស់សម្តែងព្រះអង្គឲ្យមនុស្សលោកស្គាល់តាមរបៀបណាខ្លះ?

៣) តើគ្រីស្តសាសនាខុសគ្នាត្រង់ណានឹងសាសនាឯទៀតៗ?

៤) តើឃ្លា *"ព្រះជាម្ចាស់សម្តែងព្រះអង្គតាំងពីកំណើតពិភពលោក"* មានអត្ថន័យយ៉ាងដូចម្តេច?

៥) តើត្រូវធ្វើដូចម្តេចដើម្បីដឹងថា យើងដកពិសោធន៍ពិតប្រាកដអំពីព្រះជាម្ចាស់?

# ជំពូកទី ៦
# ទំនាក់ទំនងរវាងព្រះគម្ពីរ ការបញ្ជូនបន្ត និងក្រុមណែនាំព្រះសហគមន៍[14]

****

ទេវវិទូជាអ្នកបម្រើព្រះបន្ទូល ដែលជួយពន្យល់ព្រះបន្ទូលនេះ ដល់អស់អ្នកស្វែងរកព្រះជាម្ចាស់ *(១ ពេត្រ ៣,១៥)*។ ប៉ុន្តែទេវវិទូត្រូវតែគោរពគោលការណ៍ផ្សេងៗ ជាពិសេសគេត្រូវគោរពជំនឿពិតប្រាកដរបស់ព្រះសហគមន៍កាតូលិក។ ពួកលោកអភិបាលនៅមហាសន្និបាតវ៉ាទីកង់ទីពីរបានរំលឹកថា ព្រះគម្ពីរដែលជាប់ពាក់ព័ន្ធនឹងការបញ្ជូនបន្តសំខាន់ជាងគេ។ ក្រុមអ្នកដឹកនាំព្រះសហគមន៍ រួមជាមួយប្រជាជនរបស់ព្រះជាម្ចាស់ មានមុខងារបម្រើព្រះបន្ទូល។ ទីបញ្ចប់ពួកលោក សូមឲ្យយើងចាប់អារម្មណ៍អំពីទីសម្គាល់ទាំងប៉ុន្មានរបស់ព្រះជាម្ចាស់ ដែលមានក្នុងប្រវត្តិសាស្ត្រមនុស្សលោក ។ចំណុចទាំងបួននោះ (ព្រះគម្ពីរ ប្រជាជនរបស់ព្រះជាម្ចាស់ក្រុមមេដឹកនាំប្រវត្តិសាស្ត្រមនុស្សលោក) ត្រូវតែទាក់ទងនឹងគ្នា ដើម្បីឲ្យជំនឿបានត្រឹមត្រូវ។

## ១) ការសម្តែង

### *១.១) DV ១*

នៅមហាសន្និបាតវ៉ាទីកង់ទី ១ ពួកលោកអភិបាលបានសង្កត់យ៉ាងធ្ងន់ថា ត្រូវតែជឿសេចក្ដីទាំងប៉ុន្មាននៃជំនឿ ដោយសារអំណាចរបស់ព្រះសហគមន៍។ នៅទីនេះ នៅមហាសន្និបាតវ៉ាទីកង់ទី ២ មុនដំបូងពួកលោកអភិបាលប្រកាសថា ពួកលោកសម្រេចចិត្តស្ដាប់ព្រះបន្ទូលព្រះជាម្ចាស់ និងប្រតិបត្តិតាម គឺពួកមេដឹកនាំសុខចិត្តចុះចូលក្រោមអំណាចព្រះបន្ទូល ដែលមកពីព្រះជាម្ចាស់។ ម្យ៉ាងទៀត តាមអត្ថបទនេះ ព្រះជាម្ចាស់មិនគ្រាន់តែសម្តែងសេចក្តីផ្សេងៗទេ ប៉ុន្តែព្រះអង្គប្រោសប្រទានព្រះអង្គផ្ទាល់ គឺត្រូវតែផ្ញើជីវិតទាំងស្រុងទៅលើព្រះយេស៊ូគ្រីស្ត ដើម្បីបាន *“ជីវិតអស់កល្បជានិច្ច” (១យហ ១,២-៣)*។

### *១.២) DV ២*

មហាសន្និបាតវ៉ាទីកង់ទី ២បញ្ជាក់ថា ព្រះជាម្ចាស់សម្តែងព្រះអង្គដោយព្រះគ្រីស្តនៅក្នុងអង្គព្រះវិញ្ញាណដ៏វិសុទ្ធ គឺពួកលោកអភិបាលតាមលោកកាលបារប៉េ៖ព្រះជាម្ចាស់សម្តែង *“គម្រោងការដ៏អស្ចារ្យ”*(sacramentum) របស់ព្រះអង្គ ព្រះគ្រីស្តជាអត្តសញ្ញារបស់ព្រះជាម្ចាស់។ អ្នកជឿត្រូវតែមានទំនាក់ទំនងជាមួយនឹងព្រះយេស៊ូមិនគ្រាន់តែជឿសេចក្តីផ្សេងៗនៃជំនឿឡើយ។ ព្រះជាម្ចាស់មានគោលដៅប្រោសប្រទានឲ្យមនុស្សលោកចូល *“រួមចំណែក”* នៅក្នុងអង្គព្រះត្រៃឯក។

---

14 *សូមអាន* *Dei Verbum* *(ព្រះបន្ទូលរបស់ព្រះជាម្ចាស់) - មហាសន្និបាតវ៉ាទីកង់ទីពីរ*

ព្រះជាម្ចាស់ *"សន្ទនា"* ជាមួយមនុស្សលោក ដែលជា *"មិត្តសម្លាញ់"* របស់ព្រះអង្គ។ ពួកលោកអភិបាលលែងប្រើពាក្យ *"អំណាច"* ឬ *"ស្តាប់បង្គាប់"* ទៀតទេ ពួកលោកពុំមានគោលបំណងការពារជំនឿប្រឆាំងនឹងសង្គម ពួកលោកគ្រាន់តែបង្ហាញអំពីគ្រីស្តសាសនា និងស្នើសុំឲ្យមនុស្សលោកផ្ញើជីវិតទៅលើព្រះជាម្ចាស់។

ព្រះជាម្ចាស់សម្តែងព្រះអង្គតាម *"ព្រឹត្តិការណ៍ និងព្រះបន្ទូល"* ដែលភ្ជាប់នឹងគ្នា គឺដូចនៅក្នុងអគ្គសញ្ញាទាំងប៉ុន្មាន កាយវិការបញ្ជាក់ពាក្យសម្តី ហើយពាក្យសម្តីពន្យល់អត្ថន័យនៃកាយវិការ។ នៅទីនេះ ព្រះគ្រីស្តជាអគ្គសញ្ញាដើមដំបូងរបស់ព្រះជាម្ចាស់ ដែលសម្តែងព្រះអង្គ កាយវិការជាព្រឹត្តិការណ៍ដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ចំពោះប្រជារាស្ត្រ ព្រះអង្គនៅក្នុងសម្ព័ន្ធមេត្រីចាស់ជាការរស់នៅកិច្ចការ ការសោយទិវង្គត និងការមានព្រះជន្មថ្មីរបស់ព្រះគ្រីស្ត ដែលសម្តែងសេចក្តីពិត ឯព្រះបន្ទូលស័ក្តិសិទ្ធិ ជាកិច្ចការមួយដែលសម្តែង និងសម្រេចកិច្ចសង្គ្រោះតែម្តង។ ការសម្តែងនេះ កើតឡើងនៅក្នុងប្រវត្តិសាស្ត្រ ហើយតាមរយៈកាយវិការ និងពាក្យសម្តីរបស់មនុស្ស។ កាលពីមុនយើងធ្លាប់និយាយអំពីការសម្តែងតាមធម្មជាតិ និងការសម្តែងហួសធម្មជាតិ ប៉ុន្តែការគិតបែបនេះដូចជាបែងចែកការសម្តែង និងមនុស្សជាពីរផ្នែកដែលពិបាកទាក់ទងនឹងគ្នា។

ព្រះគ្រីស្តផ្ទាល់ជា *"ព្រះបន្ទូលរបស់ព្រះជាម្ចាស់"* ជាកំពូលនៃការសម្តែង ជាអ្នកសម្តែង ជាស្ពានមេត្រីជាអ្នកនាំសារ និងជាសារតែម្តង។ ក្នុងចំណោមសាសនាឯទៀតៗ មានតែគ្រីស្តសាសនាទេ ដែលស្នើសុំឲ្យផ្ញើជីវិតលើមនុស្សម្នាក់។ ដូច្នេះហើយ បានជាការសម្តែងមិនគ្រាន់តែជាសេចក្តីផ្សេងៗ ដែលមនុស្សលោកត្រូវតែជឿ។

## ***១.៣) DV ៣***

ព្រះជាម្ចាស់សម្តែងព្រះអង្គនៅក្នុងប្រវត្តិសាស្ត្ររបស់មនុស្សលោក តាមដំណាក់កាលផ្សេងៗ។

១)ជាដំបូង ព្រះជាម្ចាស់សម្តែងព្រះអង្គតាមដំណាក់កាលមួយ ដែលជាគ្រឹះនៃដំណាក់កាលឯទៀតៗ គឺព្រះអង្គសម្តែងព្រះអង្គក្នុងការបង្កើតពិភពលោក ដោយមានព្រះហឫទ័យស្រឡាញ់។ ព្រះជាម្ចាស់សម្តែងព្រះអង្គតាមរយៈស្នាព្រះហស្តរបស់ព្រះអង្គ *(មនុស្ស និងធម្មជាតិ) (រម ១,១៩-២០)*។

ពួកលោកអភិបាលមិនសម្រេចចិត្តថា អត្ថបទគម្ពីរកំណើតពិភពលោក ទាក់ទងនឹងប្រវត្តិសាស្ត្រឬទេ។ ព្រះជាម្ចាស់សម្តែងព្រះអង្គជាអចិន្ត្រៃយ៍ តាំងពីដើមដំបូងរហូតមកដល់ឥឡូវនេះ។ តាំងពីដើម ព្រះអង្គសព្វព្រះហឫទ័យឲ្យមនុស្សលោករួមរស់ជាមួយព្រះអង្គ។ ព្រះអង្គមិនបង្កើតមនុស្សលោក *"តាមធម្មជាតិ"* មុននឹង *"លើកមនុស្សឲ្យទទួលការសង្គ្រោះ"* ឡើយ។ ម្យ៉ាងទៀត ព្រះជាម្ចាស់សម្តែងព្រះអង្គមុននឹងមនុស្សធ្លាក់ខ្លួនជាអ្នកបាប បានសេចក្តីថា ដោយសារព្រះជាម្ចាស់បានបង្កើតមនុស្ស គេត្រូវការឲ្យព្រះអង្គសង្គ្រោះគេ ដោយមិនអាចសង្គ្រោះខ្លួនឯងបានឡើយ (supernae)។

២)ក្នុងដំណាក់កាលទីពីរ ព្រះជាម្ចាស់សម្តែងព្រះអង្គតាំងពីកំណើតពិភពលោករហូតដល់លោកអប្រាហាំ។ ក្រោយពីបានធ្លាក់ខ្លួនជាអ្នកបាប ព្រះជាម្ចាស់នៅតែថែរក្សាមនុស្សលោក *(កណ ៣,១៥) "ដោយមិនឈប់ឈរ"* ដើម្បីប្រទានជីវិតអស់កល្បជានិច្ចដល់អស់អ្នកស្វែងរកព្រះអង្គ។ ទោះបីមនុស្សបានប្រព្រឹត្តបាបយ៉ាង

ណាក៏ដោយ ក៏ព្រះជាម្ចាស់នៅតែសង្គ្រោះអស់អ្នក ដែលព្យាយាមប្រព្រឹត្តអំពើល្អ តាមមនសិការរបស់ខ្លួន *(រម២,៧)*។ ពួកលោកអភិបាលសំដៅទៅលើប្រជាជាតិទាំងប៉ុន្មាន ដែលមិនទាន់ស្គាល់ព្រះជាម្ចាស់នៅឡើយ។

៣)ដំណាក់កាលទីបី មានពីលោកអប្រាហាំរហូតដល់ដំណឹងល្អ គឺព្រះជាម្ចាស់សម្ដែងព្រះអង្គតាមរយៈពួកបុព្វបុរស លោកម៉ូសេ និងពួកព្យាការី។ ព្រះជាម្ចាស់ជ្រើសរើសប្រជាជនមួយ ដាច់ដោយឡែកពីប្រជាជាតិឯទៀតៗ ដើម្បីបំពេញបេសកកម្មផ្ដល់សក្ខីភាពអំពីព្រះអង្គ។ ដំណាក់កាលនេះ រៀបចំផ្លូវថ្វាយព្រះគ្រីស្ត។

## ១.៤) DV ៤

ហប ១,១ បំពេញដំណាក់កាលទាំងបីដំបូង ដោយមានព្រះគ្រីស្តសម្ដែងព្រះជាម្ចាស់តាមរបៀបថ្មី។ ឥឡូវនេះ ព្រះគ្រីស្ត *"ជំនួស"* ព្រះជាម្ចាស់ម្យ៉ាង។ ព្រះគ្រីស្តសម្ដែងព្រះជាម្ចាស់ ដោយព្រះអង្គ *"នៅជាមួយ"* តាមរយៈ *"ព្រះបន្ទូល និងកិច្ចការ"* របស់ព្រះអង្គ។ គ្រីស្តសាសនាមិនមែនជាកម្មវិធីណាមួយទេ ប៉ុន្តែជាមនុស្សម្នាក់ ជាព្រះគ្រីស្តផ្ទាល់។ ការរស់នៅទាំងស្រុងរបស់ព្រះអង្គផ្ដល់សក្ខីភាពអំពីព្រះជាម្ចាស់។ *"ទីសម្គាល់ និងការអស្ចារ្យ"* ពន្យល់បញ្ជាក់អំពីកិច្ចការរបស់ព្រះអង្គ។ *"ជាពិសេសដោយទ្រង់សោយទិវង្គត ហើយក្រោកឡើងពីចំណោមមនុស្សស្លាប់ និងមានព្រះជន្មថ្មី"* ព្រះគ្រីស្តសម្ដែងព្រះជាម្ចាស់។ ការមានព្រះជន្មថ្មីរបស់ព្រះគ្រីស្តសម្ដែងឫទ្ធានុភាពរបស់ព្រះជាម្ចាស់បង្ហាញថា ព្រះអង្គគង់នៅជាមួយយើង ហើយទ្រង់បានឈ្នះអំពើបាប និងសេចក្ដីស្លាប់។ ពួកលោកអភិបាលមិនថ្លែងអំពីព្រះសហគមន៍ដូចកាលពីមុនទេ ព្រោះព្រះសហគមន៍ទាក់ទងនឹងការបញ្ជូនបន្តការសម្ដែង (ជំពូកទី២)។

## ១.៥) DV ៥

ដូចកាលពីមុន មនុស្សត្រូវ *"ស្ដាប់បង្គាប់"* ព្រះជាម្ចាស់ ប៉ុន្តែដោយ *"ផ្ញើជីវិតទាំងស្រុង"* ទៅលើព្រះអង្គ គឺ ព្រះជាម្ចាស់ និងមនុស្ស *"សន្ទនា"* ជាមួយគ្នា។ មនុស្សមិនស្ដាប់បង្គាប់ព្រះជាម្ចាស់ ដោយសារ *"អំណាច"* *(វ៉ាទីកង់ទី ១)* របស់ព្រះអង្គឡើយ។ ជំនឿជាការផ្ញើជីវិត ដោយជឿទុកចិត្តទៅលើព្រះជាម្ចាស់ មិនគ្រាន់តែជាការជឿជាក់សេចក្ដីផ្សេងៗ។ មុនដំបូង យើងជាប់ចិត្តនឹងព្រះគ្រីស្ត បន្ទាប់មកយើងចង់ស្វែងយល់ជំនឿ ដោយមានព្រះវិញ្ញាណដ៏វិសុទ្ធជួយបំភ្លឺយើងពីខាងក្នុង។

## ១.៦) DV ៦

មហាសន្និបាតវ៉ាទីកង់ទី២អះអាងថា មនុស្សអាចស្គាល់ព្រះជាម្ចាស់ *"ដោយសារប្រាជ្ញារបស់ខ្លួន"* ប៉ុន្តែមនុស្សត្រូវការឲ្យព្រះអង្គសម្ដែងសេចក្ដីនៃជំនឿលើសប្រាជ្ញាមនុស្ស។ មហាន្និបាតមិនប្រើពាក្យ*"ធម្មជាតិ"* និង *"ហួសធម្មជាតិ"* ដូចក្នុងមហាសន្និបាតវ៉ាទីកង់ទី១ឡើយ ដ្បិតពួកអភិបាលចង់បញ្ជាក់ថា ព្រះជាម្ចាស់មានសេរីភាពស ម្ដែងព្រះអង្គឲ្យមនុស្សលោកស្គាល់ មិនអាស្រ័យទៅលើធម្មជាតិមនុស្សទេ ហើយគោលដៅចុងក្រោយរបស់មនុស្សមកពីព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ មិនមែនមកពីធម្មជាតិរបស់គេឡើយ។

### ***១.៧) សរុបសេចក្តី***

វ៉ាទីកង់ទី ១ ចង់ការពារជំនឿប្រើពាក្យ *"ហួសធម្មជាតិ"* ប្រឆាំងនឹងពួកប្រាជ្ញានិយម សង្កត់ទៅលើការស្តាប់បង្គាប់របស់មនុស្សដែលត្រូវតែជឿសេចក្តីផ្សេងៗនៃជំនឿ ដោយសារអំណាចរបស់ព្រះសហគមន៍។

នៅមហាសន្និបាតវ៉ាទីកង់ទី ២ វិញ ពួកលោកអភិបាលស្នើសុំឲ្យមនុស្សលោកផ្ញើជីវិតទៅលើព្រះយេស៊ូគ្រីស្តជាការសម្តែងរបស់ព្រះជាម្ចាស់ផ្ទាល់។ អ្នកជឿព្រមផ្ញើជីវិតទៅលើព្រះអង្គ មិនមែនមកពីអំណាចរបស់ព្រះអង្គទេ គឺមកពីព្រះអង្គស្រឡាញ់គេ *"សន្ទនា"* ជាមួយគេ។

## **២) ការបញ្ជូនបន្តសេចក្តីដែលព្រះជាម្ចាស់បានសម្តែងឲ្យមនុស្សលោកស្គាល់**

### **២.១) ព្រះគម្ពីរ**

### ***២.១.១) តើព្រះគម្ពីរមកពីណា? ការបញ្ជូនបន្ត (DV ៧ និង ៨)***

សន្តៈប៉ូលសរសេរជូនទៅគ្រីស្តបរិស័ទនៅទៅក្រុងកូរិនថូសថា៖ *"រីឯខ្ញុំ ខ្ញុំបានជម្រាបបងប្អូននូវ សេចក្តីដែលខ្ញុំបានទទួលពីព្រះអម្ចាស់មក..."*(១ករ ១១,២៣)។ មុននឹងលោកប៉ូលប្រកាសដំណឹងល្អ មានហេតុការណ៍មួយដែលលោកផ្តល់សក្ខីភាព។ អ្វីដែលលោកបានទទួល លោកក៏បញ្ជូនបន្តទៅដល់អ្នកដទៃ។

មុនដំបូង មានព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលក្រុមគ្រីស្តទូតបានបញ្ជូនបន្តឲ្យយើងស្គាល់ ដោយផ្ទាល់មាត់ ដោយសារអត្តសញ្ញា កិច្ចការផ្សេងៗ ពិធីបុណ្យបចនាសម្ព័ន្ធព្រះសហគមន៍ជាដើម។ បន្ទាប់មក គេសរសេរជាលាយលក្ខណ៍អក្សរព្រះបន្ទូលនេះ គឺព្រះគម្ពីរ។ សព្វថ្ងៃនៅពេលដែលយើងចង់ស្គាល់អំពីហេតុការណ៍ដើមនៃគ្រីស្តសាសនា យើងត្រូវដើរតាមផ្លូវបញ្ច្រាស់ គឺពីព្រះគម្ពីរដល់ព្រះបន្ទូលដើម ដែលពួកគ្រីស្តទូតបានបញ្ជូនបន្ត។ ព្រះគម្ពីរមកពីការបញ្ជូនបន្ត ប៉ុន្តែការបញ្ជូនបន្តមិនមែនមកពីព្រះគម្ពីរទេ។

នៅសតវត្សទី ១៦ ក្រុមប្រូតេស្តង់អះអាងថា មានតែព្រះគម្ពីរទេ (Sola scriptura) ដែលអាចនាំយើងឲ្យស្គាល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ផ្ទុយទៅវិញគ្រីស្តបរិស័ទកាតូលិកអះអាងថា ព្រះគម្ពីរ និងការបញ្ជូនបន្តជាប់ពាក់ព័ន្ធនឹងគ្នា។ រហូតដល់វ៉ាទីកង់ទីពីរ យើងធ្លាប់និយាយថា[15] ព្រះគម្ពីរ និងការបញ្ជូនបន្តជាប្រភពពីរនៃសេចក្តីពិតដែលព្រះជាម្ចាស់សម្តែងឲ្យស្គាល់។ តាមការពិតនៅមហាសន្និបាតនៃទីក្រុងត្រង់ ពួកលោកអភិបាលមិនព្រមអះអាងថា ព្រះគម្ពីរ និងការបញ្ជូនបន្តជាពីរប្រភពឡើយ។ សម្រាប់ពួកលោក ដំណឹងល្អជាប្រភពតែមួយនៃសេចក្តីពិតដែលនាំឲ្យទទួលការសង្គ្រោះ និងធម្មវិន័យខាងសីលធម៌ ប៉ុន្តែមានតែនៅក្នុងព្រះសហគមន៍ដែលយើងអាចបកស្រាយព្រះគម្ពីរយ៉ាងត្រឹមត្រូវ។ ពួកលោកអភិបាលខ្លាចគ្រីស្តបរិស័ទវង្វេងក្នុងជំនឿ ដោយសារលោកលូថែរ៍ ដែលអះអាងថា គ្រីស្តបរិស័ទម្នាក់ៗអាចបកស្រាយព្រះគម្ពីរតាមចិត្តរៀងៗខ្លួន *(ឬតាមព្រះវិញ្ញាណដ៏វិសុទ្ធជួយបំភ្លឺ)*។

នៅសន្និបាតវ៉ាទីកង់ទីពីរ ពួកលោកអភិបាលមិននិយាយអំពី *"ប្រភពពីរ"* ឡើយ។ ពួកលោកអះអាងថា ព្រះគម្ពីរ និងការបញ្ជូនបន្តជា *"ផ្លូវ"* ពីរដែលនាំឲ្យស្គាល់ *"ប្រភព"* តែមួយ គឺដំណឹងល្អ។ ហេតុនេះហើយបាន

---

15 ***តាមលោកបេឡាម៉ាំង*** *(Bellarmin)*។

ជា Dei Verbum រំលឹកមហាសន្និបាតទីក្រុងត្រង់ឡើងវិញ៖

*"ការបញ្ជូនបន្តដ៏វិសុទ្ធ និងព្រះគម្ពីរជាប់ពាក់ព័ន្ធគ្នានិងមានទំនាក់ទំនងយ៉ាងស្និទ្ធស្នាលជាមួយគ្នា។ ការបញ្ជូនបន្ត និងព្រះគម្ពីរផុសចេញមកពីប្រភពតែមួយ ពោលគឺពីព្រះជាម្ចាស់។ ព្រះគម្ពីរ និងការបញ្ជូនបន្តក៏ហាក់ដូចជារួមជាធ្លុងតែមួយ និងមានទិសដៅតែមួយដែរ។ ព្រះគម្ពីរជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលកត់ត្រាទុកជាលាយលក្ខណ៍អក្សរ ដោយព្រះវិញ្ញាណបំភ្លឺចិត្តគំនិតអ្នកនិពន្ធ។ រីឯការបញ្ជូនបន្តដ៏វិសុទ្ធវិញ ក៏នាំព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលព្រះគ្រីស្តជាអម្ចាស់និងព្រះវិញ្ញាណដ៏វិសុទ្ធបានផ្ញើទុកឲ្យក្រុមគ្រីស្តទូត រួចបញ្ជូនបន្តគ្រប់សេចក្តីទាំងអស់ដល់អ្នកបន្តមុខងារពីអស់លោក។ ពេលអស់លោក ដែលបន្តមុខងាររបស់គ្រីស្តទូតទាំងឡាយនោះ ប្រកាសព្រះបន្ទូលអស់លោក រក្សាទុកបកស្រាយ និងផ្សព្វផ្សាយព្រះបន្ទូលនោះយ៉ាងស្មោះ ដោយព្រះវិញ្ញាណនៃសេចក្តីពិតបំភ្លឺចិត្តគំនិតគេ។ ហេតុនេះហើយបានជាព្រះសហគមន៍មានជំនឿយ៉ាងជាក់ច្បាស់ទៅលើសេចក្តីទាំងប៉ុន្មាន ដែលព្រះជាម្ចាស់បានសម្តែងមកនោះ ពុំមែនដោយសំអាងតែលើព្រះគម្ពីរប៉ុណ្ណោះទេ..." (DV៩)*។

ទីបញ្ចប់សព្វថ្ងៃ ព្រះគម្ពីរជាផ្លូវតែមួយឲ្យព្រះសហគមន៍ស្គាល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ហេតុនេះហើយបានជាព្រះសហគមន៍ *"តែងតែគោរពប្រណិប័តន៍ព្រះគម្ពីរជានិច្ច ដូចព្រះសហគមន៍ធ្លាប់គោរពប្រណិប័តន៍ព្រះកាយផ្ទាល់របស់ព្រះអម្ចាស់ដែរ"(DV២១)*។ព្រះគម្ពីរជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលមានសារៈសំខាន់ណាស់សម្រាប់គ្រីស្តបរិស័ទ។ ប៉ុន្តែយើងមិនអាចបែកចែកព្រះគម្ពីរពីការបញ្ជូនបន្តបានឡើយ។ សន្តៈអ៊ីរ៉េណេធ្លាប់និយាយថា៖ *"យើងមិនស្គាល់លទ្ធិនៃការសង្គ្រោះ ក្រៅពីអស់អ្នកដែលបានបញ្ជូនបន្តដំណឹងល្អមកយើង ដោយប្រកាសដំណឹងល្អនេះសិន រួចសឹមសរសេរដំណឹងល្អនេះជាលាយលក្ខណ៍អក្សរ"*។

### ២.១.២) តើនរណាបានសរសេរព្រះគម្ពីរ?

នៅក្នុង DV ១១ ពួកលោកអភិបាលនិយាយអំពីការបំភ្លឺចិត្តគំនិតអ្នកនិពន្ធ។ តាម ២ធម ៣,១៦ *"គ្រប់អត្ថបទគម្ពីរ សុទ្ធតែព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណមកបំភ្លឺឲ្យតែង និងមានប្រយោជន៍សម្រាប់បង្រៀនកែខុសត្រូវកែតម្រង់ និងអប់រំឲ្យរស់នៅតាមសេចក្តីសុចរិត"*។ ដោយសារព្រះវិញ្ញាណបំភ្លឺអ្នកនិពន្ធព្រះគម្ពីរជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។

*"ព្រះវិញ្ញាណដ៏វិសុទ្ធបានបំភ្លឺចិត្តគំនិតអ្នកនិពន្ធឲ្យកត់ត្រាទុកជាលាយលក្ខណ៍អក្សរ នូវសេចក្តីពិតដែលព្រះជាម្ចាស់បានសម្តែងមក ហើយដែលមានរៀបរាប់ក្នុងកណ្ឌទាំងប៉ុន្មាននៃព្រះគម្ពីរ។ ព្រះសហគមន៍កាតូលិកជាមាតារបស់យើង សំអាងទៅលើជំនឿរបស់ក្រុមគ្រីស្តទូតជាគ្រឹះ ហើយចាត់គ្រប់ផ្នែកនៃកណ្ឌទាំងប៉ុន្មានក្នុងគម្ពីរសម្ពន្ធមេត្រីចាស់ក្តី សម្ព័ន្ធមេត្រីថ្មីក្តី ទុកជាសក្ការៈ និងទុកជាសាសនបញ្ញត្តិរបស់ខ្លួន ព្រោះព្រះវិញ្ញាណបំភ្លឺចិត្តគំនិត អ្នកនិពន្ធឲ្យសរសេរ គឺព្រះជាម្ចាស់បាននិពន្ធកណ្ឌទាំងនោះ ហើយព្រះសហគមន៍ក៏បានទទួលកណ្ឌគម្ពីរទាំងនោះ ដោយយល់ដូច្នោះដែរ។ ព្រះជាម្ចាស់បានជ្រើសរើសមនុស្សខ្លះ ដើម្បីនិពន្ធកណ្ឌព្រះគម្ពីរទាំងនោះ គឺព្រះអង្គឲ្យអ្នកទាំងនោះប្រើបំណេះប្រាជ្ញា ទេពកោសល្យ និងបច្ចេកទេសរបស់ខ្លួនយ៉ាងពិតប្រាកដ ហើយទ្រង់មានសកម្មភាព ក្នុងអ្នកទាំងនោះ និងដោយសារអ្នកទាំងនោះ ព្រះអង្គឲ្យគេកត់ត្រាទុកជាលាយ*

*លក្ខណ៍អក្សរនូវសេចក្ដីទាំងប៉ុន្មាន ដែលព្រះអង្គសព្វព្រះហឫទ័យឲ្យគេសរសេរ គឺសរសេរតែសេចក្ដីណាដែលព្រះអង្គសព្វព្រះហឫទ័យប៉ុណ្ណោះ។ ដូច្នេះគេជាអ្នកនិពន្ធយ៉ាងពិតប្រាកដ”* (DV ១១)។

- ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធជួយបំភ្លឺអ្នកនិពន្ធ ព្រះជាម្ចាស់ជាអ្នកនិពន្ធនៃព្រះគម្ពីរដ៏វិសុទ្ធ។ ព្រះគម្ពីរជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ខុសប្លែកពីសៀវភៅឯទៀតៗទាំងអស់។
- ប៉ុន្តែមហាសន្និបាតទទួលស្គាល់ថា ព្រះគម្ពីរមានមនុស្សជាអ្នកនិពន្ធផងដែរ។ មនុស្សបានសរសេរព្រះគម្ពីរដោយ *“ប្រើចំណេះប្រាជ្ញាទេពកោសល្យ និងបច្ចេកទេសរបស់ខ្លួនយ៉ាងពិតប្រាកដ”*។ មនុស្សមិនមែនជាឧបករ ឬមធ្យោបាយ ដែលព្រះជាម្ចាស់ប្រើប្រាស់ទេ ប៉ុន្តែពួកគេជាអ្នកនិពន្ធ *“ពិតប្រាកដ”* ដែលមានសេរីភាពពេញលេញ។ ព្រះជាម្ចាស់មានសកម្មភាព *“ក្នុងអ្នកទាំងនោះ និងដោយសារអ្នកទាំងនោះ” (សូមអានហប ១,២)* ដូចព្រះបិតាមានសកម្មភាព *“ក្នុងអង្គព្រះបុត្រា និងដោយសារព្រះបុត្រា”* ដែរ បានសេចក្ដីថា ព្រះវិញ្ញាណដ៏វិសុទ្ធជួយបំភ្លឺអ្នកនិពន្ធទាំងអស់នោះ ដោយគោរពសេរីភាពរបស់ពួកគេឲ្យបានពេញលេញ។

## ២.១.៣) តើព្រះគម្ពីរនិយាយអំពីសេចក្ដីពិតឬ?

បើព្រះវិញ្ញាណដ៏វិសុទ្ធជួយបំភ្លឺអ្នកនិពន្ធ ហេតុអ្វីបានជាមានពេលខ្លះ ព្រះគម្ពីរខុសនឹងវិទ្យាសាស្ត្រ (ឧ. កណ ១-៣)? ចំពោះសន្តៈអូគូស្ទីន និងសន្តៈថូម៉ាស អាគីណាស ព្រះគម្ពីរមិនបង្រៀនសេចក្ដីពិតបែបវិទ្យាសាស្ត្រទេ ប៉ុន្តែព្រះគម្ពីរបង្រៀនសេចក្ដីពិតដ៏ចាំបាច់ដើម្បីទទួលការសង្គ្រោះ។ លោកកាលីលេ (Galilée) ធ្លាប់ពន្យល់ថា ព្រះគម្ពីរមិនបង្រៀនយើងឲ្យយល់ថា អ្វីទៅជាស្ថានលើ ប៉ុន្តែព្រះគម្ពីរបង្រៀនយើងឲ្យយល់ថា តើយើងត្រូវធ្វើដូចម្ដេច ដើម្បីឡើងទៅស្ថានលើវិញ។ តាមមហាសន្និបាតវ៉ាទីកង់ទីពីរ៖ *“ហេតុនេះហើយ បានជាត្រូវរាប់សេចក្ដីទាំងអស់ដែលអ្នកនិពន្ធ និងអ្នកតំណាលរឿងនិទានបានកត់ត្រានោះ ទុកជាសេចក្ដីដែលព្រះវិញ្ញាណបានបញ្ជាក់ ព្រោះព្រះវិញ្ញាណបានបំភ្លឺចិត្តគំនិតអ្នកនិពន្ធ។ យើងក៏ត្រូវតែប្រកាសថា ក្នុងក័ណ្ឌគម្ពីរមានបង្រៀនយ៉ាងប្រាកដប្រជាយ៉ាងត្រឹមត្រូវ ដោយគ្មានកំហុសនូវសេចក្ដីពិតដែលព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យគេកត់ត្រាទុកជាលាយលក្ខណ៍អក្សរ ក្នុងព្រះគម្ពីរសម្រាប់សង្គ្រោះយើង”* (DV១១)។

## ២.១.៤) តើត្រូវធ្វើដូចម្ដេច ដើម្បីបកស្រាយព្រះគម្ពីរយ៉ាងត្រឹមត្រូវ?

ដោយសារមនុស្សជាអ្នកនិពន្ធព្រះគម្ពីរមហាសន្និបាត ពន្យល់អំពីរបៀបបកស្រាយព្រះគម្ពីរ ដែលជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។

*“ក្នុងព្រះគម្ពីរព្រះជាម្ចាស់ពិតជាមានព្រះបន្ទូលតាមរយៈមនុស្ស និងបានប្រើពាក្យសម្ដីរបស់មនុស្ស។ ហេតុនេះ អ្នកបកស្រាយព្រះគម្ពីរត្រូវស្វែងរកដោយពិនិត្យពិច័យ នូវសេចក្ដីដែលអ្នកនិពន្ធទាំងនោះមានបំណងនិយាយប្រាប់ និងសេចក្ដីដែលព្រះជាម្ចាស់សព្វព្រះហឫទ័យសម្ដែងតាមរយៈពាក្យរបស់គេ”* (DV ១២)។

ដើម្បីបកស្រាយព្រះគម្ពីរយ៉ាងត្រឹមត្រូវ មហាសន្និបាតរំលឹកថា ត្រូវចាប់អារម្មណ៍អំពីរបៀបសរសេរអត្ថបទព្រះគម្ពីរ គឺត្រូវចាប់អារម្មណ៍អំពីវប្បធម៌ និងគោលដៅរបស់អ្នកនិពន្ធ។ អត្ថបទខាងប្រវត្តិសាស្ត្រប្លែកពីរឿង

ប្រឌិត ឬពីពាក្យកំណាព្យ។ ម៉្យាងទៀត មនុស្សមានកំណត់ព្រំដែន ធ្វើឲ្យព្រះជាម្ចាស់សម្របព្រះបន្ទូលព្រះអង្គតាមលក្ខណៈរបស់មនុស្ស៖ *“ហេតុនេះ ទោះបីយើងត្រូវតែគោរពសេចក្ដីពិត និងលក្ខណៈដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ជានិច្ចក្ដី ក៏ក្នុងព្រះគម្ពីរ ព្រះអង្គសម្ដែងព្រះហឫទ័យមេត្តាករុណាយ៉ាងអស្ចារ្យនៃព្រះប្រាជ្ញាញាណ ដែលស្ថិតនៅអស់កល្បជានិច្ច “ដើម្បីឲ្យយើងស្គាល់ព្រះហឫទ័យសប្បុរសរបស់ព្រះជាម្ចាស់ដែលរកថ្លែងពុំបាន និងដឹងថាព្រះអង្គមានព្រះបន្ទូលស្របតាម របៀបមនុស្សយើងនិយាយ ព្រោះព្រះអង្គណែនាំនិងថែទាំមនុស្សជាតិយើងជាមុន”*( DV ១៣ )។

ម៉្យាងទៀត ត្រូវតែបកស្រាយព្រះគម្ពីរតាមការបញ្ជូនបន្តដ៏រស់រវើកនៃព្រះសហគមន៍ គឺសម្រាប់អ្នកជឿ អត្ថបទព្រះគម្ពីរទាំងអស់នោះ មិនមែនជាអត្ថបទខាងវិទ្យាសាស្ត្រទេ ប៉ុន្តែអត្ថបទនោះសម្ដែងអំពីជំនឿ និងបទពិសោធន៍របស់អ្នកនិពន្ធ រួមជាមួយសហគមន៍ដែលចែករំលែកអំពីទំនាក់ទំនងរបស់គេជាមួយនឹងព្រះជាម្ចាស់។

ទីបញ្ចប់ ព្រះយេស៊ូគ្រីស្តជាគន្លឹះជួយបកស្រាយព្រះគម្ពីរ *( លក ២៤,២៧ ; កក ៨,២៦ )*។ ព្រះគ្រីស្តដែលមានព្រះជន្មថ្មីដ៏រុងរឿងបំពេញអត្ថន័យនៃព្រះគម្ពីរទាំងមូល។

## ២.២ ) ក្រុមមេដឹកនាំព្រះសហគមន៍ និងប្រជារាស្ត្រព្រះជាម្ចាស់

***អ្វីទៅជាក្រុមមេដឹកនាំ? តើក្រុមមេដឹកនាំមានមុខងារអ្វី?***

= ក្រុមមេដឹកនាំចុះក្រោមអំណាចព្រះបន្ទូលព្រះជាម្ចាស់ ហើយរួមជាមួយប្រជារាស្ត្រព្រះអង្គក្នុងការបកស្រាយព្រះគម្ពីរយ៉ាងត្រឹមត្រូវ[16]៖

តាមអត្ថន័យដើម ពាក្យ *“មេដឹកនាំ”* គឺព្រះវិញ្ញាណដ៏វិសុទ្ធតែម្ដង ដែលជួយឧបត្ថម្ភព្រះសហគមន៍ក្នុងការធ្វើដំណើរក្នុងលោកនេះ។ ដោយសារក្រុមប្រូតេស្តង់នៅសតវត្សទី ១៦ ពាក្យ *“មេដឹកនាំ”*នោះ ទទួលអត្ថន័យថ្មីហួតដល់មហាសន្និបាតវ៉ាទីកង់ទីមួយ ដែលនិយាយថា មានតែក្រុមមេដឹកនាំព្រះសហគមន៍ទេ *(គឺអស់ពួកគង្វាល)* ដែលអាចបកស្រាយព្រះគម្ពីរយ៉ាងពិតប្រាកដ ស្របតាមការបញ្ជូនបន្ត ដោយមិនភ័ន្តច្រឡំបានឡើយ។

មហាសន្និបាតវ៉ាទីកង់ទីពីរបានកែតម្រង់អត្ថន័យនេះ ដោយពន្យល់ថា ក្រុមមេដឹកនាំមិនស្ថិតនៅលើព្រះបន្ទូលព្រះជាម្ចាស់ទេ ប៉ុន្តែក្រុមមេដឹកនាំមានមុខងារបម្រើប្រជារាស្ត្រព្រះជាម្ចាស់វិញ៖ *“ការបញ្ជូនបន្តដ៏វិសុទ្ធ និងព្រះគម្ពីរជាបញ្ញើដ៏សក្ការៈតែមួយនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលផ្ញើទុកឲ្យព្រះសហគមន៍...ព្រះជាម្ចាស់បានផ្ញើបន្ទុកបកស្រាយព្រះបន្ទូលរបស់ព្រះអង្គយ៉ាងពិតប្រាកដ ទោះបីជាព្រះបន្ទូលកត់ត្រាទុកជាលាយលក្ខណ៍អក្សរក្ដី ឬបញ្ជូនបន្តមកក្ដី ឲ្យការណែនាំដែលមានជីវិតក្នុងព្រះសហគមន៍ អាចបកស្រាយបាន។ មានតែការណែនាំនោះប៉ុណ្ណោះ ដែលមានអំណាចបកស្រាយក្នុងព្រះនាមព្រះយេស៊ូគ្រីស្ត។ ប៉ុន្តែការណែនាំនេះគ្មានអំណាចលើសពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ទេ តែបម្រើព្រះបន្ទូលទៅវិញ។ ការណែនាំក៏បង្រៀនតែសេចក្ដីដែលគេបានទទួលតមក...”* (DV ១០)។

---

16 កាលពីមុន គេធ្លាប់អះអាងថា មានតែក្រុមមេដឹកនាំប៉ុណ្ណោះ ដែលអាចបកស្រាយព្រះគម្ពីរ។

*"ហេតុនេះហើយ បានជាអស់គង្វាលនិងអស់អ្នកជឿ រួមគ្នាជាចិត្តគំនិតតែមួយយ៉ាងស្អិតរមួតក្នុងកិច្ចរក្សាជំនឿ ដែលគេបានទទួលក្នុងកិច្ចប្រតិបត្តិតាមជំនឿ និងក្នុងការប្រកាសជំនឿដែលគេទទួលតមក"* (DV ១០)។ ដូច្នេះហើយបានជាយើងអាចយល់ឃើញថា ទាំងប្រជារាស្ត្រព្រះជាម្ចាស់ផង ទាំងក្រុមមេដឹកនាំព្រះសហគមន៍ផង ស្ថិតនៅក្រោមអំណាចនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ក្រុមមេដឹកនាំ ដោយរួមជាមួយប្រជារាស្ត្រគ្រាន់តែមានមុខងារបកស្រាយព្រះគម្ពីរប៉ុណ្ណោះ។

ក្រុមប្រូតេស្តង់ដែលធ្លាប់និយាយថា Sola scriptura (មានតែព្រះគម្ពីរ) ចង់សង្កត់ធ្ងន់ថាព្រះគម្ពីរសំខាន់ជាងគេជាទីបំផុត ប៉ុន្តែគេទទួលស្គាល់ថា ត្រូវតែមានក្រុមជួយបកស្រាយព្រះគម្ពីរ កុំឲ្យនរណាម្នាក់បកស្រាយព្រះគម្ពីរតាមចិត្តរៀងៗខ្លួន។ នេះគឺជាមុខងាររបស់ទេវិទូប្រូតេស្តង់។ ឯព្រះសហគមន៍កាតូលិកវិញ ចង់បញ្ជាក់ថា ព្រះគម្ពីរប្រជារាស្ត្រព្រះជាម្ចាស់ និងក្រុមមេដឹកនាំរួមជាមួយគ្នា ក្នុងការបកស្រាយជំនឿយ៉ាងត្រឹមត្រូវ។ ក្រុមដឹកនាំ គ្រាន់តែជាអ្នកបម្រើប្រជារាស្ត្រព្រះជាម្ចាស់ ដើម្បីឲ្យប្រជារាស្ត្រនេះរួមគ្នាជាធ្លុងតែមួយ ដោយមានជំនឿតែមួយ និងស្របតាមការប្រៀនប្រដៅរបស់ក្រុមគ្រីស្តទូត៖ ក្រុមមេដឹកនាំមានមុខងារបម្រើសេចក្តីពិត និងឯកភាពដោយរួមជាមួយប្រជារាស្ត្រព្រះជាម្ចាស់។

ម្យ៉ាងវិញទៀត លោកលូថែរ៍ ធ្លាប់អះអាងថា មានតែប្រជារាស្ត្រព្រះជាម្ចាស់ប៉ុណ្ណោះទេ ដែលអាចបកស្រាយព្រះគម្ពីរយ៉ាងត្រឹមត្រូវ។ នៅសម័យនោះ លោក លូថែរ៍ ប្រឆាំងនឹងក្រុមមេដឹកនាំព្រះសហគមន៍ ដែលទាមទារឲ្យមានអំណាចគ្រប់យ៉ាង។ លោកសំអាងលើអត្ថបទព្រះគម្ពីរខ្លះ ដូចជា យហ ១០,៤ មថ ៧,១៤ ១ ថស ៥,២១ មថ ២៤,៤ ជាដើម ដើម្បីបញ្ជាក់ថា គ្រីស្តបរិស័ទធម្មតាមិនអាចភ័ន្តច្រឡំបានទេ ក្នុងការបកស្រាយព្រះគម្ពីរតាមជំនឿត្រឹមត្រូវ ដែលមកពីក្រុមគ្រីស្តទូត។ តាមមហាសន្និបាតវ៉ាទីកង់ទីពីរ ទាំងសម្តេចប៉ាបទាំងក្រុមអភិបាលទាំងប្រជារាស្ត្រព្រះជាម្ចាស់ *"មិនអាចវង្វេងជំនឿបានឡើយ"*(LG១២;២៥) ប៉ុន្តែត្រូវតែព្យាយាមរួមគ្នាក្នុងការស្វែងរកសេចក្តីពិត ទោះបីជាមានពេលខ្លះ ក្រុមមេដឹកនាំ និងគ្រីស្តបរិស័ទធម្មតាពិបាកឯកភាពយ៉ាងណាក៏ដោយ (សូមរិះគិតអំពីលិខិតរបស់សម្តេចប៉ាបប៉ូលទី ៦ Humanae vitae ១៩៦៨ ដែលគ្រីស្តបរិស័ទភាគច្រើន មិនព្រមទទួល)។

## ២.៣) ព្រះបន្ទូលព្រះជាម្ចាស់ជ្រាបចូលក្នុងប្រវត្តិសាស្ត្រមនុស្សលោក

ក្នុង Fides et ratio (ជំនឿ និងប្រាជ្ញា) សម្តេចយូហានប៉ូលទី ២ សរសេរថា យើងអាចយល់ឃើញថា ព្រះជាម្ចាស់ប្រព្រឹត្តកិច្ចការសម្រាប់មនុស្សលោកក្នុងប្រវត្តិសាស្ត្រ។ ព្រះជាម្ចាស់មិនគ្រាន់តែមានព្រះបន្ទូលក្នុងប្រវត្តិសាស្ត្រទេ ថែមទាំងព្រះអង្គមានព្រះបន្ទូលតាមរយៈប្រវត្តិសាស្ត្រដែរ។ តាម មថ ១៦,៣ មហាសន្និបាតប្រើពាក្យសម្តី *"ទីសម្គាល់នៃសម័យនេះ"* ក្នុងធម្មនុញ្ញណែនាំអំពីព្រះសហគមន៍ក្នុងពិភពលោកនាបច្ចុប្បន្នកាល Gaudium et spes (អំណរ និងសេចក្តីសង្ឃឹម) លេខ៤ ដើម្បីបញ្ជាក់ថា ព្រះវិញ្ញាណដ៏វិសុទ្ធធ្វើការក្នុងប្រវត្តិសាស្ត្រមនុស្សលោក៖ *"ព្រះសហគមន៍មានភារកិច្ចពិនិត្យមើលសញ្ញាសម្គាល់នៃពេលវេលាជានិច្ច និងបកស្រាយអត្ថន័យនៃសញ្ញាសម្គាល់ទាំងនោះ តាមពន្លឺនៃដំណឹងល្អរបស់ព្រះគ្រីស្ត ដើម្បីអាចបំពេញមុខងារនេះបាន។ ធ្វើដូច្នេះ ព្រះសហគមន៍អាចតបឆ្លើយនឹងសំណួរ ដែលមនុស្សចេះតែចោទជានិច្ចជាកាលឲ្យបានស្រប*

*នឹងជំនាន់នីមួយៗ...”*។

ព្រះជាម្ចាស់ប្រោសប្រទានទីសម្គាល់ខ្លះ ក្នុងប្រវត្តិសាស្ត្រមនុស្សលោក ដែលព្រះសហគមន៍ត្រូវបកស្រាយក្រោមពន្លឺនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់៖ *“ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ខិតខំពិនិត្យមើលព្រឹត្តិការណ៍ ដើម្បីរកឃើញនូវអ្វីៗដែលមនុស្សសម័យឥឡូវទាមទារ និងចង់បានជាចំបាច់ ព្រមទាំងរកឃើញអ្វីៗ ដែលជាសញ្ញាសម្គាល់ដ៏ពិតប្រាកដអំពីវត្តមានរបស់ព្រះជាម្ចាស់ និងអំពីគម្រោងការព្រះអង្គផង... មុនដំបូងមហាសន្និបាតមានបំណងចង់យកជំនឿនេះ មករិះគិតពិចារណាអំពីអ្វីៗ ដែលមនុស្សសម័យឥឡូវយល់ឃើញថា មានតម្លៃថ្លៃជាងគេ និងភ្ជាប់អ្វីៗ ដែលមានតម្លៃជាងគេទាំងនោះទៅនឹងព្រះជាម្ចាស់ជាប្រភព។ ដោយអ្វីៗដែលមនុស្សសម័យឥឡូវយល់ឃើញថា មានតម្លៃហូរចេញពីប្រាជ្ញាញាណរបស់មនុស្ស គឺអ្វីៗទាំងនោះពិតជាល្អណាស់ ព្រោះជាព្រះអំណោយទានរបស់ព្រះជាម្ចាស់។ ក៏ប៉ុន្តែដោយសារកិលេសតណ្ហា មនុស្សបង្វែរអ្វីៗដ៏ល្អដែលមានតម្លៃទាំងនោះ ឆ្ងាយពីរបៀបរៀបរយដែលព្រះជាម្ចាស់រៀបចំទុក។ ហេតុនេះហើយ ត្រូវជម្រះអ្វីៗទាំងនោះជាចាំបាច់”* (GS ១១)។

## សេចក្តីបញ្ចប់៖

ដោយសារព្រះយេស៊ូគ្រីស្ត ព្រះជាម្ចាស់បានសម្តែងព្រះអង្គក្នុងប្រវត្តិសាស្ត្រមនុស្សលោក។ ព្រះជាម្ចាស់បានសម្តែងអ្វីទាំងអស់ និងជាស្ថាពរគ្មានអ្វីត្រូវតែសម្តែងសាជាថ្មីឡើយ។ ប៉ុន្តែដោយសារព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុត មនុស្សលោកតែងតែត្រូវស្វែងរកព្រះអង្គជានិច្ច និងចូលក្នុងអាថ៌កំបាំងព្រះអង្គកាន់តែជ្រៅទៅៗ គឺយើងមិនដែលស្គាល់ព្រះជាម្ចាស់ឲ្យបានពេញលក្ខណៈ។ ក្នុងការស្វែងរកសេចក្តីពិតគ្រប់ជំពូកនេះ ព្រះវិញ្ញាណដ៏វិសុទ្ធជួយបំភ្លឺព្រះសហគមន៍ គឺការបញ្ជូនបន្តព្រះគម្ពីរ ក្រុមមេដឹកនាំត្រូវតែរួមគ្នា (ដូចព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ រួមជាមួយគ្នាដែរ) ដើម្បីបានជំនឿត្រឹមត្រូវដោយយល់ថា ការទាំងបីនោះ ចុះក្រោមអំណាចនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់។

## សំណួរ៖

១) ហេតុអ្វីបានជាសម្រាប់ព្រះសហគមន៍កាតូលិក ការបញ្ជូនបន្តព្រះសហគមន៍មិនអាចបែកចេញពីព្រះគម្ពីរបានឡើយ?

២) នរណាជាអ្នកនិពន្ធព្រះគម្ពីរ? បើព្រះជាម្ចាស់ជាអ្នកនិពន្ធ ហេតុអ្វីបានជាមានពេលខ្លះ ព្រះគម្ពីរខុសខាងវិទ្យាសាស្ត្រ?

៣) តើត្រូវធ្វើដូចម្តេច ដើម្បីបកស្រាយព្រះគម្ពីរឲ្យបានត្រឹមត្រូវ? នរណាអាចបកស្រាយព្រះគម្ពីរឲ្យបានត្រឹមត្រូវ? ហេតុអ្វី?

៤) តើក្រុមមេដឹកនាំ ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ការបញ្ជូនបន្ត និងព្រះគម្ពីររួមជាមួយគ្នាយ៉ាងដូចម្តេចក្នុងការស្វែងរកសេចក្តីពិត?

៥) ក្នុងប្រវត្តិសាស្ត្រ (ជាពិសេសនៅស្រុកខ្មែរ) តើមានទីសម្គាល់អ្វីខ្លះ បង្ហាញបញ្ជាក់ថា ព្រះវិញ្ញាណដ៏វិសុទ្ធណែនាំមនុស្សលោក? សូមលើកឧទាហរណ៍ណាមួយ។

# ជំពូកទី ៧
# មនុស្សឆ្លើយតបនឹងព្រះជាម្ចាស់៖ អ្វីទៅជាជំនឿ?

****

អ្វីទៅជាជំនឿ? យើងបានយល់ឃើញថា នៅពេលដែលព្រះជាម្ចាស់សម្តែងព្រះអង្គឲ្យមនុស្សលោកស្គាល់ គេត្រូវតែសម្រេចចិត្តថាតើគេយល់ព្រមដើរតាមព្រះអង្គឬទេ? ជំនឿជាចម្លើយរបស់មនុស្សចំពោះព្រះជាម្ចាស់។ ព្រះបន្ទូលព្រះជាម្ចាស់ជំរុញមនុស្សឲ្យសម្រេចចិត្តផ្ញើជីវិតទៅលើព្រះអង្គឬទេ។

ដើម្បីនិយាយអំពីជំនឿ ព្រះគម្ពីរប្រើពាក្យ Aman គឺ *"ភ្ជាប់ចិត្តនឹង" "ផ្ញើជីវិតទាំងស្រុង" (អស ៧,៩)* batach, hasah ៖ ពឹងផ្អែកយកជាទីពឹងទុកចិត្ត...ក្នុងសម្ព័ន្ធមេត្រីថ្មី សន្តៈប៉ូលប្រើពាក្យ Pistis *(កាឡ ១,២៣; ២,១៦)* សំដៅទៅលើអ្វីដែលត្រឹមត្រូវពិតប្រាកដ (Amen ) - យហ ២,២២ ; ៨,៤៥។

## ១) មូលហេតុផ្សេងៗ ដែលនាំមនុស្សឲ្យមានជំនឿ

ហេតុអ្វីបានជាយើងជឿ? យើងជឿមកពីមូលហេតុអ្វីខ្លះ? លោកនីកូឡាស ដូណាស (Nicolas Dunas) បានរៀបចំមូលហេតុផ្សេងៗ ដែលនាំឲ្យមនុស្សមានជំនឿដូចតទៅ៖

- ១ ការមើលឃើញសកម្មភាព និងទង្វើរបស់អ្នកជឿ ជាពិសេសរបស់ព្រះសហគមន៍
- ១ ការអស្ចារ្យផ្សេងៗដូចជាការប្រោសអ្នកជំងឺឲ្យបានជា ជាដើម
- ១ មរណសាក្សី គឺគ្រីស្តបរិស័ទ ដែលបូជាជីវិតដោយសារជំនឿ
- ១ លទ្ធិនៃគ្រីស្តសាសនា ដែលមានហេតុផលច្បាស់លាស់ និងស្របតាមសេចក្តីពិត
- ១ ការបំពេញតម្រូវការ សេចក្តីសង្ឃឹម និងការរង់ចាំរបស់មនុស្ស

ប៉ុន្តែត្រូវតែទទួលស្គាល់ថា មូលហេតុទាំងអស់នោះ មិនអាចបង្ហាញភស្តុតាងអំពីព្រះជាម្ចាស់ឡើយ៖ ឧ.មរណសាក្សីផ្តល់សក្ខីភាពអំពីជំនឿរបស់ខ្លួន ប៉ុន្តែតើជំនឿនេះ ពិតជាត្រឹមត្រូវឬទេ? ទោះបីមរណសាក្សីបូជាជីវិតយ៉ាងណាក៏ដោយ ក៏ពួកគាត់អាចភ័ន្តច្រឡំបានដែរ! ឧ. អំពីការអស្ចារ្យ៖ សូមអានយហ ៩៖ ទោះបីព្រះយេស៊ូប្រោសមនុស្សខ្វាក់តាំងពីកំណើតឲ្យភ្លឺយ៉ាងណាក៏ដោយ ក៏ពួកផារីស៊ីមិនព្រមជឿទាល់តែសោះ។ ការអស្ចារ្យទាំងប៉ុន្មាន ដែលព្រះយេស៊ូប្រព្រឹត្តបំភ្លឺអ្នកខ្លះ ធ្វើឲ្យអ្នកផ្សេងបានទៅជាមនុស្សខ្វាក់វិញ។ ដូច្នេះហើយ បានជាមូលហេតុផ្សេងៗ ដែលនាំមនុស្សឲ្យមានជំនឿ គ្រាន់តែជាសញ្ញាសម្គាល់ផ្សេងៗ ដើម្បីជួយពង្រឹងជំនឿរបស់អស់អ្នកដែលមានជំនឿរួចហើយ!

## ២) ការវិវត្តន៍ពីមហាសន្និបាតវ៉ាទីកង់ទី១ដល់មហាសន្និបាតវ៉ាទីកង់ទី២

តាមលិខិត Dei Filius របស់មហាសន្និបាតវ៉ាទីកង់ទី១ *"ដោយសារជំនឿ យើងចាំបាច់ត្រូវតែយកប្រាជ្ញា និងបំណងទាំងស្រុងរបស់ខ្លួន មកគោរពប្រណិប័តន៍ព្រះជាម្ចាស់ដែលសម្ដែងព្រះអង្គ។ ជំនឿនេះ ជាគុណធម៌ហួសធម្មជាតិ ដែលព្រះជាម្ចាស់បានប្រោសប្រណីឲ្យយើងជឿជាក់នឹងសេចក្ដីផ្សេងៗ ដែលព្រះអង្គបានសម្ដែងឲ្យយើងស្គាល់។ យើងជឿជាក់សេចក្ដីទាំងអស់នោះ មិនមែនមកពីពន្លឺនៃប្រាជ្ញាទេ ប៉ុន្តែមកពីអំណាចរបស់ព្រះជាម្ចាស់ដែលទ្រង់មិនអាច និងពុំមានព្រះហឫទ័យឲ្យយើងច្រឡំបានឡើយ (...)។ ទោះជាយ៉ាងណាក៏ដោយ ក៏ដើម្បីឲ្យជំនឿយើងស្របតាមប្រាជ្ញា ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យការអស្ចារ្យផ្សេងៗ និងព្យាការណ៍ផ្សេងៗ ជួយកំដរពន្លឺពីខាងក្នុងនៃព្រះវិញ្ញាណដ៏វិសុទ្ធ (...)។ ការអស្ចារ្យទាំងអស់នោះ ដែលបង្ហាញឫទ្ធានុភាព និងព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ ដែលគ្មានកំណត់ព្រំដែន ពិតជាទីសម្គាល់ច្បាស់លាស់នៃការសម្ដែង ស្របតាមប្រាជ្ញារបស់មនុស្សទាំងអស់។ ហេតុនេះហើយ បានជាលោកម៉ូសេ ពួកព្យាការី ជាពិសេសព្រះគ្រីស្ដជាអម្ចាស់នៃយើងបានប្រព្រឹត្តការអស្ចារ្យជាច្រើន និងបានព្យាករផងដែរ (...)។ គ្មាននរណាម្នាក់អាចជឿ ដោយគ្មានការបំភ្លឺនៃព្រះវិញ្ញាណដ៏វិសុទ្ធ ដែលប្រោសប្រទានឲ្យមនុស្សទាំងអស់ជាប់ និងជឿជាក់នឹងសេចក្ដីពិត។ ហេតុនេះហើយបានជាជំនឿជួយសង្គ្រោះ មនុស្សដោយគោរពប្រណិប័តន៍ព្រះជាម្ចាស់ និងរួមសហការជាមួយនឹងព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ (...)។ មានតែក្នុងព្រះសហគមន៍កាតូលិកប៉ុណ្ណោះទេ ដែលព្រះជាម្ចាស់បានសម្ដែងទីសម្គាល់ទាំងប៉ុន្មាន ដើម្បីជួយឲ្យយល់ថា ជំនឿគ្រីស្ដសាសនាពិតជាពិតប្រាកដមែន។ លើសពីនេះទៅទៀត ដោយសារព្រះសហគមន៍កាតូលិកពិតជាវិសុទ្ធបង្កើតផលល្អៗ និងរួមឯកភាពជាធ្លុងតែមួយព្រះសហគមន៍កាតូលិកនេះជាហេតុផ្ទាល់ដ៏ប្រសើរ និងជានិច្ចនិរន្តរ៍ផ្ដល់សក្ខីភាពថាត្រូវតែជឿ"*។

ឯតាមលិខិត Dei Verbum របស់មហាសន្និបាតវ៉ាទីកង់ទី២វិញ៖ *"ហេតុនេះ អ្នកដែលឃើញព្រះគ្រីស្ដក៏ឃើញព្រះបិតាដែរ (យហ ១៤,៩)។ ពេលព្រះយេស៊ូរស់នៅជាមួយមនុស្សលោក ទ្រង់បង្ហាញព្រះអង្គផ្ទាល់តាមព្រះបន្ទូល និងតាមកិច្ចការ តាមទីសម្គាល់ និងតាមការអស្ចារ្យ ហើយជាពិសេសដោយទ្រង់សោយទិវង្គត ហើយក្រោកឡើងពីចំណោមមនុស្សស្លាប់ និងមានព្រះជន្មថ្មីដ៏រុងរឿង។ នៅទីបញ្ចប់ ទ្រង់ចាត់ព្រះវិញ្ញាណនៃសេចក្ដីពិត។ ដោយព្រះគ្រីស្ដប្រព្រឹត្តកិច្ចការទាំងនោះ ព្រះអង្គបង្ហើយនិងបង្គ្រប់សេចក្ដីដែលព្រះជាម្ចាស់បានសម្ដែងអំពីព្រះអង្គផ្ទាល់ ព្រះគ្រីស្ដក៏បញ្ជាក់ពីការសម្ដែងព្រះជាម្ចាស់នេះដែរ (...) មនុស្សយើងត្រូវតែ «គោរពប្រណិប័តន៍ព្រះជាម្ចាស់ ដោយធ្វើជីវិតលើព្រះអង្គ» ដែលសម្ដែងព្រះអង្គ (រម ១៦, ២៦ ; រម ១, ៥; ២ករ ១០, ៥-៦)។ ដោយសារជំនឿ មនុស្សធ្វើជីវិតទាំងស្រុង និងដោយសេរីទៅលើព្រះជាម្ចាស់ គឺគេ «យកប្រាជ្ញា និងបំណងទាំងស្រុងរបស់ខ្លួន មកគោរពប្រណិប័តន៍ព្រះជាម្ចាស់ដែលសម្ដែងព្រះអង្គ» (វ៉ាទីកង់ទី១)។ អ្នកជឿក៏សម្រេចចិត្តទទួលសេចក្ដីដែលព្រះអង្គសម្ដែងនោះថែមទៀតផង។ ព្រះជាម្ចាស់ត្រូវតែប្រណីសន្ដោសគេ ជួយបំភ្លឺចិត្តមនុស្សជាមុនសិន ទើបគេអាចធ្វើជីវិតលើព្រះអង្គបាន ព្រមទាំងដឹងថា ព្រះវិញ្ញាណដ៏វិសុទ្ធជួយគេពីខាងក្នុង គឺព្រះវិញ្ញាណប្រោសឲ្យគេរំភើបចិត្ត និងប្រែចិត្តគេទៅរកព្រះជាម្ចាស់ ព្រះវិញ្ញាណក៏បើកភ្នែកនៃវិញ្ញាណរបស់គេ និងប្រទានឲ្យ "អស់អ្នកជឿមានចិត្តកក់ក្ដៅ ដោយយល់ស្រប និងសុខចិត្តជឿសេចក្ដីពិត»។ ព្រះវិញ្ញាណដ៏វិសុទ្ធ នៅតែប្រោសឲ្យជំនឿនេះបានកាន់តែប្រសើរឡើងៗ ដោយព្រះអង្គប្រទានព្រះអំណោយទានផ្សេងៗ ដើម្បីឲ្យគេយល់កាន់តែជ្រៅនូវសេចក្ដីដែលព្រះជាម្ចាស់បានសម្ដែងមកនោះ"*។

ដោយប្រៀបធៀបអត្ថបទទាំងពីរនោះ យើងអាចយល់ឃើញថា អត្ថបទទាំងពីរស្រដៀងគ្នា៖ ក្នុងករណីទាំងពីរ *"ព្រះវិញ្ញាណដ៏វិសុទ្ធដែលជួយបំភ្លឺពីខាងក្នុង"*។ ប៉ុន្តែអត្ថបទទាំងពីរប្លែកពីគ្នាអំពីមូលហេតុផ្សេងៗ ដែលនាំមនុស្សឲ្យមានជំនឿ៖

សម្រាប់វ៉ាទីកង់ទី ១ យើងជឿមកពីព្រះវិញ្ញាណដ៏វិសុទ្ធជួយបំភ្លឺពីខាងក្នុង និងដោយសារភាពអស្ចារ្យ និងការព្យាករផ្សេងៗ ហើយដោយសារព្រះសហគមន៍កាតូលិកទៀតផង។ ការទាំងអស់នោះ ជំរុញមនុស្សឲ្យមានជំនឿហើយជំនឿនេះ មកពីប្រាជ្ញាមកគោរពប្រណិប័តន៍ព្រះជាម្ចាស់ដែលមានអំណាច។ តាមការពិត វ៉ាទីកង់ទី១ សរសេរអត្ថបទនេះ ប្រឆាំងនឹងក្រុមប្រូតេស្តង់ និងពួកប្រាជ្ញានិយម។ សម្រាប់ពួកប្រូតេស្តង់ យើងជឿមកពីយើងម្នាក់ៗ មានបទពិសោធន៍ផ្ទាល់ខ្លួនអំពីព្រះវិញ្ញាណដ៏វិសុទ្ធ។ ប៉ុន្តែសម្រាប់ពួកអភិបាលនៅវ៉ាទីកង់ទី១ ក្រៅពីបទពិសោធន៍ផ្ទាល់ខ្លួននៃព្រះវិញ្ញាណដ៏វិសុទ្ធ មានមូលហេតុផ្សេងៗដែលនាំឲ្យមានជំនឿ ស្របតាមប្រាជ្ញារបស់មនុស្ស។ បើមិនដូច្នោះទេ មនុស្សអាចវង្វេងក្នុងជំនឿបាន។ ឯសម្រាប់ពួកប្រាជ្ញានិយមវិញ ពួកអភិបាលអះអាងថា ប្រាជ្ញាត្រូវតែចុះក្រោមអំណាចនៃព្រះហឫទ័យសន្តោសរបស់ព្រះជាម្ចាស់។ ជំនឿស្របតាមប្រាជ្ញា ប៉ុន្តែជំនឿលើសប្រាជ្ញា។

សម្រាប់វ៉ាទីកង់ទី២ មូលហេតុសំខាន់ៗដែលនាំមនុស្សឲ្យមានជំនឿ មិនមែនមកពីការអស្ចារ្យ និងការព្យាករផ្សេងៗទេ ប៉ុន្តែមកពីព្រះគ្រីស្ត ដែលបានសោយទិវង្គត និងមានព្រះជន្មថ្មី។ ជំនឿមកពីសេចក្តីពិតនៃហេតុការណ៍នេះ ដោយមានព្រះវិញ្ញាណជួយបំភ្លឺពីខាងក្នុង មិនចាំបាច់បន្ថែមមូលហេតុផ្សេងៗទេ។ តាមការពិតនៅសម័យវ៉ាទីកង់ទី ២ មនុស្សភាគច្រើនមិនរវីរវល់នឹងជំនឿ ឬព្រះជាម្ចាស់ទេ។ ហេតុនេះហើយបានជាពួកលោកអភិបាលចង់បង្ហាញថា យើងជឿមិនមែនមកពីមូលហេតុផ្សេងៗ ដែលមិនអាចទាក់ទាញចិត្តមនុស្សទេ យើងជឿមកពីព្រះគ្រីស្តសម្តែងព្រះអង្គ។ ពួកលោកចង់បញ្ជាក់ថា យើងជឿមកពីយើងម្នាក់ៗទទួលព្រះអំណោយទាននៃការសម្តែង មិនមែនមកពីអំណាចរបស់ព្រះជាម្ចាស់ ឬសក្ខីភាពរបស់ព្រះសហគមន៍ទេ *(តាម យហ ៤ ជនជាតិសាម៉ារីជឿ មិនមែនមកពីស្ត្រីសាម៉ារី (តំណាងព្រះសហគមន៍)* បានប្រកាសថា ព្រះយេស៊ូជាព្រះមេស្ស៊ី តែមកពីគេបានជួបព្រះគ្រីស្តផ្ទាល់)។

## ៣) ជំនឿមកពីសេរីភាពមនុស្សផង និងពីព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ផង

យើងទើបយល់ឃើញថា មូលហេតុផ្សេងៗ ដែលនាំមនុស្សឲ្យមានជំនឿ ដូចជាការអស្ចារ្យ ឬការព្យាករផ្សេងៗ អំណាចរបស់ព្រះជាម្ចាស់ ឬសក្ខីភាពរបស់ព្រះសហគមន៍ អាចរារាំងមិនឲ្យជឿបានឡើយ គឺមនុស្សសម្រេចចិត្តផ្ញើជីវិតទាំងស្រុងទៅលើព្រះជាម្ចាស់ តាមព្រះវិញ្ញាណដ៏វិសុទ្ធជួយបំភ្លឺគេពីខាងក្នុង *"ក្នុងទីស្ងាត់កំបាំងនៃជម្រៅចិត្តមនុស្ស"*។ និយាយអំពី រម ១០,១៦ សន្តៈថូម៉ាស អាគីណាស បង្ហាញថា ទោះបីមានគេប្រកាសដំណឹងល្អយ៉ាងណាក៏ដោយក៏មានមនុស្សមួយចំនួនមិនព្រមជឿដែរ។ គ្រីស្តទូតប៉ូលសរសេរ រម ១០,១៦ ដូច្នេះដើម្បីបង្ហាញថា បើមនុស្សមិនបើកចិត្តឲ្យទូលាយ ការប្រកាសដំណឹងល្អនេះ (ទោះជាអស្ចារ្យក្តី) មិនគ្រប់គ្រាន់ ដើម្បីនាំមនុស្សឲ្យផ្ញើជីវិតទៅលើព្រះជាម្ចាស់ *(យហ ៦,៤៥)*។ ការបើកចិត្តឲ្យទូលាយនេះ មិនមែនមកពីមនុស្សទេ ប៉ុន្តែមកពីព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ ដែលគង់ក្នុងជម្រៅចិត្តមនុស្សទុក

ជាមុន។ ទោះជាយ៉ាងណាក៏ដោយ ក៏មនុស្សត្រូវតែចូលរួមយ៉ាងសកម្ម ក្នុងការទទួលព្រះអំណោយទាននៃជំនឿដែរ។ ជំនឿមកពីព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ផង មកពីមនុស្សស្ម័គ្រចិត្តផ្ញើជីវិតទៅលើព្រះអង្គផងដែរ។ ជំនឿជាកិច្ចការរបស់ព្រះជាម្ចាស់ផង ជាកិច្ចការរបស់មនុស្សផងដែរ។ មនុស្សត្រូវតែរួមសហការជាមួយព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ ដោយគ្មាននរណាម្នាក់បង្ខំ។

## *៣.១) ជំនឿមកពីព្រះជាម្ចាស់*

តាមវ៉ាទីកង់ទី២ ជំនឿជាកិច្ចការរបស់ព្រះជាម្ចាស់ ជាព្រះអំណោយទានរបស់ព្រះអង្គ (donum Dei ) ដែលមកពីព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះអង្គទុកជាមុន។ ពួកលោកអភិបាលនិយាយអំពី *"ព្រះវិញ្ញាណដ៏វិសុទ្ធជួយបំភ្លឺមនុស្សពីខាងក្នុង"*។ យើងអាចអាន ទន ៣៦,១០ *"យើងខ្ញុំមើលឃើញពន្លឺ ដោយសារពន្លឺរបស់ព្រះជាម្ចាស់"* ឬ មថ *១៦,១៧ ព្រះយេស៊ូមានព្រះបន្ទូលតបទៅគាត់វិញថា៖ «ស៊ីម៉ូនកូនលោកយ៉ូណាសអើយ អ្នកពិតជាមានសុភមង្គលមែន អ្នកដឹងសេចក្ដីនេះមិនមែនដោយខ្លួនឯងទេ គឺព្រះបិតារបស់ខ្ញុំដែលគង់នៅស្ថានបរមសុខបានសម្ដែងឲ្យអ្នកដឹង"* ឬ **យហ** ៦,៤៤ *"ប្រសិនបើព្រះបិតា ដែលចាត់ខ្ញុំឲ្យមក មិនទាក់ទាញចិត្តគេទេ គ្មាននរណាម្នាក់អាចមករកខ្ញុំបានឡើយ"*។ បើព្រះវិញ្ញាណដ៏វិសុទ្ធមិនប្រោសប្រទានឲ្យមនុស្សមានជំនឿទេ មនុស្សក៏ពុំអាចផ្ញើជីវិតទៅលើព្រះជាម្ចាស់បានឡើយ។

ចំពោះលោក ពេឡាគីយូស (Pelagius) ដែលអះអាងថា មនុស្សមានជំនឿមកពីខ្លួនឯង សន្តៈអូគូស្ទីនតែងតែឆ្លើយតបថា សូម្បីតែកំណើតនៃជំនឿក៏មកពីព្រះជាម្ចាស់ដែរ។ ឯសន្តៈថូម៉ាស អាគីណាសវិញ លោកអះអាងថា ព្រះជាម្ចាស់មិនគ្រាន់តែជាប្រភពនៃសេចក្ដីនៃជំនឿ ថែមទាំងព្រះអង្គជាប្រភពនៃកិច្ចការនៃជំនឿផ្ទាល់តែម្ដង ដ្បិតកិច្ចការនេះហួសសមត្ថភាពរបស់មនុស្ស។

## *តាមវ៉ាទីកង់ទី២ ព្រះវិញ្ញាណដ៏វិសុទ្ធ៖*

- **បើកជម្រៅចិត្តគំនិតរបស់មនុស្សបែរឆ្ពោះទៅរកព្រះជាម្ចាស់៖** កក ១៦,១៤; រម ១០,៩-១០។ តាមព្រះគម្ពីរចិត្តគំនិតស្មើនឹងប្រាជ្ញា៖ ១យហ ៥,២០ ; អស ១១,១៩ ; ៣៦,២៦ ; យរ ៣១,៣៣។ មនុស្សសម្រេចចិត្តជឿ ឬមិនជឿក្នុងទីជម្រៅចិត្តរបស់ខ្លួន ហើយគឺនៅទីនោះហើយ ដែលព្រះវិញ្ញាណដ៏វិសុទ្ធប្រព្រឹត្តកិច្ចការ។
- **ប្រែចិត្តគំនិតមនុស្ស៖** ព្រះវិញ្ញាណបង្កើតមនុស្សសាជាថ្មីម្ដងទៀត *(មក ១,១៥ ; ១០,២៧)*។ បើគ្មានព្រះវិញ្ញាណដ៏វិសុទ្ធជួយណែនាំទេ មនុស្សក៏ពុំអាចកែប្រែចិត្តគំនិតដោយខ្លួនឯងបានឡើយ។
- **ប្រោសជំនឿរបស់មនុស្សឲ្យកាន់តែល្អប្រសើរ៖** ព្រះវិញ្ញាណប្រោសអ្នកជឿឲ្យយល់កាន់តែច្បាស់ និងកាន់តែស៊ីជម្រៅអំពីការសម្ដែង៖ អស ១១,២ *(ព្រះអំណោយទានទាំងប្រាំពីរនៃព្រះវិញ្ញាណ)*។ នៅវ៉ាទីកង់ទី២ ពួកលោកអភិបាលលែងនិយាយអំពី *"ការស្ដាប់បង្គាប់ដោយមិនយល់"* (វ៉ាទីកង់ទី១) ប៉ុន្តែពួកលោកនិយាយថា អ្នកជឿ *"យល់អំពីការសម្ដែងកាន់តែជ្រៅ"* បានសេចក្ដីថា យើងជឿមកពីការសម្ដែងមានហេតុផលច្បាស់លាស់។

ដូចសន្តៈអូគូស្ទីនធ្លាប់និយាយព្រះវិញ្ញាណដ៏វិសុទ្ធជំរុញមនុស្សឲ្យជឿ និងឲ្យកែប្រែចិត្តគំនិត។ ព្រះអង្គ

មានសកម្មភាពក្នុងជម្រៅចិត្តមនុស្ស ដ្បិតព្រះជាម្ចាស់គង់នៅក្នុងចិត្តមនុស្ស។ ម្យ៉ាងទៀត ត្រូវតែ *"ជឿដើម្បីយល់"* គឺអ្នកជឿចង់យល់អំពីជំនឿកាន់តែច្រើនៗ៖ *"ឱ ! ព្រះអម្ចាស់អើយ សូមព្រះអង្គជួយឲ្យខ្ញុំយល់ជំនឿក្រែងលោ ខ្ញុំលែងស្វែងរកព្រះអង្គ"*។

## ៣.២) ជំនឿមកពីមនុស្ស

ព្រះគ្រីស្ត ដែលជួយសង្គ្រោះមនុស្ស សូមឲ្យគេសម្រេចចិត្តទទួលការសង្គ្រោះឬទេ៖ រម ១៣,១១។ ព្រះជាម្ចាស់សព្វព្រះហឫទ័យប្រណីសន្ដោសឲ្យមនុស្សបើកចិត្តគំនិត ដើម្បីជឿ និងផ្ញើជីវិតទៅលើព្រះអង្គ។ ជំនឿជាកិច្ចការរបស់មនុស្សផងដែរ។

មហាសន្និបាតវ៉ាទីកង់ទី ២ និយាយអំពីជំនឿ ដោយប្រើពាក្យ *"ផ្ញើជីវិតទៅលើព្រះជាម្ចាស់"*។ ម្យ៉ាងទៀត យោងតាមវ៉ាទីកង់ទី១ អ្នកជឿត្រូវយកប្រាជ្ញា និងបំណងប្រាថ្នាគោរពប្រណិប័តន៍ព្រះជាម្ចាស់ *(រម ១៦,២៦)*។

- អ្នកស្វែងយល់ប្រើប្រាជ្ញាដើម្បីជឿ។ អ្នកស្វែងយល់ស្វែងរកហេតុផលនៃជំនឿ មុននឹងផ្ញើជីវិតទៅលើព្រះជាម្ចាស់។ អ្នកស្វែងរកវិះគិតពិចារណា មុននឹងសុខចិត្តដើរតាមព្រះជាម្ចាស់។ សន្តះប៉ូលនិយាយអំពីការស្គាល់ព្រះគ្រីស្ត ឬការស្គាល់សេចក្តីពិត (១ករ ១៣,៩-១២; ភល ៣,៧-១១; ២ករ ៤,៦)។
- បន្ទាប់មកអ្នកស្វែងរកត្រូវសម្រេចចិត្តផ្ញើជីវិតទៅលើព្រះជាម្ចាស់។ ទោះបីអ្នកស្វែងយល់មិនអាចយល់អ្វីៗទាំងអស់ក៏ដោយ ក៏គេមានបំណងចង់ចាប់ផ្ដើមមានទំនាក់ទំនងជាមួយព្រះជាម្ចាស់ ដោយសុខចិត្តជឿទុកចិត្តព្រះអង្គ។
- ទីបញ្ចប់វ៉ាទីកង់ទី ២ និយាយថា អ្នកស្វែងយល់ផ្ញើជីវិតទាំងស្រុងទៅលើព្រះជាម្ចាស់។ មនុស្សមិនគ្រាន់តែប្រើប្រាជ្ញាប៉ុណ្ណោះទេ *(អ្នកជឿមិនគ្រាន់តែជឿសេចក្តីផ្សេងៗ)* ឬគេមិនគ្រាន់តែមានបំណងសុខចិត្តដើរតាមព្រះជាម្ចាស់ទេ *(អ្នកជឿមិនគ្រាន់តែធ្វើតាមព្រះបញ្ញាព្រះអង្គ)* គឺគេប្រថុយជីវិតតែម្តង៖ លក ៩,២៤។ ក្នុងសម្ព័ន្ធមេត្រីចាស់អ្នកជឿផ្ញើជីវិតទៅលើព្រះជាម្ចាស់ មកពីគេជឿជាក់ថា ព្រះអង្គនឹងគោរពព្រះបន្ទូលសន្យារបស់ព្រះអង្គចំពោះគេ ហើយក្នុងសម្ព័ន្ធមេត្រីថ្មី អ្នកជឿផ្ញើជីវិតទៅលើព្រះជាម្ចាស់មកពីគេជាប់ចិត្តនឹងព្រះយេស៊ូគ្រីស្ត ដែលបានសោយទិវង្គត និងមានព្រះជន្មថ្មី។

## ៣.៣) តើត្រូវធ្វើយ៉ាងដូចម្ដេច ដើម្បីយល់ថា ជំនឿមកពីព្រះជាម្ចាស់ផង មកពីមនុស្សផងដែរ?

បើយើងនិយាយថា ជំនឿមកពីព្រះជាម្ចាស់តែប៉ុណ្ណោះ នោះមនុស្សគ្មានសេរីភាព ឬសកម្មភាពសោះ (fideism)។ ផ្ទុយទៅវិញ បើយើងអះអាងថាជំនឿមកពីមនុស្សតែប៉ុណ្ណោះ នោះមនុស្សពឹងផ្អែកទាំងស្រុងទៅលើខ្លួនឯង (pelagianism)។

- **តាមក្រុមប្រូតេស្តង់** ៖ ជំនឿជាកិច្ចការរបស់ព្រះជាម្ចាស់តែប៉ុណ្ណោះ៖ sola gratia, sola fides, sola scriptura។ សម្រាប់លោក លូថែរ មនុស្សទទួលការសង្គ្រោះ ដោយសារតែព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ គេមិនចូលរួមក្នុងការសង្គ្រោះខ្លួនឯងទាល់តែសោះ។ មនុស្សទទួលការសង្គ្រោះ មកពីការប្រោសប្រណីរបស់ព្រះជាម្ចាស់តែប៉ុណ្ណោះ ទោះបីគេប្រព្រឹត្តកិច្ចការនៃសេចក្តីស្រឡាញ់ឬទេយ៉ាងណាក៏ដោយ។

សម្រាប់លោក លូថែរ៍ មនុស្សទៅជាមនុស្សសុចរិត ដោយសារព្រះហឫទ័យសន្ដោសរបស់ព្រះជាម្ចាស់តែប៉ុណ្ណោះ សូម្បីតែជំនឿមកពីព្រះអង្គដែរ។

- **តាមព្រះសហគមន៍កាតូលិក ៖** មនុស្ស *"សុខចិត្តរួមសហការនឹងព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់"* (មហាសន្និបាតត្រង់- មហាសន្និបាតវ៉ាទីកង់ទី១)។វ៉ាទីកង់ទី២និយាយ (អំពីព្រះនាងម៉ារី) ថា *"នាងម៉ារីមិនគ្រាន់តែមានរូបកាយ ដែលព្រះជាម្ចាស់ផ្ទុកផ្ដាក់ប៉ុណ្ណោះនោះទេ តែនាងម៉ារី រួមសហការក្នុងការនាំការសង្គ្រោះដល់មនុស្សលោក ដោយសារនាងមានសេរីភាព គឺផ្ញើជីវិតលើព្រះជាម្ចាស់ និងសុខចិត្តធ្វើតាមព្រះបញ្ញារបស់ព្រះអង្គ"* (LG ៥៦)។

តើព្រះជាម្ចាស់ប្រសូតជាមនុស្សមកពីនាងម៉ារីសុខចិត្តធ្វើតាមព្រះអង្គ ឬតើនាងម៉ារីសុខចិត្តធ្វើតាមព្រះអង្គមកពីព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះអង្គទុកជាមុន?

### *តើ "រួមសហការ" មានអត្ថន័យយ៉ាងណា?*

ទោះបីគេទទួលស្គាល់ថា មនុស្សចូលរួមចំណែកក្នុងការសង្គ្រោះខ្លួនឯងយ៉ាងណាក៏ដោយ ក៏ក្រុមប្រូតេស្តង់មិនព្រមប្រើពាក្យនេះ ព្រោះគេខ្លាចថា ជំនឿក្លាយទៅជាបុណ្យកុសល ហើយមនុស្សពឹងលើខ្លួនឯងច្រើនជាងលើព្រះជាម្ចាស់។ ឯព្រះសហគមន៍កាតូលិកប្រើពាក្យនេះ ដើម្បីការពារសេរីភាព និងសកម្មភាពរបស់មនុស្ស។

ទីបញ្ចប់សព្វថ្ងៃ ព្រះសហគមន៍កាតូលិក និងក្រុមប្រូតេស្តង់រួមឯកភាព ដោយអះអាងថា៖ អ្វីៗទាំងអស់មកពីព្រះជាម្ចាស់ សូម្បីតែសេរីភាពរបស់យើង។ ប៉ុន្តែនៅពេលជាមួយគ្នានេះ មនុស្សមិនមែនអសកម្មក្នុងការសង្គ្រោះខ្លួនឯងទេ គឺព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ ជំរុញសេរីភាពរបស់មនុស្សឲ្យផ្ញើជីវិតទាំងស្រុងទៅលើព្រះអង្គ។

### *សេចក្ដីបញ្ចប់៖*

ជំនឿជាព្រះអំណោយទានរបស់ព្រះជាម្ចាស់ផង និងជាកិច្ចការរបស់មនុស្សផងដែរ ទាំងដឹងច្បាស់ថាមនុស្សផ្ទាល់ជាព្រះអំណោយទានរបស់ព្រះជាម្ចាស់៖ *"អ្វីៗដែលអ្នកមាន គឺសុទ្ធតែបានទទួលពីព្រះជាម្ចាស់ទេតើ!"* (១ករ ៤,៧)។

### *សំណួរ៖*

១) តើយើងជឿមកពីអ្វីខ្លះ?

២) ... តាមវ៉ាទីកង់ទី១?

៣) ... តាមវ៉ាទីកង់ទី២?

៤) តើជំនឿមកពីព្រះជាម្ចាស់ ឬមកពីមនុស្ស? សូមពន្យល់។

៥) តើត្រូវធ្វើដូចម្ដេចដើម្បីដឹងថា អ្នកស្វែងយល់ម្នាក់មានជំនឿឬទេ? តើមិត្តអ្នកអានសន្និដ្ឋានអ្វីខ្លះ (អំពីជំនឿ និងការប្រព្រឹត្តកិច្ចការ) ?

# ជំពូកទី ៨
# ទំនាក់ទំនងជាមួយនឹងសាសនាដទៃ[17]

***

នៅក្នុងជំពូកមុនៗយើងបានព្យាយាមពន្យល់ហេតុផលនៃជំនឿតាមគ្រីស្តសាសនាចំពោះអ្នកដទៃ ដោយគោរពសេរីភាពរបស់ពួកគេ។ តាមរយៈព្រះយេស៊ូគ្រីស្ត ព្រះជាម្ចាស់សម្តែងព្រះអង្គឲ្យមនុស្សលោកស្គាល់ ហើយគេត្រូវតែសម្រេចចិត្ត *(ដោយគ្មាននរណាបង្ខំ)* ផ្ញើជីវិតទៅលើព្រះអង្គទេ។ ក្នុងជំពូកនេះ យើងនឹងសួរខ្លួនឯងអំពីសេចក្តីពិត ដែលមាននៅក្នុងសាសនាដទៃ៖ ក្រៅពីគ្រីស្តសាសនា តើមនុស្សលោកអាចទទួលការសង្គ្រោះយ៉ាងដូចម្តេច? តើអ្នកដែលមិនផ្ញើជីវិតទៅលើព្រះយេស៊ូ អាចទទួលការសង្គ្រោះបានឬទេ? តើសាសនានីមួយៗជាផ្លូវផ្សេងៗ ដែលអាចនាំមនុស្សលោកឲ្យទទួលការសង្គ្រោះឬទេ? តើព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យសាសនាដទៃអាចសង្គ្រោះអ្នកដទៃឬទេ? តាមការពិតត្រូវតែទទួលស្គាល់ថា អ្នកកាន់សាសនាដទៃអះអាងថា សាសនារបស់ខ្លួនជាផ្លូវតែមួយដើម្បីទទួលការសង្គ្រោះ។ បើដូច្នេះមែន តើត្រូវគិតយ៉ាងដូចម្តេចអំពី **កក** ៤,១២៖ *"ក្រៅពីព្រះយេស៊ូ គ្មាននរណាម្នាក់អាចសង្គ្រោះមនុស្សបានទាល់តែសោះ ដ្បិតនៅក្រោមមេឃនេះ ព្រះជាម្ចាស់ពុំបានប្រទាននាមណាមួយផ្សេងទៀតមកមនុស្ស ដើម្បីសង្គ្រោះយើងនោះឡើយ" (ឬយហ១៤,៦; មថ ១៦,១៦ ; ១ធម ២,៤)?*

## ១) ព្រះជាម្ចាស់សព្វព្រះហឫទ័យសង្គ្រោះមនុស្សទាំងអស់

តាម មក ១៦,១៦៖ *"អ្នកណាជឿ ហើយទទួលពិធីជ្រមុជទឹក ព្រះជាម្ចាស់នឹងសង្គ្រោះអ្នកនោះ រីឯអ្នកដែលមិនជឿនឹងត្រូវទទួលទោស"* គឺក្រៅពីបានផ្ញើជីវិតទៅលើព្រះគ្រីស្ត ហាក់ដូចជាគ្មាននរណាម្នាក់អាចទទួលការសង្គ្រោះបានឡើយ។ ប៉ុន្តែតាម **កក** ១០,៣៤-៣៥៖ *"ឥឡូវនេះ ខ្ញុំបានយល់យ៉ាងច្បាស់ហើយថា ព្រះជាម្ចាស់រាប់រកមនុស្សទូទៅឥតរើសមុខឡើយក្នុងចំណោមជាតិសាសន៍ទាំងប៉ុន្មាន អ្នកណាក៏ដោយឲ្យតែគោរពកោតខ្លាចព្រះអង្គ ហើយប្រព្រឹត្តអំពើសុចរិតព្រះអង្គមុខជាគាប់ព្រះហឫទ័យនឹងអ្នកនោះមិនខាន"* គឺព្រះជាម្ចាស់មានព្រះហឫទ័យសង្គ្រោះ មនុស្សគ្រប់ជាតិសាសន៍ សូម្បីតែអ្នកណាមិនជឿលើព្រះគ្រីស្តក៏ដោយ។ ម្យ៉ាងទៀតតាម ១ធម ២,៤-៥៖ *"ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យមនុស្សទាំងអស់បានទទួលការសង្គ្រោះ និងបានស្គាល់សេចក្តីពិតយ៉ាងច្បាស់។ មានព្រះជាម្ចាស់តែមួយ មានស្ពានមេត្រីតែមួយរវាងព្រះជាម្ចាស់ និងមនុស្សលោកជាមនុស្សម្នាក់ គឺព្រះគ្រីស្តយេស៊ូ"*។ តើត្រូវធ្វើដូចម្តេចដើម្បីយល់ថា បើយើងមិនជឿលើព្រះយេស៊ូគ្រីស្ត យើងមិនអាចទទួលការសង្គ្រោះបានឡើយ ហើយនៅពេលជាមួយគ្នានេះ ព្រះជាម្ចាស់មានព្រះហឫទ័យសង្គ្រោះមនុស្សទាំងអស់?

---

*17 សូមអាន Nostra Aetate (នៅសម័យយើងនេះ) - មហាសន្និបាតវ៉ាទីកង់ទីពីរ*

## ១.១) តើការសង្គ្រោះមានអត្ថន័យអ្វីខ្លះ?

តាមចំណុចអវិជ្ជមាន នរណាទទួលការសង្គ្រោះ នៅពេលដែលគេរួចផុតពីគ្រោះកាច ជំងឺ ឬបរាជ័យ។ តាមចំណុចវិជ្ជមាន នរណាទទួលការសង្គ្រោះ នៅពេលដែលគេបានសុខសាន្ត និងសុភមង្គល។ ក្នុងព្រះគម្ពីរគេបកប្រែការសង្គ្រោះដោយប្រើពាក្យ Apoluo ដែលមានន័យថា ស្រាយរំដោះ លើកលែង *(បំណុចអវិជ្ជមាន)*។ ក្នុងគម្ពីរអ្នកជឿមានបទពិសោធន៍ថា បានរួចពីខ្មាំងសត្រូវ ជាពិសេសពីភាពជាទាសករនៅស្រុកអេស៊ីប។ សម្រាប់គ្រីស្តបរិស័ទគេទទួលការសង្គ្រោះ នៅពេលគេលែងវង្វេងទៀតហើយ៖ *"សេចក្តីពិតនឹងរំដោះអ្នករាល់គ្នាឲ្យមានសេរីភាព" (យហ ៨,៣២)*។ លើសពីនេះទៅទៀត ការសង្គ្រោះ គឺនៅពេលដែលយើងរួចពីសេចក្តីស្លាប់។ សន្តះប៉ូលសរសេរថា៖ *"ព្រះគ្រីស្តបានរំដោះយើងឲ្យមានសេរីភាពពិតប្រាកដ" (កាឡ ៥,១)*។ ពាក្យ Soteria បកប្រែចំណុចវិជ្ជមាន ដូចជានៅពេលដែលប្រជាជនអ៊ីស្រាអែលចូលក្នុងទឹកដីសន្យា។ ក្នុងអត្ថបទដំណឹងល្អ មនុស្សមានសេចក្តីសុខសាន្តដ៏ពេញលេញនៅពេលដែលគេរួមរស់ជាមួយព្រះជាម្ចាស់ *(១ពត្រ ១,៤)*។

គ្រីស្តសាសនាមានលក្ខណៈពិសេស គឺយើងទទួលការសង្គ្រោះ ដោយសារតែព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់។ *"ព្រះជាម្ចាស់បានសង្គ្រោះបងប្អូន មកពីព្រះអង្គមានព្រះហឫទ័យប្រោសប្រណី"* (អភ ២,៥)។ លុះចាប់ផ្តើមប្រកាសដំណឹងល្អ ព្រះយេស៊ូមានគម្រោងការសង្គ្រោះមនុស្ស *(លក ៤,១៤-៣០)*៖ ប្រកាសដំណឹងល្អដល់ជនក្រីក្រ រំដោះអ្នកជាប់ជាឈ្លើយ ប្រោសអ្នកខ្វាក់ឲ្យភ្លឺ...ប៉ុន្តែព្រះអង្គមិនគ្រាន់តែប្រកាសការសង្គ្រោះ ដែលមកពីព្រះជាម្ចាស់ទេ គឺព្រះយេស៊ូផ្ទាល់ជាព្រះសង្គ្រោះ *(ហប ៥,៩)* ហើយព្រះអង្គប្រគល់អំណាចនេះដល់ព្រះសហគមន៍ថែមទៀតផង៖ *"ខ្ញុំបានទទួលគ្រប់អំណាចទាំងនៅស្ថានបរមសុខ ទាំងនៅលើផែនដី។ ដូច្នេះចូរចេញទៅ..." (មថ ២៨,១៨-១៩)*។

## ១.២) លក្ខណៈពិសេសនៃគ្រីស្តសាសនា

មនុស្សគ្រប់ៗរូបជួបពិសោធន៍នៃទុក្ខលំបាក។ តើទុក្ខវេទនានេះមកពីណា? តើត្រូវធ្វើដូចម្តេចដើម្បីបានរួចពីទុក្ខវេទនាទាំងអស់នោះ? តាមពុទ្ធសាសនាទុក្ខវេទនាមកពីព្រហ្មលិខិត ហើយម្នាក់ៗអាចរំដោះពីទុក្ខលំបាកដោយខ្លួនឯង។ យើងមិនត្រូវរង់ចាំការសង្គ្រោះពីម្នាក់ផ្សេងទៀតឡើយ។ ឯតាមគ្រីស្តសាសនាវិញ ទុក្ខវេទនាមកពីសេរីភាពមនុស្ស (លោកអដាំ) ហើយការសង្គ្រោះមកពីព្រះជាម្ចាស់ប្រោសប្រណី។ សន្តះប៉ូលយល់ឃើញថា ទាំងជនជាតិយូដា ទាំងសាសន៍ដទៃជាប់ជាឈ្លើយនៃអំពើបាប ហើយមិនអាចទទួលការសង្គ្រោះដោយខ្លួនឯងបានឡើយ។ មានតែព្រះជាម្ចាស់ទេ ដែលអាចជួយសង្គ្រោះគេ *(រម ៥,១២-១៨)*៖

*"តាមរយៈមនុស្សតែម្នាក់ បាបបានចូលមកក្នុងពិភពលោក ហើយតាមរយៈបាបសេចក្តីស្លាប់ក៏ចូលមកដែរ។ ហេតុនេះហើយ បានជាសេចក្តីស្លាប់រាលដាលដល់មនុស្សគ្រប់ៗរូប ព្រោះគ្រប់គ្នាសុទ្ធតែបានប្រព្រឹត្តអំពើបាប(...) ប៉ុន្តែកំហុសរបស់លោកអដាំ និងព្រះអំណោយទានរបស់ព្រះជាម្ចាស់ មានលទ្ធផលខុសគ្នាទាំងស្រុង។ មនុស្សទូទៅត្រូវស្លាប់ ព្រោះតែកំហុសរបស់មនុស្សម្នាក់យ៉ាងណា ព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ និងព្រះអំណោយទាននៃការប្រណីសន្តោស ក៏បានហូរមកលើមនុស្សទាំងអស់រឹតតែបរិបូណ៌ តាម*

*រយៈមនុស្សម្នាក់ គឺព្រះយេស៊ូគ្រីស្តយ៉ាងនោះដែរ។ រីឯព្រះអំណោយទានរបស់ព្រះជាម្ចាស់ និងអំពើបាបរបស់មនុស្សតែម្នាក់វិញ ក៏មានលទ្ធផលខុសគ្នាទាំងស្រុងដែរ គឺដោយសារទោសរបស់មនុស្សតែម្នាក់ មនុស្សទាំងអស់ត្រូវជាប់ទោស។ រីឯព្រះអំណោយទានវិញ ធ្វើឲ្យមនុស្សបានសុចរិត ទោះបីគេប្រព្រឹត្តខុសជាច្រើនយ៉ាងណាក៏ដោយ។ ព្រោះតែមនុស្សម្នាក់បានប្រព្រឹត្តខុស ហើយដោយសារមនុស្សតែម្នាក់នេះមច្ចុរាជបានសោយរាជ្យចំណាង់បើតាមរយៈព្រះយេស៊ូគ្រីស្តតែមួយព្រះអង្គវិញ អស់អ្នកដែលបានទទួលការប្រណីសន្តោសដ៏បរិបូណ៌លើសលប់ ព្រមទាំងបានសុចរិតដោយសារព្រះអំណោយទាននឹងរឹតតែបានសោយរាជ្យ នៅក្នុងជីវិតថែមទៀតជាពុំខាន។ សរុបមកដោយសារកំហុសរបស់មនុស្សតែម្នាក់ មនុស្សទាំងអស់ត្រូវជាប់ទោសយ៉ាងណា ដោយសារអំពើសុចរិតរបស់មនុស្សតែម្នាក់ មនុស្សទាំងអស់ក៏បានសុចរិត និងបានទទួលជីវិតយ៉ាងនោះដែរ"។*

ក្នុងអត្ថបទនេះ ព្រះគ្រីស្តជាស្ពានមេត្រីតែមួយ ដែលប្រោសមនុស្សឲ្យបានសុចរិត និងរំដោះគេ ឲ្យរួចពីទោសដែលលោកអដាំ (មនុស្ស) បានប្រព្រឹត្ត ហើយដែលប្រោសមនុស្សឲ្យមានជីវិតដ៏ពេញលេញ។ ទោះបីជាប្រាជ្ញាញាណមនុស្ស និងសាសនាជាច្រើនជំរុញមនុស្សឲ្យរំដោះខ្លួនឯង ដោយខ្លួនឯង គ្រីស្តសាសនាអញ្ជើញគេឲ្យទទួលព្រះហឫទ័យប្រណីសន្តោស ដែលមកពីព្រះជាម្ចាស់។

### ១.៣) របៀបនៃការសង្គ្រោះក្នុងគ្រីស្តសាសនា

តាមគ្រីស្តសាសនា និងតាមព្រះគម្ពីរ ការសង្គ្រោះមានផ្លូវពីរ៖ ព្រះគ្រីស្តដែលជាព្រះជាម្ចាស់ប្រសូតជាមនុស្ស យាងចុះទៅរកមនុស្សដើម្បីសង្គ្រោះគេ ហើយព្រះគ្រីស្តជាមនុស្សដូចយើងបេះបិទ ដែលសង្គ្រោះមនុស្សដោយព្រះអង្គរងទុក្ខលំបាក និងបូជាព្រះជន្មជំនួសមនុស្ស។ គេហៅផ្លូវទីមួយ (ដែលចាប់ផ្តើមពីព្រះជាម្ចាស់ទៅដល់មនុស្ស)ថា ការប្រោសឲ្យបានជា គឺព្រះគ្រីស្តប្រៀបធៀបដូចជាលោកគ្រូពេទ្យម្នាក់ (លក ១៩,១០) ដែលយាងមកប្រសូតជាមនុស្ស ដើម្បីប្រោសមនុស្សឲ្យបានជា។ គេហៅផ្លូវទីពីរថា ការប្រោសឲ្យបានទៅជាព្រះ គឺព្រះជាម្ចាស់ប្រសូតជាមនុស្សដើម្បីឲ្យយើងទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ (សន្តៈអាថាណាស - Athanase - សន្តអ៊ីរ៉េណេ សន្តៈ អូគូស្ទីន)។

## ២) "ក្រៅពីព្រះសហគមន៍ គ្មានការសង្គ្រោះទេ"

គ្រូបាធ្យាយ[18]ធ្លាប់និយាយជាញឹកញាប់ថា៖ *"ក្រៅពីព្រះសហគមន៍ គ្មានការសង្គ្រោះទេ"*។ តើត្រូវយល់ការអះអាងនេះយ៉ាងដូចម្តេច? ហាក់ដូចជាមានតែអ្នករស់នៅក្នុងព្រះសហគមន៍ ដែលអាចទទួលការសង្គ្រោះបាន។ តាមការពិតគ្រូបាធ្យាយប្រើឃ្លានេះ មិនមែនដើម្បីសាសន៍ដទៃទេ ប៉ុន្តែពួកលោកសំដៅទៅលើគ្រីស្តបរិស័ទដែលបានចាកចេញពីព្រះសហគមន៍។ ចំពោះគ្រីស្តបរិស័ទ ដែលបានលះបង់ជំនឿចោល ឬដែលវង្វេងក្នុងនិកាយផ្សេងៗ សន្តៈស៊ីព្រីយ៉ាំងធ្លាប់និយាយថា ពួកគេមិនអាចទទួលការសង្គ្រោះឲ្យបានពេញលេញទេ។ ប៉ុន្តែយូរៗទៅមេដឹក នាំព្រះសហគមន៍ប្រើសេចក្តីនេះ សំដៅទៅលើមនុស្សទាំងអស់ ដែលមិនជាប់នឹងព្រះសហគមន៍គ្រីស្តបរិស័ទក្តីសាសនាដទៃក្តី។ នៅមហាសន្និបាតនៃទីក្រុងហ្វ្លរ៉ង់ (Florence) នៅឆ្នាំ១៤៤២ ពួកលោកអភិបាលសរសេរថា *"ក្រៅពីបងប្អូន ដែលរស់នៅក្នុងព្រះសហគមន៍កាតូលិក គ្មាននរណាម្នាក់អាចចូល*

18 *សន្តស៊ីព្រីយ៉ាំង* (Cyprian)

*រួមចំណែកក្នុងជីវិតអស់កល្បជានិច្ចបានឡើយ"*!

## ២.១) ការបកស្រាយផ្សេងៗនៃសេចក្ដីនេះ

ដោយសារមនុស្សទូទៅយល់ខុសថា នរណាមិនជាប់នឹងព្រះសហគមន៍កាតូលិក មិនអាចទទួលការសង្គ្រោះបានឡើយ នៅឆ្នាំ១៨៥៤ព្រះសហគមន៍បន្ថែមថា*"គ្មានការសង្គ្រោះ សម្រាប់អស់អ្នកដែលបានប្រព្រឹត្តខុស"*។ ប៉ុន្តែសេចក្ដីនេះឆ្លុះបញ្ចាំងចិត្តចង្អៀតចង្អល់របស់មេដឹកនាំព្រះសហគមន៍ ហើយនាំឲ្យមនុស្សជាច្រើនបាកចេញពីព្រះសហគមន៍ ឬមិនអាចចូលបានឡើយ។ ឧ. តាមហេតុផលនៃសេចក្ដីនេះ កូនក្មេងដែលស្លាប់ដោយមិនបានទទួលពិធីជ្រមុជទឹកត្រូវតែធ្លាក់ឋាននរក។

ម្យ៉ាងទៀត មនុស្សភាគច្រើនមិនស្គាល់ព្រះសហគមន៍ ហើយមិនទទួលពិធីជ្រមុជទឹក៖ តើអ្នកទាំងអស់នោះ មិនអាចទទួលការសង្គ្រោះឬ? ពួកទេវវិទូធ្លាប់និយាយថា ក្នុងករណីនេះ ព្រះជាម្ចាស់នឹងសង្គ្រោះគេ ដោយចាត់ទេវទូតមួយរូប ឬសាសនទូតម្នាក់ ឬដោយប្រោសគេឲ្យបានភ្លឺពីខាងក្នុង! គឺព្រះជាម្ចាស់ត្រូវប្រព្រឹត្តការអស្ចារ្យជានិច្ច! បន្ទាប់មកពួកអភិបាលធ្លាប់និយាយថា បើគេពិតជាមិនអាចស្គាល់សាសនាពិតប្រាកដមែនទែនដោយមិនបានប្រព្រឹត្តខុស មនុស្សអាចទទួលការសង្គ្រោះបាន។ បន្ទាប់មកទៀត ពួកលោកធ្លាប់និយាយថា បើគេចង់ចូលក្នុងព្រះសហគមន៍មែន មនុស្សអាចទទួលការសង្គ្រោះ (ទោះបីបំណងចង់នេះនៅតែស្ថិតក្នុងជម្រៅចិត្តគេក៏ដោយ)។ នៅឆ្នាំ១៩៤៣ សម្ដេចប៉ាបពីយ៉ូស (Pius) ទី១២ និយាយអំពីព្រះសហគមន៍ ដែលមើលពុំឃើញ គឺមានមនុស្សជាច្រើនចូលក្នុងព្រះសហគមន៍ដ៏អាថ៌កំបាំង ដែលមានតែព្រះគ្រីស្ដស្គាល់នោះ។ ទីបញ្ចប់លោក ឌឺ លូបាក (de Lubac) បកស្រាយសេចក្ដីនេះ ដោយសេសេរថា សេចក្ដីនេះ មានន័យថា មានតែព្រះសហគមន៍ទេ ដែលអាចផ្ដល់ការសង្គ្រោះ (តាមលោក ឌឺ លូបាក សេចក្ដីនេះ មិនមែនមានន័យថា ក្រៅពីព្រះសហគមន៍ មនុស្សទាំងអស់ធ្លាក់នរកទេ)។

## ២.២) មហាសន្និបាតវ៉ាទីកង់ទី២

សម្រាប់អស់លោកអភិបាល នៅមហាសន្និបាតវ៉ាទីកង់ទី ២ មនុស្សទាំងអស់អាចទទួលការសង្គ្រោះឲ្យពេញលេញបាន ទោះបីជាពួកគេកាន់សាសនាដទៃយ៉ាងណាក៏ដោយ។

ក្រៅពីព្រះគ្រីស្ដ គ្មានការសង្គ្រោះឡើយ។ ប៉ុន្តែព្រះគ្រីស្ដបានសោយទិវង្គតសម្រាប់មនុស្សទាំងអស់ មិនគ្រាន់តែសម្រាប់គ្រីស្ដបរិស័ទប៉ុណ្ណោះទេ៖ *"ដោយព្រះគ្រីស្ដសោយទិវង្គតដើម្បីមនុស្សទាំងអស់ និងដោយព្រះជាម្ចាស់កំណត់ទិសដៅតែមួយឲ្យជីវិតមនុស្សយ៉ាងពិតមែននោះ ពោលគឺឲ្យរួមរស់ជាមួយព្រះអង្គ យើងត្រូវតែយល់ថា ព្រះវិញ្ញាណដ៏វិសុទ្ធប្រោសឲ្យមនុស្សទាំងអស់ អាចរួមជាមួយព្រះគ្រីស្ដដែលសោយទិវង្គត និងមានព្រះជន្មថ្មីតាមរបៀបដែលព្រះជាម្ចាស់ស្គាល់"* (GS ២២,៥)។ ព្រះវិញ្ញាណដ៏វិសុទ្ធជាអ្នកនាំមនុស្សទាំងអស់ឲ្យចូលរួមជាមួយព្រះគ្រីស្ដ ប៉ុន្តែយើងមិនដឹងថា តាមរបៀបណាខ្លះទេ (fides quae)។

ម្យ៉ាងទៀត *"អស់អ្នកដែលមិនស្គាល់ដំណឹងល្អរបស់ព្រះគ្រីស្ដ និងមិនស្គាល់ព្រះសហគមន៍របស់ព្រះអង្គ ដោយគេគ្មានកំហុសអ្វី តែស្វែងរកព្រះជាម្ចាស់ដោយចិត្តស្មោះ និងខិតខំប្រព្រឹត្តតាមព្រះហឫទ័យព្រះអង្គ*

*ស្របតាមមនសិការបង្ហាញ និងបញ្ជាឲ្យប្រព្រឹត្តនោះ អ្នកទាំងនោះក៏អាចឈានទៅដល់ការសង្គ្រោះអស់កល្បជានិច្ច*"(LG ១៦)។ដូច្នេះមនុស្សអាចទទួលការសង្គ្រោះ ដោយធ្វើតាមមនសិការរបស់ខ្លួន ទោះបីជាគេមិនជឿលើព្រះជាម្ចាស់ក៏ដោយ (រម ២,១៤-១៦) (fides qua)។

## តើត្រូវបំភ្លេចសេចក្តីថា "ក្រៅពីព្រះសហគមន៍ គ្មានការសង្គ្រោះទេ" ឬទេ?

សម្រាប់គណៈកម្មាធិការទេវវិទ្យាអន្តរជាតិ ពាក្យ *"ព្រះសហគមន៍"* សំដៅទៅលើប្រជាជនរបស់ព្រះជាម្ចាស់ ដែលធំជាងព្រះសហគមន៍កាតូលិក គឺអស់អ្នកដែលព្យាយាមប្រព្រឹត្តអំពើល្អ តាម មថ ២៥។ ប៉ុន្តែតាមវ៉ាទីកង់ទី ២ ៖ *"ព្រះសហគមន៍បែបនេះ (ព្រះសហគមន៍ដ៏អាថ៌កំបាំង) តែងតាំងទុកជាសង្គមម៉្យាង ក្នុងលោកនេះ ដោយមានរបៀបរៀបរយ គឺពិតជា (subsistit in) ព្រះសហគមន៍កាតូលិក ដែលមានអភិបាលព្រះសហគមន៍ក្រុងរ៉ូមគ្រប់គ្រង ក្នុងឋានៈជាអ្នកបន្តមុខងារពីគ្រីស្តទូតសិលាមក និងដែលមានអស់លោកអភិបាលគ្រប់គ្រងរួបរួមជាមួយលោកដែរ។ ទោះបីនៅខាងក្រៅរចនាសម្ព័ន្ធនៃព្រះសហគមន៍មានកត្តាជាច្រើន អាចនាំឲ្យមនុស្សបានវិសុទ្ធ និងឲ្យស្គាល់សេចក្តីពិតក្តីក៏កត្តាទាំងនោះ ជាកម្មសិទ្ធិនៃព្រះសហគមន៍របស់ព្រះគ្រីស្ត តាមព្រះអំណោយទានរបស់ព្រះជាម្ចាស់ដែរ។ កត្តាទាំងនោះដាស់តឿនមនុស្សលោកឲ្យរួបរួមគ្នាជាធ្លុងតែមួយក្នុងព្រះសហគមន៍កាតូលិក"* (LG ៨)។

តើ Subsistit មានអត្ថន័យអ្វីខ្លះ? សម្រាប់អ្នកខ្លះ ពាក្យនេះសំដៅទៅលើព្រះសហគមន៍កាតូលិកតែប៉ុណ្ណោះ គឺព្រះសហគមន៍កាតូលិកជាព្រះសហគមន៍តែមួយយ៉ាងពិតប្រាកដរបស់ព្រះគ្រីស្ត ដែលមានគ្រប់មធ្យោបាយនៃការសង្គ្រោះដ៏ពេញលេញ។ ក្រៅពីព្រះសហគមន៍នេះ មនុស្សអាចទទួលការសង្គ្រោះ ប៉ុន្តែការសង្គ្រោះនេះ មិនគ្រប់លក្ខណៈទេ។ សម្រាប់អ្នកខ្លះផ្សេងទៀត ពាក្យ Subsistit មានន័យថា ព្រះសហគមន៍របស់ព្រះគ្រីស្តមានព្រះសហគមន៍កាតូលិកផង ព្រះសហគមន៍ដ៏អាថ៌កំបាំងដែលមើលពុំឃើញផងដែរ បានសេចក្តីថា មនុស្សទាំងអស់អាចទទួលការសង្គ្រោះឲ្យបានពេញលក្ខណៈ ក្រៅពីព្រះសហគមន៍កាតូលិក។

សរុបសេចក្តី ត្រូវតែយល់សេចក្តីថា *"ក្រៅពីព្រះសហគមន៍ គ្មានការសង្គ្រោះទេ"* ស្របតាមសេចក្តីផ្សេងទៀត ដែលមានក្នុងសន្និបាតវ៉ាទីកង់ទី ២ ដូចជា *"ព្រះសហគមន៍ (...) មានសារៈសំខាន់ជាចាំបាច់ ដើម្បីឲ្យមនុស្សលោកទទួលការសង្គ្រោះ"* (LG ១៤) *"ព្រះសហគមន៍ជាមធ្យោបាយសកលនៃការសង្គ្រោះ (UR ៣) ព្រះសហគមន៍ "ជាមធ្យោបាយដើម្បីរំដោះមនុស្សទាំងអស់" (LG ៩) "ព្រះសហគមន៍ជាអគ្គសញ្ញានៃការសង្គ្រោះរបស់មនុស្សទាំងអស់"* (LG ៤៨) *"ព្រះសហគមន៍ក៏ជាសញ្ញាសម្គាល់ និងជាមធ្យោបាយនាំឲ្យមនុស្សជាតិទាំងមូលរួមគ្នាជាធ្លុងតែមួយដែរ"* (LG ១) គឺព្រះសហគមន៍មានតួនាទីដ៏សកម្មក្នុងការសង្គ្រោះ ប៉ុន្តែមនុស្សទាំងអស់ ដែលខិតខំធ្វើតាមមនសិការរបស់ខ្លួន និងប្រព្រឹត្តអំពើល្អរួមគ្នាក្នុងព្រះសហគមន៍ដ៏អាថ៌កំបាំងរបស់ព្រះគ្រីស្តដែរ។ ដូច្នេះហើយបានជាត្រូវតែយល់ពាក្យ *"ព្រះសហគមន៍"* ក្នុងសេចក្តី *"ក្រៅពីព្រះសហគមន៍គ្មានការសង្គ្រោះទេ"* ដូចជាព្រះសហគមន៍ដ៏អាថ៌កំបាំងរបស់ព្រះគ្រីស្ត មិនគ្រាន់តែព្រះសហគមន៍កាតូលិកទេ។

## ៣) តើសាសនាដទៃជាផ្លូវដ៏ពិតប្រាកដ ដើម្បីទទួលការសង្គ្រោះ ឬទេ?

ទោះបីជាក្នុងសម្ព័ន្ធមេត្រីចាស់ ប្រជាជនអ៊ីស្រាអែលប្រកាន់សាសន៍ដទៃ កុំឲ្យជនជាតិអ៊ីស្រាអែលបោះបង់ជំនឿចោលយ៉ាងណាក៏ដោយ (*"ពួកយើងកម្ទេចពួកគេថ្វាយផ្ដាច់ដល់ព្រះអម្ចាស់ (...)គឺពួកយើងកម្ទេចអ្នកក្រុងទាំងនោះ ទាំងប្រុស ទាំងស្រី និងកូនក្មេង ថ្វាយផ្ដាច់ដល់ព្រះអម្ចាស់"* (ទក ៣,៦) ក៏ជនជាតិអ៊ីស្រាអែលបានយល់ឃើញថា ព្រះជាម្ចាស់ជាព្រះរបស់មនុស្សទាំងអស់ដែរ (*"ព្រះអម្ចាស់នៃពិភពទាំងមូលនឹងប្រទានពរដល់ពួកគេថា"* សូមឲ្យអេស៊ីបជាប្រជាជនរបស់យើង ព្រមទាំងអាស្ស៊ីរី ដែលយើងបានបង្កើតមក និងអ៊ីស្រាអែលជាចំណែកមត៌ករបស់យើងបានទទួលពរ" (អស ១៩,២៥)។ ក្នុងសម្ព័ន្ធមេត្រីថ្មី គ្រីស្តបរិស័ទយល់ថា អ្នកជឿទទួលការសង្គ្រោះរួចហើយ ប៉ុន្តែព្រះជាម្ចាស់មិនបោះបង់ចោលអ្នកដទៃឡើយ៖ *"យើងសង្ឃឹមលើព្រះជាម្ចាស់ដ៏មានព្រះជន្មគង់នៅ ព្រះអង្គជាព្រះសង្គ្រោះរបស់មនុស្សលោកទាំងអស់ ជាពិសេសរបស់អ្នកជឿ"* (១ធម ៤,១០)។

តាំងពីមហាសន្និបាតវ៉ាទីកង់ទី ២ គ្រីស្តបរិស័ទយល់ឃើញច្បាស់ថា ព្រះជាម្ចាស់សព្វព្រះហឫទ័យសង្គ្រោះមនុស្សទាំងអស់ ទោះបីជាពួកគេកាន់សាសនាដទៃក៏ដោយ។ ប៉ុន្តែតើយើងអាចនិយាយថា សាសនាដទៃជាផ្លូវដ៏ពិតប្រាកដ ដើម្បីទទួលការសង្គ្រោះឬទេ?

យើងមិនត្រូវច្រឡំសំណួរនេះ ជាមួយនឹងសំណួរថា តើមនុស្សទាំងអស់អាចទទួលការសង្គ្រោះ ក្រៅពីព្រះសហគមន៍ គឺនៅទីនេះ យើងសួរថា តើសាសនាដទៃមានតួនាទីសង្គ្រោះមនុស្សតាមគម្រោងការរបស់ព្រះជាម្ចាស់ឬទេ? បើសាសនាដទៃមានតួនាទីសង្គ្រោះសមាជិករបស់ខ្លួនមែន (ដូចលោក កាល រ៉ាន់ើរ ធ្លាប់និយាយ) យើងត្រូវតែសួរថា តើការសង្គ្រោះដែលសាសនាទាំងអស់នោះ ផ្ដល់ឲ្យជាការសង្គ្រោះដ៏ពេញលក្ខណៈឬទេ?

### ៣.១) ព្រះគ្រីស្តជាដើមកំណើតនៃការសង្គ្រោះរបស់មនុស្សទាំងអស់ (LG ១៧)

**ព្រះគ្រីស្តជាស្ពានមេត្រីតែមួយគត់៖** *"ក្រៅពីព្រះយេស៊ូ គ្មាននរណាម្នាក់អាចសង្គ្រោះមនុស្សបានទាល់តែសោះ" (កក ៤,១២)។ តាម* Nostra aetate *"ព្រះសហគមន៍កាតូលិកមិនទាត់ចោលអ្វីៗដ៏ពិតប្រាកដ និងអ្វីៗដ៏វិសុទ្ធដែលមានកប់ទុកក្នុងសាសនា(ដទៃ)"* ប៉ុន្តែនៅពេលជាមួយគ្នានេះ *"ព្រះសហគមន៍ប្រកាសព្រះគ្រីស្ត ហើយមានភារកិច្ចប្រកាសព្រះគ្រីស្តដោយឥតឈប់ឈរ ព្រោះព្រះអង្គពិតជាមាគ៌ា ជាសេចក្ដីពិត និងជាជីវិត" (យហ ១៤,៦)។ មនុស្សទាំងអស់មុខជានឹងរកឃើញជីវិតខាងសាសនាយ៉ាងពេញលក្ខណៈក្នុងអង្គព្រះគ្រីស្ត ព្រោះព្រះជាម្ចាស់បានសម្រុះសម្រួលសត្វលោកទាំងអស់ឲ្យជានានឹងព្រះអង្គក្នុងអង្គព្រះគ្រីស្តនេះឯង (២ករ ៥,១៨-១៩)"*(NA២) បានសេចក្ដីថា មហាសន្និបាតវ៉ាទីកង់ទី២ អះអាងថា សាសនាដទៃជារស្មីនៃសេចក្ដីពិត ប៉ុន្តែព្រះគ្រីស្តជាសេចក្ដីពិតដ៏ពេញលេញ។

### *តើត្រូវគិតយ៉ាងដូចម្ដេច?*

សម្រាប់លោក កាល បារថ៍ ត្រូវតែបោះបោលសាសនាដទៃ ដែលរាំងមនុស្សមិនអាចឈានចូលទៅកាន់

ព្រះបិតា។ សម្រាប់លោកសាសនានីមួយៗជាការខិតខំរបស់មនុស្សទៅរកព្រះជាម្ចាស់ ប៉ុន្តែព្រះជាម្ចាស់ដែលសម្តែងព្រះអង្គឲ្យមនុស្សលោកស្គាល់ ធ្វើឲ្យការខិតខំទាំងប៉ុន្មានរបស់មនុស្សរលាយសាបសូន្យតែម្តង។ ដោយសារព្រះជាម្ចាស់ សម្តែងព្រះអង្គ សាសនានីមួយៗគ្មានតម្លៃទាល់តែសោះ។ លើសពីនេះទៅទៀត លោកចាត់ទុកថា សាសនាដទៃ ព្រមទាំងគ្រីស្តសាសនានាំមនុស្សឲ្យគោរពព្រះក្លែងក្លាយទៅទៀត៖ Sola gratia គឺមានតែព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ដែលសង្គ្រោះមនុស្សលោក។ ប៉ុន្តែបើយើងតាមលោកបារប៍ ធ្វើយ៉ាងដូចម្តេច ដើម្បីឲ្យមានទំនាក់ទំនងជាមួយសាសនាដទៃបាន? សព្វថ្ងៃមានតែក្រុមប្រូតេស្តង់ជ្រុលនិយមខ្លះ ដែលធ្វើតាមលោក កាល បារប៍។

សម្រាប់ទេវវិទូកាតូលិកភាគច្រើន ហើយយោងតាមមហាសន្និបាតវ៉ាទីកង់ទី២ គ្រីស្តបរិស័ទទទួលស្គាល់ថា សាសន៍ដទៃមានតម្លៃពិតប្រាកដមែន ប៉ុន្តែសាសនាទាំងអស់នោះ គ្រាន់តែ *"រៀបចំផ្លូវថ្វាយដំណឹងល្អ"* របស់ព្រះគ្រីស្ត ទាំងអស់នោះមកពី *"គរុកោសល្យរបស់ព្រះជាម្ចាស់"* ជា *"គ្រាប់ពូជនៃព្រះបន្ទូល"*។ ព្រះគ្រីស្តមិនប្រឆាំងនឹងសាសនាដទៃទេ ប៉ុន្តែព្រះអង្គគង់យ៉ាងស្ងាត់កំបាំងនៅក្នុងសាសនាដទៃ ហើយព្រះអង្គបំពេញសាសនាទាំងអស់នោះដែរ។ ព្រះគ្រីស្តយាងមកប្រែសាសនាដទៃឲ្យបានពេញលក្ខណៈ។

## ៣.២) តួនាទីរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ

យើងបានយល់ឃើញថា ១. ព្រះគ្រីស្តជាស្ពានមេត្រីតែមួយ ដែលសង្គ្រោះមនុស្សទាំងអស់ ២. សាសនាដទៃ មានតម្លៃដ៏ពិតប្រាកដ សាសនាទាំងអស់នោះជាផ្លូវ ឬ *"អគ្គសញ្ញា"* នៃការសង្គ្រោះដែរ។ តើត្រូវធ្វើយ៉ាងដូចម្តេច ដើម្បីឲ្យការអះអាងទាំងពីនោះស្របនឹងគ្នា?

តាមមហាសន្និបាតវ៉ាទីកង់ទី២ *"ព្រះសហគមន៍ធ្វើឲ្យព្រះគ្រីស្តមានវត្តមានក្នុងពិភពលោកនេះហើយ គឺព្រះគ្រីស្តដែលសម្រេចការសង្គ្រោះ។ ព្រះជាម្ចាស់បានសាបព្រោះអ្វីៗដ៏ពិតប្រាកដ និងអ្វីៗដែលសម្តែងព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គ កប់ទុកក្នុងចំណោមសាសន៍ដទៃ ហាក់ដូចជាវត្តមានម៉្យាងដ៏ស្ងាត់កំបាំងរបស់ព្រះអង្គក្នុងសាសន៍ទាំងនោះ។ បើព្រះសហគមន៍រកឃើញព្រះសហគមន៍រំដោះអ្វីទាំងនោះឲ្យរួចពីចំណងអាក្រក់ និងលើកទៅថ្វាយសងព្រះគ្រីស្ត ដែលបានបង្កើតអ្វីៗទាំងនោះវិញ"* (AG ៩)។ ព្រះវិញ្ញាណដ៏វិសុទ្ធដូចជាខ្យល់ គឺព្រះអង្គបក់ទៅទីណាក៏បាន *(យហ ៣,៨)*។ តាមពួកលោកអភិបាល គឺព្រះវិញ្ញាណនេះទេតើដែល *"ប្រោសឲ្យមនុស្សទាំងអស់អាចរួមជាមួយព្រះគ្រីស្តដែលសោយទិវង្គត និងមានព្រះជន្មថ្មី"* (GS ២២,៥) ដោយយល់ច្បាស់ថា *"មនុស្សទាំងអស់"* សំដៅទៅលើ *"សាសនាទាំងឡាយ"* ដែរ។ ព្រះវិញ្ញាណគង់នៅសកលលោកទាំងមូល (AG ៤) ហើយព្រះអង្គនាំមនុស្សទាំងអស់ទៅរកព្រះគ្រីស្ត ដោយសារគ្រាប់ពូជនៃព្រះបន្ទូល និងការប្រកាសដំណឹងល្អ (AG ១៥)។ ព្រះវិញ្ញាណដ៏វិសុទ្ធមិនគ្រាន់តែប្រព្រឹត្តកិច្ចការក្នុងជីវិតមនុស្សម្នាក់ៗទេ ថែមទាំងព្រះអង្គប្រតិបត្តិតាមវប្បធម៌ និងសាសនាផងដែរ។ តាមសម្តេចប៉ាបយ៉ូហានប៉ូលទី ២៖ ព្រះវិញ្ញាណដ៏វិសុទ្ធគង់ក្នុងជម្រៅចិត្តមនុស្សម្នាក់ៗ ហើយព្រះអង្គគង់នៅក្នុងសង្គមប្រវត្តិសាស្រ្ត ប្រជាជាតិនានា វប្បធម៌ និងសាសនា។ ប៉ុន្តែព្រះវិញ្ញាណមិនជំនួសព្រះគ្រីស្តទេ គ្រាន់តែរៀបចំផ្លូវថ្វាយព្រះគ្រីស្ត (RM ២៨)។

## ៣.៣) ព្រះសហគមន៍ជាអគ្គសញ្ញានៅក្នុងអង្គព្រះគ្រីស្ដសម្រាប់មនុស្សទាំងអស់

បើព្រះគ្រីស្ដជាស្ពានមេត្រីតែមួយ សាសនាដទៃជាផ្លូវដពិតប្រាកដ អាចនាំមនុស្សលោកឲ្យទទួលការសង្គ្រោះ ហើយបើព្រះវិញ្ញាណដ៏វិសុទ្ធនាំមនុស្សទាំងអស់ឲ្យចូលរួមជាមួយព្រះគ្រីស្ដ ដែលបានសោយទិវង្គត និងមានព្រះជន្មថ្មី តើព្រះសហគមន៍មានតួនាទីអ្វីខ្លះក្នុងការសង្គ្រោះ?

*"ព្រះសហគមន៍រួមក្នុងអង្គព្រះគ្រីស្ដហាក់ដូចជាអគ្គសញ្ញាម៉្យាង គឺជាសញ្ញាសម្គាល់បង្ហាញព្រះជាម្ចាស់ និងជាមធ្យោបាយ នាំឲ្យមនុស្សអាចរួមរស់យ៉ាងជិតស្និទ្ធជាមួយព្រះអង្គបាន។ ព្រះសហគមន៍ក៏ជាសញ្ញាសម្គាល់ និងជាមធ្យោបាយនាំឲ្យមនុស្សជាតិទាំងមូលរួមគ្នាជាធ្លុងតែមួយដែរ"* (LG ១)។ *"ព្រះសហគមន៍ជាអគ្គសញ្ញាសកលនៃការសង្គ្រោះ"*(LG៤៨)បានសេចក្ដីថាព្រះសហគមន៍មិនមែនជាព្រះរាជ្យរបស់ព្រះជាម្ចាស់ផងដែរ។ ព្រះសហគមន៍ក្នុងឋានៈជាអគ្គសញ្ញាដូចជា អ្នកកណ្ដាលរវាងព្រះគ្រីស្ដ ដែលព្រះសហគមន៍ទទួលអ្វីៗទាំងអស់ពីព្រះអង្គ និងមនុស្សលោកដែលព្រះជាម្ចាស់បានចាត់ព្រះសហគមន៍នេះឲ្យទៅ។ ព្រះសហគមន៍នៅក្នុងលោក ដោយមិនភ្ជាប់នឹងលោកីយ៍ឡើយ (យហ ១៧,១៥)។ ទោះបីព្រះសហគមន៍មិនត្រូវជាប់ជំពាក់រឿងលោកីយ៍ក៏ដោយ ក៏ព្រះសហគមន៍ត្រូវតែនៅក្នុងលោកនេះ ដើម្បីធ្វើជាទីសម្គាល់របស់ព្រះគ្រីស្ដ និងផ្ដល់សក្ខីភាពអំពីព្រះអង្គ *(យហ ១៧, ២៣)*។ ព្រះសហគមន៍មានបេសកកម្មណែនាំមនុស្សគ្រប់ជាតិសាសន៍ឲ្យចូលក្នុងព្រះរាជ្យព្រះជាម្ចាស់ *(ព្រះសហគមន៍ ពុំមានបេសកកម្មណែនាំមនុស្សលោកឲ្យចូលក្នុងព្រះសហគមន៍ទេ)*។ ព្រះសហគមន៍នៅក្នុងលោក ដើម្បីបម្រើព្រះរាជ្យព្រះជាម្ចាស់។ ព្រះសហគមន៍មិនមែនជាគោលដៅរបស់ខ្លួនទេ ប៉ុន្តែគោលដៅរបស់ព្រះសហគមន៍ គឺព្រះរាជ្យរបស់ព្រះជាម្ចាស់វិញ។

## សេចក្ដីបញ្ចប់៖

ក្នុងឯកសារ Nostra aetate នៃមហាសន្និបាតវ៉ាទីកង់ទី ២ ពួកលោកអភិបាលសង្កេតឃើញថា ទោះបីជាមនុស្សកាន់សាសនាផ្សេងៗយ៉ាងណាក៏ដោយ ក៏ពួកគេនៅតែមានសំណួរដដែល៖ *"មនុស្សផងទាំងពួងតែងតែបារម្ភយ៉ាងខ្លាំងក្នុងចិត្តនិងសួរខ្លួនឯងថា៖ តើអ្វីទៅមនុស្ស? តើជីវិតមនុស្សយើងមានអត្ថន័យយ៉ាងណា? តើជីវិតមនុស្សយើងមានទិសដៅទៅណាដែរ? តើអ្វីទៅបុណ្យអ្វីទៅបាប? តើទុក្ខវេទនាកើតពីប្រភពណាមក ហើយមានទិសដៅយ៉ាងណា? តើមានមាគ៌ាណាអាចនាំមនុស្សយើង ឆ្ពោះទៅកាន់សុភមង្គលដ៏ពិតប្រាកដបាន? តើអ្វីជាសេចក្ដីស្លាប់? ក្រោយពីស្លាប់ តើមានវិនិច្ឆ័យកាត់ទោស និងទទួលរង្វាន់ឬយ៉ាងណា? តើអ្វីជាការអាថ៌កំបាំងដ៏អស្ចារ្យចុងក្រោយបំផុតនៃជីវិតមនុស្សដែលរកថ្លែងពុំបាន? ការអាថ៌កំបាំងដ៏អស្ចារ្យនេះជាប្រភពនៃជីវិតយើងឬទេ? តើយើងកំពុងតម្រង់ទៅរកការអាថ៌កំបាំងនោះទៀតដែរឬ?"* (NA ១)។

សាសនានីមួយៗមានចម្លើយប្លែកពីគ្នា។ មហាសន្និបាតវ៉ាទីកង់ទី ២ ទទួលស្គាល់សេចក្ដីពិត ដែលមានទុកក្នុងសាសនាដទៃ ហើយឆ្លើយនឹងសំណួរទាំងអស់នោះតាមគ្រីស្ដសាសនា៖ "តើអ្វីទៅមនុស្ស?(...)ព្រះសហគមន៍ជឿថា ព្រះគ្រីស្ដដែលសោយទិវង្គតនិងមានព្រះជន្មថ្មីដ៏រុងរឿងដើម្បីជាប្រយោជន៍ដល់មនុស្សទាំងអស់ *(២ករ៥,១៥)* ព្រះអង្គប្រទានពន្លឺនិងកម្លាំងឲ្យមនុស្ស ដោយសារព្រះវិញ្ញាណព្រះអង្គ ដើម្បីឲ្យមនុស្ស

អាចតបឆ្លើយស្របតាមទិសដៅដ៏ខ្ពង់ខ្ពស់របស់ខ្លួន គឺតាមព្រះជាម្ចាស់ត្រាស់ហៅ។ ព្រះសហគមន៍ជឿថា នៅក្រោមមេឃនេះក្រៅពីព្រះគ្រីស្តយេស៊ូ ព្រះជាម្ចាស់ពុំបានប្រទាននាមណាមួយផ្សេងទៀតមកមនុស្ស ដើម្បីសង្គ្រោះ យើងនោះឡើយ *(កក ៤, ១២)*។ ព្រះសហគមន៍ក៏ជឿថា អត្ថន័យដ៏សំខាន់ និងទិសដៅនៃប្រវត្តិសាស្ត្រទាំងមូលរបស់មនុស្ស ស្ថិតនៅក្នុងអង្គព្រះអម្ចាស់ និងព្រះបរមគ្រូរបស់ខ្លួន។(...) ហេតុនេះហើយបានជាមហាសន្និបាត ក្រោមពន្លឺរបស់ព្រះគ្រីស្តជារូបតំណាងរបស់ព្រះជាម្ចាស់ ដែលយើងមើលពុំឃើញជារៀមច្បងនៃសត្វលោកទាំងអស់ ដែលព្រះជាម្ចាស់បានបង្កើតមក *(កូឡ១,១៥)* មានបំណងនិយាយសន្ទនាជាមួយមនុស្សទាំងអស់ ដើម្បីបំភ្លឺការអាថ៌កំបាំងរបស់មនុស្ស និងជួយមនុស្សជាតិឲ្យរកដំណោះស្រាយចំពោះបញ្ហាដ៏សំខាន់ៗនាបច្ចុប្បន្ននេះ (GS ១០)។

ព្រះសហគមន៍ចាត់ទុកថា សាសនាដទៃរួមជាមួយគ្រីស្តសាសនានៅតាមផ្លូវនៃការសង្គ្រោះ។ ប៉ុន្តែនៅពេលជាមួយគ្នានេះ មហាសន្និបាតអះអាងថា ដោយសារព្រះគ្រីស្តព្រះជាម្ចាស់សម្តែងព្រះអង្គឲ្យបានពេញលក្ខណៈ ហើយសម្តែងមនុស្សឲ្យបានពេញលេញផងដែរ។ ក្នុងទំនាក់ទំនងជាមួយនឹងសាសនាដទៃ ព្រះសហគមន៍ ពុំមានតួនាទីលើកតម្កើងខ្លួនឲ្យបានលើសសាសនាដទៃទេ ប៉ុន្តែព្រះសហគមន៍ត្រូវផ្តល់សក្ខីភាពអំពីព្រះគ្រីស្ត ដោយគោរព អ្វីដែលស្ថិត *"ក្នុងចិត្តមនុស្ស" (យហ ២,២៥) និងដោយគោរពកិច្ចការនៃព្រះវិញ្ញាណដ៏វិសុទ្ធ ដែល "បក់ទៅទីណាក៏បាន" (យហ ៣,៨)* គឺព្រះអង្គប្រតិបត្តិក្នុងចិត្តគំនិតមនុស្សផង ក្នុងសាសនានីមួយៗផងដែរ។ ដូច្នេះ ហើយបានជាព្រះសហគមន៍រំលឹកយើងថា ត្រូវជឿទុកចិត្តលើព្រះវិញ្ញាណដ៏វិសុទ្ធ។

**សំណួរ៖**

១) សូមបកស្រាយ ១ធម ២,៤៖ តើសេចក្តីនេះលើកបញ្ហាអ្វីខ្លះ?

២) តាមគ្រីស្តសាសនា តើមនុស្សទាំងអស់អាចទទួលការសង្គ្រោះយ៉ាងដូចម្តេច?

៣) សូមបកស្រាយ *"ក្រៅពីព្រះសហគមន៍ គ្មានការសង្គ្រោះទេ"*។

៤) តើសាសនាដទៃជាផ្លូវដ៏ពិតប្រាកដ អាចនាំមនុស្សលោកឲ្យទទួលការសង្គ្រោះបានឬទេ? ហេតុអ្វី? ដូច្នេះ តើអ្នកយល់យ៉ាងដូចម្តេចអំពីតួនាទីរបស់ព្រះសហគមន៍?

៥) នៅពេលអ្នកមានទំនាក់ទំនងជាមួយនឹងពុទ្ធសាសនា តើចំណុចសំខាន់អ្វីខ្លះ ដែលអ្នកត្រូវចាប់អារម្មណ៍?